សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការរឹបអូសជាបណ្តោះអាសន្នចំពោះ អចលនវត្ថុ

ស្រាវជ្រាវពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៥ ដល់ថ្ងៃទី ៣១ ខែ ឧសភាឆ្នាំ២០១៥


គាត់តែងឡើងដោយ

និស្សិតឈ្មោះ **ឈារី ម៉ារ៉ូ**

**អៀ ហាំងឡេង**

សាស្ត្រាចារ្យណែនាំ

លោក **គង់ សុភ័ក្ត្រ**



ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៥

**២០១៤**

ឆ្នាំចូលសិក្សា ២០១១

ឆ្នាំសរសេរសារណា ២០១៥

**២០១៥**

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឈាវី ម៉ារ៉ូ** និង ខ្ញុំបាទឈ្មោះ **អៀ ហាំងឡេង** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី១៥ ឆ្នាំសិក្សា ២០១៤-២០១៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាបឋមយើងខ្ញុំទាំងពីរនាក់ សូមគោរពលំអោនកាយវិចារចិត្តប្រកបដោយកត្តញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅបំផុតអស់ពីដួងចិត្តជូនចំពោះ **លោកអ្នកមានគុណទាំងពីរ** ដែលអ្នកមានគុណទាំងពីរបានផ្តល់កំណើតដល់រូបកូន និងយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅកូនប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងបានទំនុកបំរុងកូនសព្វគ្រប់បែបយ៉ាងទាំងផ្នែកស្មារតី និងសម្ភារៈរហូតដល់កូនមានឱកាសសិក្សារៀនសូត្រចាប់ពីថ្នាក់បឋមសិក្សា រហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក-លោកស្រីសាស្ត្រាចារ្យទាំងអស់** ដែលបានខិតខំអស់ពីកំលាំងកាយចិត្ត ក្នុងការបង្ហាត់បង្រៀន និងណែនាំដល់យើងខ្ញុំយ៉ាងច្រើនទាក់ទងនឹងវិស័យច្បាប់ និងស្ថានភាពសង្គមជាក់ស្តែង ជាពិសេសបានផ្តល់នូវដំបូន្មានល្អៗ និងជួយណែនាំបង្ហាញផ្លូវដល់យើងខ្ញុំ ដើម្បីជាទុនដល់ការស្រាវជ្រាវនិងគំនិតក្នុងការតាក់តែងនូវស្នាដៃនេះឡើង។

សាស្ត្រាចារ្យ **គង់ សុភ័ក្ត្រ** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំផ្តល់យោបល់ល្អៗ និងជួយកែលម្អរាល់ចំណុចខ្វះខាតទាំងឡាយ ដើម្បីជម្រុញឲ្យសារណារបស់យើងខ្ញុំទទួលបាននូវលទ្ធផលល្អប្រសើរ។

អរគុណដល់ លោកយាយ លោកតា លោកអ៊ុំ លោកពូ បងប្រុស និងបងស្រី ព្រមទាំងមិត្តភ័ក្រ្តដែលបានផ្តល់កម្លាំងចិត្ត និងជួយផ្តល់មិតយោបល់ល្អៗដល់ខ្ញុំក្នុងការសិក្សាកន្លងមក។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមជូនពរដល់អ្នកទាំងអស់គ្នាឲ្យមានសុខភាពល្អ និងទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ចជានិរន្តន៍។

# អារម្ភកថា

ជាដំបូង យើងខ្ញុំមានអារម្មណ៍សែនត្រេកអរណាស់ដែលយើងខ្ញុំមានឱកាសបានសរសេរសារណាក្រោមចំណងជើងថា **ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ** ដែលជាសមិទ្ធផលនៃការខិតខំប្រឹងប្រែងរៀនសូត្រ សិក្សាស្រាវជ្រាវ និងរៀបចំឡើងសម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ការជ្រើសរើសប្រធានបទសារណា **ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ** នេះគឺមិនមែនជារឿងចៃដន្យនោះទេ ប៉ុន្តែក្រោយពីឆ្លងកាត់ការសិក្សាអស់រយៈពេលបួនឆ្នាំយើងខ្ញុំយល់ឃើញថាប្រធានបទសារណានេះ គឺសមប្រកបសម្រាប់សិក្សាបរិបទសង្គមប្រទេសកម្ពុជាដែលប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ហើយវិស័យអចលវត្ថុបាននឹងមានភាពរីកដុះដាលយ៉ាងខ្លាំង។ ដើម្បីទប់ស្កាត់នូវហានិភ័យ គំនិតទុច្ចរិត ក៏ដូចជាដើម្បីផ្ដល់ភាពយុត្តិធម៌ដែលអាចនឹងកើតមានជាយថាហេតុមិនអាចស្ដារឡើងវិញបាននោះ ដូច្នេះ **ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ** គឺជាយន្តការមួយដ៏ប្រសើបំផុតសម្រាប់ការពារផលប្រយោជន៍ស្របច្បាប់របស់បុគ្គលឯកជនទាំងនោះ។

ដែនកំណត់ក្នុងការស្រាវជ្រាវសារណានេះ គឺយើងខ្ញុំបានកំណត់ត្រឹម ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលវត្ថុ ដែលជាផ្នែកមួយនៃការចាត់ចែងរក្សាការពារតែប៉ុណ្ណោះ។ យើងខ្ញុំមិនបានផ្ដោតទៅលើការចាត់ចែងរក្សាការពារទាំងមូលនោះទេ ដោយសារការចាត់ចែងរក្សាការពារមានការបែងចែកជាផ្នែកផ្សេងៗទៀតដូចជា ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន។ ដូច្នេះ យើងខ្ញុំបានលើកយកនូវប្រធានបទមួយផ្នែកនៃការចាត់ចែងរក្សាការពារ ដើម្បីធ្វើការសរសេរសារណាគឺ **ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ** ។

គោលបំណងនៃការស្រាវជ្រាវលើប្រធានបទនេះ គឺចង់បង្ហាញអំពីបញ្ហានៃការរឹបអូសជាបណ្ដោះអាសន្នលើអចលវត្ថុ និងការវិវត្តនៃច្បាប់ស្របទៅតាមបរិបទសង្គមនយោបាយកម្ពុជាពីសម័យកាលមួយទៅសម័យកាលមួយដើម្បីផ្ដល់ភាពងាយស្រួលដល់អ្នកសិក្សាផ្នែកនីតិសាស្ត្រ និងអាជ្ញាធរទទួលបន្ទុកក្នុងការអនុវត្ត។

ជាចុងក្រោយ យើងខ្ញុំសូមអភ័យទោសនូវកំហុសឆ្គងពាក្យពេជន៍ អក្ខរាវិរុទ្ធមួយចំនួន ឬរាល់ចំណុចខ្វះខាតទាំងឡាយដែលអាចកើតមានឡើងដោយចេតនាក្ដី និងអចេតនាក្ដី យើងខ្ញុំនឹងរីករាយទទួលនូវការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឲ្យសារណានេះកាន់តែមានភាពល្អប្រសើរ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ..................................................................................................... ១

**ជំពូកទី១ សញ្ញាណទូទៅការរឹបអូសជាបណ្តោះអាសន្ន** ................................................ ៤

**១.១. ខ្លឹមសារនៃការរឹបអូសជាបណ្តោះអាសន្ន** .......................................................... ៤

១.១.១. អត្ថន័យ ........................................................................................... ៤

១.១.២. ប្រវត្តិនៃការរឹបអូសជាបណ្តោះអាសន្ន ....................................................... ៤

១.១.៣. វិសាលភាពនៃរឹបអូសជាបណ្តោះអាសន្ន ...................................................... ៦

**១.២. គោលបំណងនិងប្រភេទនៃការរឹបអូសជាបណ្តោះអាសន្ន** ......................................... ៦

១.២.១. គោលបំណង ...................................................................................... ៦

១.២.២. ប្រភេទនៃការរឹបអូសជាបណ្តោះអាសន្ន ....................................................... ៦

១.២.២.១. ការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ........................................... ៧

១.២.២.២. ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ......................................... ៧

១.២.២.៣. ការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល ..................................... ៧

**១.៣. ចរិតលក្ខណៈនៃការរក្សាការពារ** .................................................................... ៨

១.៣.១. លក្ខណៈបណ្តោះអាសន្ន ........................................................................ ៨

១.៣.២. លក្ខណៈបន្ទាន់បង្ខំ .............................................................................. ៨

១.៣.៣. លក្ខណៈបន្ទាប់បន្សំ ............................................................................. ៩

១.៣.៤. លក្ខណៈសម្ងាត់ ................................................................................. ១០

**ជំពូកទី២ នីតិវិធីចំពោះការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ** ...... ១២

**២.១. សមត្ថកិច្ចរបស់យុត្តាធិការ** .......................................................................... ១២

២.១.១. តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ................................................ ១២

២.១.២.សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុជាកម្មវត្ថុនៃវិវាទស្ថិតនៅ . ១៣

**២.២. លក្ខខណ្ឌនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលវត្ថុ** .................................... ១៣

២.២.១. សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ........................................ ១៣

២.២.២. ភាពចាំបាច់នៃការរក្សាការពារ .................................................................. ១៤

**២.៣. ពាក្យសុំដីការឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ** ............................ ១៤
២.៣.១. ទម្រង់នៃពាក្យសុំ និងសេចក្ដីបញ្ជាក់ដំបូង .................................................... ១៥
២.៣.២. ពន្ធដាក់ពាក្យសុំ និងប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ .................................... ១៩
**២.៤. ការពិនិត្យលើពាក្យសុំដីការឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ** ......... ១៩
២.៤.១. កម្មវត្ថុនៃការពិនិត្យ ............................................................................... ២០
២.៤.២. នីតិវិធីនៃការពិនិត្យ ............................................................................... ២០
**២.៥. ការចេញដីកាសម្រេចលើពាក្យសុំ** ............................................................. ២២
២.៥.១. ដីកាសម្រេចបង្គាប់ឲ្យរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ................. ២២
២.៥.២. ទម្រង់ដីកាសម្រេចបង្គាប់ឲ្យរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ........ ២២
២.៥.៣. ប្រាតិភោគ ........................................................................................ ២៥
២.៥.៣.១. គោលបំណងនៃការដាក់ប្រាតិភោគ ..................................................... ២៥
២.៥.៣.២. ចំនួននៃប្រាតិភោគ ......................................................................... ២៥
២.៥.៣.៣. អំឡុងពេលនៃការដាក់ប្រាតិភោគ ...................................................... ២៦
២.៥.៤. ប្រាក់រំដោះ ....................................................................................... ២៧
២.៥.៤.១. គោលបំណងនៃការដាក់ប្រាក់រំដោះ .................................................... ២៧
២.៥.៤.២. ចំនួននៃការដាក់ប្រាក់រំដោះ ............................................................. ២៧
២.៥.៥. ដីកាសម្រេចលើកចោលពាក្យសុំ .............................................................. ២៨
**២.៦. ការបញ្ជូនដីកាសម្រេច** ............................................................................ ២៩
២.៦.១. ការបញ្ជូនដោយប្រគល់ ........................................................................ ២៩
២.៦.២. ការបញ្ជូននៅកន្លែងជួបប្រទះ ................................................................. ៣០
២.៦.៣. ការបញ្ជូនដោយបង្គ្រប់កិច្ច ..................................................................... ៣០
២.៦.៤. ការបញ្ជូនដោយទុកចោល ....................................................................... ៣១
២.៦.៥. ការបញ្ជូនទៅបរទេស ........................................................................... ៣១
២.៦.៦. ការបញ្ជូនតាមការផ្សាយជាសាធារណៈ ...................................................... ៣១
**ជំពូកទី៣ ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះ អចលនវត្ថុ** ........................................................................................ ៣៥
**៣.១. ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះ អចលនវត្ថុ** ........................................................................................ ៣៥

**៣.២. ពាក្យសុំឲ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះ អចលនវត្ថុ** ........................................ ៣៥
៣.២.១. ទម្រង់ពាក្យសុំឲ្យអនុវត្តដីកាសម្រេច និងឯកសារដែលត្រូវភ្ជាប់ ........................ ៣៥
៣.២.១.១. ទម្រង់ពាក្យសុំឲ្យអនុវត្តដីកាសម្រេច ........................................ ៣៥
៣.២.១.២. ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំឲ្យអនុវត្តដីកាសម្រេច ............... ៣៦
៣.២.២. ការពិនិត្យលើពាក្យសុំ និង ការពិនិត្យលើល័ក្ខខ័ណ្ឌចាំបាច់ ............................. ៣៧
៣.២.២.១. ការពិនិត្យលើពាក្យសុំ ........................................ ៣៧
៣.២.២.២. ការពិនិត្យលើល័ក្ខខ័ណ្ឌចាំបាច់នៃការអនុវត្តដីកាសម្រេច ........................ ៣៧
**៣.៣. ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ** ........................ ៣៨
៣.៣.១. ការអនុវត្តចំពោះអចលនវត្ថុដែលបានចុះបញ្ជី ........................................ ៣៨
៣.៣.១.១. ទម្រង់នៃលិខិតផ្ទុកផ្ដាក់ ........................................ ៣៩
៣.៣.១.២. របៀបចុះបញ្ជីសម្រាប់ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះ អចលវត្ថុ ........................................ ៣៩
៣.៣.២. ការអនុវត្តចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ........................................ ៤២
**៣.៤. អានុភាពនៃការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ** .... ៤៣
**៣.៥. ការផ្អាកការអនុវត្តចំពោះការរឹបអូសជាបណ្ដោះអាសន្ន** ........................ ៤៣
**៣.៦. ការលុបចោលប្រាតិភោគ** ........................................ ៤៤
**ជំពូកទី៤ បណ្ដឹងឧបាស្រ័យ** ........................................ ៤៥
**៤.១. ពាក្យសុំតវ៉ាចំពោះការរឹបអូសជាបណ្ដោះអាសន្នលើអចលវត្ថុ** ........................ ៤៦
៤.១.១. ការដាក់ពាក្យសុំតវ៉ា ........................................ ៤៦
៤.១.២. ល័ក្ខខ័ណ្ឌនៃពាក្យសុំតវ៉ា ........................................ ៤៦
៤.១.៣. ការវិនិច្ឆ័យអំពីការពាក្យសុំតវ៉ា ........................................ ៤៧
៤.១.៤. ដីកាសម្រេចអំពីពាក្យសុំតវ៉ា ........................................ ៤៧
**៤.២. ការលុបចោលនៃដីកាសម្រេច** ........................................ ៤៨
៤.២.១. ការមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ........................................ ៤៨
៤.២.២. ការផ្លាស់ប្ដូរស្ថានភាព ........................................ ៤៩
៤.២.៣. ការអស់សុពលភាពនៃដីកាសម្រេច ........................................ ៥០
**៤.៣. អានុភាពនៃការលុបចោល** ........................................ ៥១

៤.៣.១. ពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ................................... ៥២
៤.៣.២. ពាក្យសុំអនុវត្តការរឹបអូសជាបណ្តោះអាសន្នត្រូវបានដក ............................... ៥២
៤.៣.៣. ដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះ
អចលនវត្ថុ ........................................................................................ ៥៣
៤.៣.៤. នីតិវិធីការលុបការចុះបញ្ជី ........................................................................ ៥៥
**៤.៤. បណ្តឹងជំទាស់** ................................................................................................ ៥៦
៤.៤.១. របៀបប្តឹងជំទាស់ ........................................................................................ ៥៧
៤.៤.២. ការសម្រេចសេចក្តី ........................................................................................ ៥៧
**សេចក្តីសន្និដ្ឋាន** ........................................................................................................ ៦០
**អនុសាសន៍** ................................................................................................................ ៦២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នៅក្នុងសង្គមសេដ្ឋកិច្ចទីផ្សារសេរី បុគ្គលឯកជនម្នាក់ៗដែលជាសមាជិកសង្គមនោះ ចូលរួមក្នុងជីវភាពសេដ្ឋកិច្ច តាមរយៈការដោះដូរទំនិញ និងសេវាដោយប្រើរូបិយវត្ថុជាចម្បង។ វាជារឿងធម្មតានៅក្នុងការដោះដូរទំនិញ និងសេវាត្រូវធ្វើឡើងតាមរយៈកិច្ចសន្យា ឬការសន្យារបស់បុគ្គលម្នាក់ជាមួយនឹងបុគ្គលម្នាក់ទៀត ឬច្រើននាក់ដែលពាក់ព័ន្ធ ដោយធ្វើឡើងទៅតាមទំនៀមទំលាប់នៃទីកន្លែង ឬទៅតាមការអនុវត្តតៗគ្នាពីមុនមករបស់ពួកគេទាំងអស់នោះ។ នៅក្នុងករណីជាច្រើនបុគ្គលនានាប្រតិបត្តិតាមកិច្ចសន្យាដោយគោរពសិទ្ធិរបស់ភាគីម្ខាងទៀត ហើយអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយសេចក្តីសុចរិត និងស្មោះត្រង់។ ជារឿងធម្មតាទេ ដែលប្រជាពលរដ្ឋរស់នៅក្នុងប្រទេសនីមួយៗត្រូវតែគោរពច្បាប់ ក៏ដូចគ្នាផងដែរ បុគ្គលនានាតាំងចិត្តគោរពការសន្យារបស់ខ្លួនដោយបុព្វហេតុទំនុកចិត្តលើសង្គម ឬដោយសារតែបុព្វហេតុខាងសាសនាជាដើម។

ភាពរីកចម្រើនឥតឈប់ឈររបស់កម្ពុជា ដែលជាប្រទេសប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យដែលគោរពទៅលើសិទ្ធិ សេរីភាពក្នុងការធ្វើសកម្មភាពពាណិជ្ជកម្ម និងសិទ្ធិក្នុងការធ្វើសកម្មភាពទាំងឡាយរបស់ពលរដ្ឋដើម្បីធានានូវគុណភាពជីវិត ព្រមទាំងបានទទួលស្គាល់នូវរបបកម្មសិទ្ធិឯកជនទៀតផង។ ដើម្បីឆ្លើយតប ទៅនឹងភាពរីកចម្រើនឥតឈប់ឈរជាមួយនឹងការប្រែប្រួលស្ថានភាពសង្គមនយោបាយ រដ្ឋបានបង្កើតឲ្យមាននូវទំនើបកម្មគតិយុត្តឲ្យស្របទៅតាមស្ថានភាពជាក់ស្តែងរបស់សង្គមក្នុងគោលបំណង ដើម្បីគ្រប់គ្រងទៅលើបណ្តាសកម្មភាពទាំងអស់ របស់ពលរដ្ឋប្រកបដោយប្រសិទ្ធភាពធានារក្សាបាននូវសណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គមពីព្រោះការបង្កើតទំនាក់ទំនងគតិយុត្តក្នុងសកម្មភាពពាណិជ្ជកម្ម អាចបង្កើតឲ្យមានការខ្វែងគំនិតគ្នាខាងផ្នែកផលប្រយោជន៍ ដែលជាហេតុនាំឲ្យកើតមានជម្លោះ។

ដើម្បីទប់ស្កាត់នូវ បញ្ហាផ្សេងៗដែលនឹងអាចកើតមានជាយថាហេតុនោះទើបជម្រុញឲ្យកិច្ចសហប្រតិបត្តិការរវាងក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (**JICA**) បានបង្កើតឲ្យមានក្រមនីតិវិធីរដ្ឋប្បវេណី ដែលក្រមនីតិវិធីរដ្ឋប្បវេណីថ្មីនៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តនៅថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ២០០៦ និងចូលជាធរមាននៅរាជធានីភ្នំពេញថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០០៧ នឹងទូទាំងប្រទេសថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៧ ដោយយោលតាមបញ្ញត្តិស្តីពីអវសានប្បញ្ញត្តិ នៃក្រមនីតិវិធីរដ្ឋប្បវេណីថ្មី រួមទាំងរដ្ឋធម្មនុញ្ញផងដែរ។ ក្រមនេះបានបញ្ញត្តិស្តីពីការរឹបអូសជាបណ្តោះអាសន្ន ដែលស្ថិតនៅក្នុងការចាត់ចែងរក្សាការពារចាប់ពីមាត្រា៥៣០ ដល់មាត្រា ៥៧១។ មុនក្រមនីតិវិធីរដ្ឋប្បវេណីបញ្ញត្តិអំពី ការរឹបអូសជាណ្តោះ នេះក៏ដោយក៏នៅក្នុង

ច្បាប់ ឬសារាចរចាស់ក៏បាននិយាយអំពី ការរឹបអូសនេះផងដែរ។ ក្រមនីតិវិធីរដ្ឋប្បវេណី មានខ្លឹមសារជាសំខាន់និយាយអំពីការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ។ ការចាត់ចែងរក្សាការពារ គឺជានីតិវិធីមួយដែលមាន គោលបំណងការពារ និងថែរក្សាស្ថានភាពបច្ចុប្បន្ន ដោយប្រើអំណាចរបស់រដ្ឋ ហើយការចាត់ចែងរក្សាការពារ ជានីតិវិធីមួយខុសប្លែកពីការអនុវត្តនូវនីតិវិធីផ្សេងៗទៀត ហើយត្រូវបានលើកយកមកពិភាក្សាជាប្រធានបទសារណានៅពេលនេះ។

ជាបឋម យើងនឹងធ្វើការស្វែងយល់ទៅលើខ្លឹមសារជារួម នៃប្រធានបទសារណានេះជាមុនសិន។ យន្តការនៃការរឹបអូសជាបណ្តោះអាសន្នលើអចលវត្ថុ គឺជាវិធានការនៃការការពារជាបណ្តោះអាសន្ន និងជាផ្នែកមួយនៃវិធានការក្នុងការប្រើសិទ្ធិរបស់បុគ្គលឯកជន ដើម្បីពឹងពាក់តុលាការជួយអន្តរាគមន៍ការពារផលប្រយោជន៍របស់ខ្លួន។ ម្យ៉ាងវិញទៀត គោលបំណងនៃវិធានការនេះ គឺដោយសារតែម្ចាស់បំណុលមានការបារម្ភថាការអនុវត្តដោយបង្ខំនឹងមិនអាចដោសារតែមានការប្រែប្រួលនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ។ ជារួមមក គឺដើម្បីរក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងកម្រិតនូវរឹបអូសជាបណ្តោះអាសន្ន ទៅលើទ្រព្យសម្បត្តិរបស់កូនបំណុលក្នុងករណីម្ចាស់បំណុលមានការបារម្ភថា ការអនុវត្តដោយបង្ខំនាពេលអនាគតអាចកើតមានឧបសគ្គដល់ការសម្រេចនូវសិទ្ធិទាមទាររបស់ខ្លួនដោយហេតុថា៖ ដំណើរការនៃនីតិវិធីបណ្តឹងអង្គសេចក្តីមានភាពស្មុគស្មាញ និងចំណាយពេលវេលាយូរទំរាំមានសាលក្រម ឬសាលដីកាដែលកំណត់ពីទំនាក់ទំនងគតិតយុត្តរវាងគូភាគីដោយផ្អែកតាមច្បាប់សារធាតុនោះ។

ហេតុនេះហើយ ដើម្បីជៀសវាងនូវហានិភ័យដែលនឹងអាចកើតមានឡើងជាយថាហេតុចំពោះម្ចាស់បំណុល គឺការរឹបអូសជាបណ្តោះអាសន្នបានធ្វើការហាមឃាត់កូនបំណុលមិនឲ្យធ្វើអនុប្បទាន លក់ ដូរ ជួល បញ្ចាំ ហ៊ីប៉ូតែក ធ្វើមរតក ឬអច្ច័យទាន ជាអាទិ៍ នូវទ្រព្យសម្បត្តិរបស់ខ្លួនឲ្យទៅអ្នកដទៃនោះ គឺជារឿងសំខាន់ និងចម្បងបំផុត។

ដោយអនុឡោមតាមមាត្រា១៩៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ សញ្ញាណនៃវត្ថុត្រូវបានផ្តល់និយមន័យថា វត្ថុសំដៅទៅលើរបស់ដែលមានរូបរាង ជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសាធាតុរឹង។ ម្យ៉ាងទៀតតាមមាត្រា ១២០ នៃក្រមរដ្ឋប្បវេណីដដែលនេះ បានធ្វើការបែងចែកវត្ថុជាពីរគឺ ចលនវត្ថុ និងអចលវត្ថុ និងផ្តល់អត្ថន័យថា ចលនវត្ថុ គឺសំដៅលើវត្ថុទាំងឡាយណាក្រៅពីអចលវត្ថុ ចំណែកឯ អចលនវត្ថុ គឺសំដៅទៅលើវត្ថុជាប់នឹងដី ហើយមិនអាចផ្លាស់ទីកន្លែងបាន។ សញ្ញាណនៃអចលនវត្ថុ ត្រូវបានឲ្យនិយមន័យផ្សេងៗគ្នា ដោយអាស្រ័យតាមបរិបទច្បាប់នីមួយៗ បើតាមមាត្រា៨១៧ ក្រមនីតិវិធីរដ្ឋប្បវេណី បានផ្តល់អត្ថន័យថាអលចនវត្ថុសំដៅលើដី ឬអាគារ ដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគ

ដែលបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម។ ទាក់ទងទៅនឹងសញ្ញាណ នៃវត្ថុដែលលើកយកមកសិក្សាស្វែងយល់នៅក្នុងប្រធានបទសារណានេះសំដៅទៅលើ អចលនវត្ថុ។

ម្យ៉ាងវិញទៀត ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួនគេចផុតពីការអន្តរាយដែលអាចនឹងកើតឡើងជាយថាហេតុដោយមិនអាចស្តារឡើងវិញបាននោះ បុគ្គលដែលមានសិទ្ធិលើបំណុលអាចដាក់ពាក្យសុំឲ្យធ្វើការរឹបអូសជាបណ្ដោះអាសន្ន ហាមឃាត់លើទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលជាបណ្ដោះអាសន្ន។ ការធ្វើបែបនេះ ដើម្បីឲ្យរដ្ឋអាចចូលរួមជួយអន្តរាគមន៍ក្នុងការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួនបានពីព្រោះបុគ្គលឯកជនម្នាក់មិនអាចបង្ខំឲ្យបុគ្គលឯកជនម្នាក់ទៀតដែលសន្មតថាមានករណីកិច្ច ចំពោះខ្លួនដោយប្រើកម្លាំងឯកជននោះទេ។

ដូច្នេះ តើយន្តការនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ អាចប្រព្រឹត្តទៅបានដោយបំពេញតាមលក្ខណៈអ្វីខ្លះ? តើម្ចាស់បំណុលដែលជាអ្នកមានសិទ្ធិស្របច្បាប់ត្រូវធ្វើបែបណាដើម្បីការពារផលប្រយោជន៍របស់ខ្លួន? តើអាជ្ញាធរពាក់ព័ន្ធត្រូវមានសមត្ថកិច្ចអនុវត្តសកម្មភាពបែបណាខ្លះនៅក្នុងនីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនោះ?

ដើម្បីឆ្លើយតបនឹងសំនួរខាងលើនេះ យើងសូមធ្វើការបកស្រាយក្នុងប្រធានបទសារណានេះដោយធ្វើការបែងចែកជាបួនផ្នែកធំៗដូចខាងក្រោមនេះ៖

**ជំពូកទី ១៖** សញ្ញាទូទៅការរឹបអូសជាបណ្ដោះអាសន្ន

**ជំពូកទី ២៖** នីតិវិធីចំពោះការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

**ជំពូកទី ៣៖** ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

**ជំពូកទី ៤៖** បណ្ដឹងឧបាស្រ័យ

# ជំពូកទី១
# សញ្ញាណទូទៅការរឹបអូសជាបណ្តោះអាសន្ន

ការរឹបអូសជាបណ្តោះអាសន្ន គឺជាវិធានការមួយស្ថិតនៅក្នុងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ ដែលការរឹបអូសជាបណ្តោះអាសន្ន ស្ថិតនៅគន្ថីទី៧ ការចាត់ចែងរក្សាការពារ។ ហើយការចាត់ចែងរក្សាការពារ មានការបែងចែកជាបីប្រភេទផ្សេងៗគ្នា ក្នុងនោះមានដូចជា៖ ១.ការរឹបអូសជាបណ្តោះអាសន្ន, ២. ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ៣. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន[1]។ ដូច្នេះ ការបកស្រាយប្រធានបទផ្តោតទៅលើការរឹបអូសជាបណ្តោះអាសន្ន ហើយមុននឹងធ្វើការបកស្រាយ ឬសិក្សាទៅលើការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចាំបាច់ត្រូវស្គាល់សញ្ញាណមួយចំនួនជាមុនសិន។

## ១.១. ខ្លឹមសារនៃការរឹបអូសជាបណ្តោះអាសន្ន

### ១.១.១. អត្ថន័យ

ការររឹបអូសជាបណ្តោះអាសន្ន គឺជាវិធានការមួយដើម្បីការពារជាបណ្តោះអាសន្ននូវសិទ្ធិរបស់ម្ចាស់បំណុល។ ទន្ទឹមនឹងនោះ ការរឹបអូសជាបណ្តោះអាសន្នគឺជាប្រភេទមួយ ដែលតុលាការមានគោលបំណងចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់[2]។ ហើយការរឹបអូសជាបណ្តោះអាសន្ន កម្រិតនូវការចាត់ចែងទ្រព្យរបស់កូនបំណុល រក្សានូវស្ថានភាពបច្ចុប្បន្ននៃទ្រព្យរបស់កូនបំណុល ធ្វើឡើងក្នុងករណីសិទ្ធិដែលត្រូវបានរក្សាការពារ គឺជាសិទ្ធិទាមទារឲ្យសងជាប្រាក់។

### ១.១.២. ប្រវត្តិនៃការរឹបអូសជាបណ្តោះអាសន្ន

ការរឹបអូសជាបណ្តោះអាសន្ន កើតឡើងដោយសារាចរ ស្តីពីសេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី ដែលវាជាកម្មវត្ថុចាំបាច់របស់ក្រសួងយុត្តិធម៌ក្នុងការបង្កើតនូវសារាចរនេះដើម្បីសម្របសម្រួលដោះស្រាយជម្លោះក្នុងវិស័យតុលាការ រួមទាំងការពន្លឿននៅនីតិវិធិ និងសំរាប់បម្រើឲ្យផលប្រយោជន៍ប្រជាពលរដ្ឋ។

សេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី អយ្យការ និងតុលាការប្រជាជនខេត្តក្រុង បានដំណើរការនិងបានអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយជោគជ័យ។ ក្នុងវិស័យព្រហ្មទណ្ឌ ការចោទប្រកាន់ និងការបើកសវនាការជំនុំជម្រះ បាននាំមកនូវឥទ្ធិពលយ៉ាងល្អប្រពៃ ក្នុងការរួមចំណែកការពារ និង

[1] មាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[2] មាត្រា ៥៣១.ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

កសាងមាតុភូមិ ជាពិសេសក្នុងការពារសន្តិសុខសង្គម របៀបរៀបរយសាធារណៈ ការពារទ្រព្យសម្បត្តិរដ្ឋ ការពារអាយុជីវិត និងទ្រព្យសម្បត្តិស្របច្បាប់ របស់ពលរដ្ឋ។

រីឯក្នុងវិស័យរដ្ឋប្បវេណីវិញ អាពាហ៍ពិពាហ៍ និងគ្រួសារ តុលាការប្រជាជនខេត្ត ក្រុងក៏បានដំណើរការផ្សះផ្សារគូភាគីឲ្យជានានឹងគ្នាឡើងវិញ បានច្រើនរឿង សំដៅធ្វើឲ្យប្រជាជនមានសាមគ្គីភាពឯកភាពគ្នារួមកំលាំងគ្នា ជំរុញការបង្កបង្កើនផល និងថែរក្សាស្ថេរភាពនៃការរស់នៅរបស់ខ្លួន។

ប៉ុន្តែទន្ទឹមនឹងលទ្ធផលដ៏ប្រពៃដែលអយ្យការ និងតុលាការប្រជាជនខេត្ត ក្រុង ដណ្តើមនោះ ក្រសួងយុត្តិធម៌ក៏បានមើលឃើញការលំបាក និងមានភាពស្មុគស្មាញមួយចំនួន ក្នុងការងាររបស់តុលាការប្រជាជន ផ្នែករដ្ឋប្បវេណី។ តុលាការប្រជាជនផ្នែករដ្ឋប្បវេណី ពុំទាន់បានបើកសវនាការជំនុំជម្រះរឿងរដ្ឋប្បវេណី រឿងអាពាហ៍ពិពាហ៍ និងគ្រួសារឡើយ ធ្វើឲ្យរឿងប្រភេទនេះ ដែលផ្សះផ្សា ពុំបានសម្រេចនោះ នៅសល់កាន់តែច្រើនឡើងៗ។ បាតុភាពនេះបើមានតទៅទៀតជាហេតុមួយនាំឲ្យប្រជាជន ថ្នាំងថ្នាក់ចិត្ត និងអស់ជំនឿលើតុលាការប្រជាជន ក្នុងការធ្វើដំណោះស្រាយរឿងទំនាស់របស់គេ[3]។

ដូច្នេះ ប្រវត្តិនៃការរឹបអូសជាបណ្តោះអាសន្ន មានចាប់តាំងពីឆ្នាំ ១៩៨៤ ដែលបង្កើតឡើងដោយសារាចរលេខ ០៤ សរច ៨៤ របស់ក្រសួងយុត្តិធម៌។ ថ្វីបើការរឹបអូសជាបណ្តោះអាសន្ននៅសម័យនោះ គេហៅថាវិធានការបណ្តោះអាសន្នៈ ចែងនៅ ឧប្បត្តិហេតុក្នុងអំឡុងនីតិវិធី ដែលវិធានការបណ្តោះអាសន្នៈ បានបញ្ញត្តិថា ចាប់តាំងពីពេលទទួលពាក្យបណ្តឹង រហូតដល់ពេលជំនុំជម្រះ ចៅក្រមមានសិទ្ធិចេញដីកាសម្រេចជាការប្រញាប់ តាមដានសំណូមពររបស់គូភាគី ប្រសិនបើយល់ឃើញថាចាំបាច់។ ដីកាសម្រេចនេះមានគោលដៅបង្ការអន្តរាយផ្សេងៗ ដែលអាចកើតមានជាយថាហេតុដូចជាដីការសម្រេចឲ្យប្តី និងប្រពន្ធ ដែលសុំលះលែងគ្នា បែកលំនៅពីគ្នាជាបណ្តោះអាសន្ន ដីកាសម្រេចឲ្យភាគីម្ខាងចិញ្ចឹមអាហារកិច្ចកូនជាបណ្តោះអាសន្ន។ ដីកាសម្រេចឲ្យកត់ទ្រព្យសម្បត្តិ និងប្រគល់សិទ្ធិដល់ជនណាម្នាក់ ឲ្យថែរក្សាជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិដែលមានទំនាស់ ឬទ្រព្យសម្បត្តិសំរាប់ការពារផលប្រយោជន៍របស់គូភាគី។

ចៅក្រម ចេញដីកាសម្រេចជាការប្រញាប់បាន ចំពោះតែកិច្ចការជាបណ្តោះអាសន្ន ដែលមិនបានប៉ះពាល់ទៅដល់អង្គសេចក្តី។ ដីកាសម្រេចនេះ មិនអាចប្តឹងជំទាស់បានឡើយ។[4]

[3] ទំព័រទី ១១៩៥ សារាចរ លេខ ០៤ សរច ៨៤ ឆ្នាំ ១៩៨៤ ស្តីពី សេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី ភ្នំពេញ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៨៤

[4] ទំព័រទី ១២០៧ សារាចរ លេខ ០៤ សរច ៨៤ ឆ្នាំ ១៩៨៤ ស្តីពី សេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី ភ្នំពេញ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៨៤

### ១.១.៣. វិសាលភាពនៃការរឹបអូសជាបណ្តោះអាសន្ន

ការរឹបអូសជាបណ្តោះអាសន្នមានវិសាលភាពទៅលើ ចលនវត្ថុ អចលវត្ថុ និងសិទ្ធិលើបំណុល ពីព្រោះការអនុវត្តរបស់វាធ្វើឡើងតែ ក្នុងករណីនៃសិទ្ធិដែលត្រូវបានរក្សាការពារ គឺជាសិទ្ធិទាមទារឲ្យសងជាប្រាក់ប៉ុណ្ណោះ មិនមែនជាការទាមទារឲ្យប្រគល់អ្វីមួយក្រៅពីប្រាក់នោះទេ។

## ១.២. គោលបំណងនិងប្រភេទនៃការរឹបអូសជាបណ្តោះអាសន្ន

### ១.២.១. គោលបំណង

គោលបំណងសំខាន់នៅក្នុងការរឹបអូសជាបណ្តោះអាសន្ន គឺដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បំណុល ក្នុងការប្រើប្រាស់សិទ្ធិទាមទារបំណុល ដោយការដាក់ពាក្យសុំឲ្យអនុវត្តពីតុលាការទៅអនុវត្តដោយបង្ខំលើកូនបំណុលរបស់ខ្លួន[5]។ ហេតុអ្វីបានជាមានការរៀបចំឲ្យមាននីតិវិធី ឬគោលបំណងបែបនេះ? ពីព្រោះថា នីតិវិធីរបស់តុលាការប្រើប្រាស់នូវរយៈពេលវែងទំរាំបានចេញជាលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តទៅលើកូនបំណុលបាន។ ម្យ៉ាងវិញទៀត ម្ចាស់បំណុលមានការបារម្ភថា បណ្តឹងរបស់ខ្លួនពុំមានឥទ្ធិពលលើវត្ថុ ដែលជាកម្មវត្ថុនៃបណ្តឹងទេ នៅពេលដែលនីតិវិធីរបស់តុលាការកំពុងដំណើការ។

នីតិវិធីរបស់តុលាការមានរយៈពេលវែងនេះហើយធ្វើឲ្យម្ចាស់បំណុលបាត់បង់ផលប្រយោជន៍ជាច្រើនដោយសារតែសកម្មភាពរបស់កូនបំណុល។ នៅក្នុងករណីនេះ ប្រសិនបើកូនបំណុលដឹងថាខ្លួននឹងចាញ់ក្តី គឺកូនបំណុលអាចនឹងរំដោះវត្ថុដែលពាក់ព័ន្ធ ឬទ្រព្យសម្បត្តិរបស់ខ្លួនទាំងអស់ តាមរយៈការធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនៃវិវាទដូចជា៖ ការលក់ ការដូរ ការផ្ទេរវត្ថុ ជាអាទិ៍ ដែលជាកម្មវត្ថុនៃវិវាទ។[6] ដូច្នេះ ដើម្បីការពារអំពើខាងលើនេះ ទើបក្រមនីតិវិធីរដ្ឋប្បវេណីមានយន្តការមួយហៅថា ការចាត់ចែងរក្សាការពារ (ការរឹបអូសជាបណ្តោះអាសន្ន) ដែលមានគោលបំណងពិសេស គឺការពារសិទ្ធិរបស់ម្ចាស់បំណុលទាមទារសិទ្ធិរបស់ម្ចាស់បំណុលឲ្យមានប្រសិទ្ធិភាពក្នុងទៅលើកូនបំណុល។

### ១.២.២. ប្រភេទនៃការរឹបអូសជាបណ្តោះអាសន្ន

ការរឹបអូសជាបណ្តោះអាសន្ន អាចអនុវត្តបានចំពោះវត្ថុផ្សេងទៀតដែលជាទ្រព្យរបស់កូនបំណុល ដើម្បីជៀសវាងនូវចេតនាទុច្ចរិតរបស់កូនបំណុល ដែលធ្វើអោយទ្រព្យផ្សេងនោះបាត់បង់ដោយការលក់ ឬធ្វើអនុប្បទានឲ្យតតិយជនជាដើម[7]។

---

[5] មាត្រា ៥៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[6] មាត្រា ៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[7] ទំព័រទី ៣ សៀវភៅ ស្តីពី នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអលចនវត្ថុ ដែលបង្កើតឡើងដោយសមាជិកក្រុមការងារនៃសាលាភូមិន្ទចៅក្រម នៅខែមិនា ឆ្នាំ ២០០៩

ការរឹបអូសជាបណ្ដោះអាសន្នវាមិនខុសគ្នាពី ការអនុវត្តដោយបង្ខំទេ គឺការរឹបអូសជាបណ្ដោះអាសន្នអាចធ្វើឡើងចំពោះចលវត្ថុ អចលនវត្ថុ និងសិទ្ធិលើបំណុល[8]។

### ១.២.២.១. ការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ

ការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ជាការរឹបអូសជាបណ្ដោះអាសន្នទៅលើចលនវត្ថុទាំងឡាយណារបស់កូនបំណុល ដែលម្ចាស់បំណុលបានការបារម្ភថា មិនអាចធ្វើការអនុវត្តដោយបង្ខំបាន។ ហើយការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ[9]។ ឧទាហរណ៍៖ កូនបំណុលឈ្មោះ **ក** មានរថយន្ត ឬទោចក្រយានយន្ត បានធ្វើការខ្ចីប្រាក់ពី **ខ** ១០លានរៀល ដែល **ខ** ជាម្ចាស់បំណុល ដោយសារមានការបារម្ភថាកូនបំណុលមិនលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច នឹងសងបំណុលរបស់ខ្លួនបាន។ ម្ចាស់បំណុលបានធ្វើការដាក់ពាក្យសុំទៅតុលាការធ្វើការចាត់ចែងរក្សាការពារ ដោយធ្វើការរឹបអូសជាបណ្ដោះអាសន្នទៅលើចលនវត្ថុ ដើម្បីកុំឲ្យកូនបំណុលមានការធ្វើអនុប្បទានទៅលើចលនវត្ថុទាំងអស់របស់ខ្លួន។ ចំពោះកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្នចលនវត្ថុ ជាប្រាក់អាជ្ញាសាលាមិនដកហូតទុក[10] ឬឲ្យកូនបំណុលរក្សាទុកប្រាក់នោះទេ[11] តែអាជ្ញាសាលត្រូវធ្វើប្រាក់នោះ នៅតុលាការដែលខ្លួនស្ថិតនៅ[12]។

### ១.២.២.២. ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ជាការរឹបអូសជាបណ្ដោះអាសន្ននូវអចលវត្ថុរបស់កូនបំណុលដើម្បីការពារ ថែរក្សានូវស្ថានភាពដើមនៃអចលវត្ថុ ដោយសារការមានការបារម្ភពីម្ចាស់បំណុល។ ហើយការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើតាមរបៀបចំបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន[13] ។

### ១.២.២.៣. ការរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល

សិទ្ធិលើបំណុលរបស់កូនបំណុល លើកូនបំណុលទី៣ជាប្រភេទសិទ្ធិមួយដែលជាកម្មវត្ថុនៃការចាត់ចែងរក្សាការពារ។ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុល ត្រូវធ្វើតាម

---

[8] កំណត់ហេតុបង្រៀនស្ដីពី ការអនុវត្តដោយបង្ខំ និងការចាត់ចែង ការរក្សាការពារ នៅសាលាភូមិន្ទចៅក្រម នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ នៅថ្ងៃទី ១៩-២០ ខែកុម្ភៈ ឆ្នាំ ២០០៨ ដោយលោកសាស្ត្រចារ្យ **តូម៉ូគី មីយ៉ាហ្សាគី**

[9] មាត្រា ៥៦៥.កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[10] មាត្រា ៣៨៥ កថាខណ្ឌទី ១ នៃក្រមនីវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[11] មាត្រា ៣៨៥ កថាខណ្ឌទី៤ នៃក្រមនីវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[12] មាត្រា ៥៦៥.កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[13] មាត្រា ៥៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

របៀបដែលតុលាការអនុវត្តរក្សាការពារ ចេញដីការសម្រេចដែលហាមឃាត់មិនឲ្យកូនបំណុលទី៣សងទៅកូនបំណុល[14]។ នៅក្នុងករណីនេះតុលាការត្រូវចាត់ចែងរក្សាការពារដោយការរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុលរបស់កូនបំណុលទី៣។ ឧទាហរណ៍៖ ក្នុងករណីដែលកូនបំណុលមានគណនេយ្យធនាគារ ម្ចាស់បំណុលអាចរឹបអូសជាបណ្ដោះអាសន្នលើបំណុលរបស់កូនបំណុលដើម្បីដកប្រាក់ពីធានាគាររបស់គាត់ តាមរយៈតុលាការអនុវត្ត ដោយបង្គាប់ទៅធនគារ (កូនបំណុលទី៣) មិនត្រូវបើកប្រាក់ឲ្យកូនបំណុលឡើយ។

## ១.៣. ចរិតលក្ខណៈនៃការរក្សាការពារ

### ១.៣.១ លក្ខណៈបណ្ដោះអាសន្ន

ដីកាសម្រេចរក្សាការពារ គឺជានីតិវិធីមួយដែលធ្វើឡើងដោយបណ្ដោះអាសន្ន មានន័យថាដីកាសម្រេចរក្សាការពារពុំមានឥទ្ធិពលទៅលើសេចក្ដីសម្រេចដោយសាលក្រមក្នុងបណ្ដឹងអង្គសេចក្ដីឡើយ ឬធ្វើឲ្យសេចក្ដីសម្រេចប្រែប្រួលទេ។ ទោះបីដីកាសម្រេចរក្សាការពារដែលបានចេញដោយតុលាការក៏ដោយ ក៏សិទ្ធិលើបំណុលឬសិទ្ធិទាមទារផ្សេងៗទៀតរបស់បណ្ដឹងអង្គសេចក្ដីមិនត្រូវបានបញ្ជាក់ថា មានអត្ថិភាព ឬនត្ថិភាពឡើយ[15]។

### ១.៣.២ លក្ខណៈបន្ទាន់បចុំ

នីតិវិធីនៃការចេញដីកាសម្រេចរក្សាការពារ គឺជាការប្រញាប់ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ ឬការពារការខូចខាតដែលរំពឹងថានឹងកើតមានឡើងនាពេលឆាប់ៗខាងមុខជាក់ជាមិនខាន ដូច្នេះចៅក្រមមានឆន្ទានុសិទ្ធិជ្រើសរើសយកនីតិវិធីណាមួយក៏បាន ប៉ុន្តែនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចៅក្រមកម្រនឹងធ្វើណាស់ ព្រោះពេលខ្លះធ្វើឲ្យខូចខាតដល់កម្មវត្ថុដែលត្រូវរក្សាការពារដែលបង្កឡើងដោយកូនបំណុល ចៅក្រមច្រើនតែជ្រើសរើសយកនីតិវិធីការសួរម្ចាស់បំណុល គឺមានលក្ខណៈល្អជាង គ្រាន់តែពិនិត្យភស្តុតាងជាឯកសារ ឬឲ្យភាគីធ្វើសេចក្ដីបញ្ជាក់ដំបូងលឿនៗបានហើយ។ សេចក្ដីបញ្ជាក់ដំបូងត្រូវធ្វើដោយផ្អែកលើភស្តុតាងដែលអាចឲ្យគេពិនិត្យបានភ្លាមៗបាន[16]។ បន្ទាប់ពីធ្វើសេចក្ដីបញ្ជាក់ដំបូងដែលនាំឲ្យចេញការរក្សាការពារ ហើយដីកាសម្រេចនេះត្រូវទុករយៈពេលនៃការអនុវត្តក្នុងអំឡុង២(ពីរ) សប្ដាហ៍ចាប់ពីថ្ងៃដែលចាប់បញ្ជូនទៅម្ចាស់បំណុល[17] បើម្ចាស់បំណុលមិនសុំអនុវត្តទេ នោះដីកាសម្រេចត្រូវអស់អានុភាព ប៉ុន្តែពេល

[14] មាត្រា ៥៦៦.កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[15] ទំព័រទី ៩ សៀវភៅ ស្ដីពី នីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអលចនវត្ថុ ដែលបង្កើតឡើងដោយសមាជិកក្រុមការងារនៃសាលាភូមិន្ទចៅក្រម នៅខែមិនា ឆ្នាំ ២០០៩

[16] មាត្រា ១៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[17] មាត្រា ៥៦២.កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

អនុវត្តដីកាសម្រេចនេះមិនចាំបាច់មានរូបមន្តអនុវត្ត។ ម្យ៉ាងទៀតដើម្បីឲ្យបានលឿន និងបន្ទាន់ផង ច្បាប់បានតម្រូវទៅលើសមត្ថកិច្ចផ្តាច់មុខ បានន័យថា ភាគីមិនអាចផ្លាស់ប្តូរសមត្ថកិច្ច ដោយការព្រមព្រៀងបានឡើយ[18]។

**១.៣.៣ លក្ខណៈបន្ទាប់បន្សំ**

នីតិវិធីនៃការចាត់ចែងរក្សាការពារ គឺជានីតិវិធីបន្ទាប់បន្សំដើម្បីធ្វើបណ្តឹងអង្គសេចក្តីនៅក្នុងចំណុចមួយចំនួន។ ដូចដែលបានរៀបរាប់រួចមកហើយ ដីកាសម្រេចរក្សាការពារជានីតិវិធីមួយដែលធ្វើឡើងបណ្តោះអាសន្ន វាពុំមានឥទ្ធិពលទៅលើបណ្តឹងអង្គសេចក្តីទេ ហើយវាបានកំណត់ដោយសមត្ថកិច្ចផ្តាច់មុខ នៅពេលដែលភាគីបានដាក់បណ្តឹងអង្គសេចក្តីទៅតុលាការដែលមានសមត្ថកិច្ច នោះការរក្សាការពារត្រូវតែសុំទៅតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តីនោះដែរ។

ដូច្នេះរឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ[19]។ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺតុលាការនៃការជំនុំជម្រះលើកទី១[20]។

យោងលើពាក្យសុំរបស់កូនបំណុល តុលាការត្រូវបង្គាប់ឲ្យម្ចាស់បំណុលដាក់បណ្តឹងអង្គសេចក្តីក្នុងអំឡុងពេលសមរម្យ បើម្ចាស់បំណុលខកខានមិនដាក់បណ្តឹងអង្គសេចក្តីក្នុងកំឡុងពេលដែលបានកំណត់ទេ នោះតុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារនោះ តាមការស្នើសុំរបស់កូនបំណុល[21]។

ម្យ៉ាងវិញទៀត នៅក្នុងបណ្តឹងរក្សាការពារលុះណាតែមានទំនាក់ទំនងគតិយុត្ត ឬការបង្កើតសិទ្ធិដែលត្រូវការពារ ឬភាពចាំបាច់ក្នុងរក្សាការពារ។ ក្នុងករណីដែលមានការរលត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្តនឹងត្រូវបានរក្សាការពារ ឬភាពចាំបាច់នៃរក្សាការពារ ឬមានការផ្លាស់ប្តូរស្ថានភាពផ្សេងទៀត មិនត្រឹមតែបានចេញដីកាសម្រេចរក្សាការពារប៉ុណ្ណោះទេ ថែមទាំងធ្វើការជំនុំជម្រះក្តីលើបណ្តឹងអង្គសេចក្តី អាចលុបដីកាសម្រេចនោះចោលបាន[22]។

ឧទាហរណ៍: ការចាត់ចែងរក្សាការពារការរឹបអូសរថយន្តរបស់កូនបំណុលដើម្បីធានាសំណងដល់ម្ចាស់បំណុល ប៉ុន្តែបន្ទាប់មកកូនបំណុលបានយកទៅសងម្ចាស់បំណុលតាមការ

---

[18] ទំព័រទី ១០ សៀវភៅ ស្តីពី នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអលចនវត្ថុ ដែលបង្កើតឡើងដោយសមាជិកក្រុមការងារនៃសាលាភូមិន្ទចៅក្រម នៅខែមិនា ឆ្នាំ ២០០៩

[19] មាត្រា ៥៤០.កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[20] មាត្រា ៥៤០.កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[21] មាត្រា ៥៥៧.កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[22] មាត្រា ៥៥៨.កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ទាមទារហើយនោះ ធ្វើឲ្យរលត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្តរវាងកូនបំណុល និងម្ចាស់បំណុល។ ដូច្នេះ មិនត្រឹមតែតុលាការដែលបានចេញដីកាសម្រេចរក្សាការពារប៉ុណ្ណោះទេ ដែលអាចលុបចោលដីកាសម្រេចរក្សាការពារនេះបាន គឺថែមទាំងតុលាការដែលវិនិច្ឆ័យលើងបណ្តឹងអង្គសេចក្តីអាចលុបដីកាសម្រេចរក្សាការពារនោះវិញបានតាមពាក្យសុំ[23]។

**១.៣.៤ លក្ខណៈសម្ងាត់**

ម្ចាស់បំណុល ឬអ្នកប្តឹងសុំការរក្សាការពារតែងតែបារម្ភថា នៅពេលតុលាការកំណត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្តិជាស្ថាពរហើយ ខ្លួនមិនអាចអនុវត្តនូវកិច្ចការទាំងនោះបានទេ ហើយម្ចាស់បំណុលតែងតែស្នើសុំមកតុលាការឲ្យចាត់ចែងរក្សាការពារ។ ប៉ុន្តែពេលខ្លះតុលាការតម្រូវឲ្យម្ចាស់បំណុលដាក់ប្រាតិភោគ ដើម្បីកុំឲ្យប្រើសិទ្ធិនេះហួសហេតុពេក រីឯកូនបំណុលវិញ កាលបើខ្លួនដឹងថាចាញ់ក្តី ពេលនោះខ្លួនក៏បានលួចចាត់ចែងទ្រព្យនោះទៅឲ្យអ្នកដទៃផ្សេងទៀត ក្នុងគោលបំណងគេចវេសមិនទទួលខុសត្រូវ។ ភាពសម្ងាត់នេះ គឺរក្សាផលប្រយោជន៍ឲ្យអ្នកប្តឹងសុំដែលនីតិវិធីនេះធ្វើឲ្យបាត់បង់ សិទ្ធិទាមទារឲ្យសាកសួរ គោលការណ៍ចំពោះមុខ[24] ប៉ុន្តែដោយសារមានលក្ខណៈសម្ងាត់បែបនេះហើយ ម្ចាស់បំណុលដែលជាអ្នកស្នើសុំយកដីកាសម្រេចរក្សាការពារនេះ ទៅអនុវត្តមុនពេលដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅដល់កូនបំណុលក៏ដោយ ក៏ការអនុវត្តរក្សាការពារអាចធ្វើបានដែរ[25]។ចៅក្រមអាចជ្រើសរើសយកនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ដូចជាការការពិនិត្យភស្តុតាង និងការសាកសួរសាមី ភាគីបានដែរ ប៉ុន្តែនីតិវិធីនេះអាចធ្វើជាសាធារណៈ ដូច្នេះអាចមានហានិភ័យកើតឡើងដោយកូនបំណុល ឬតតិយជនផ្សេងទៀតធ្វើឲ្យខូចប្រយោជន៍របស់ម្ចាស់បំណុល។ ដើម្បីចៀសវាងនូវហានិភ័យនេះ តុលាការត្រូវធ្វើនីតិវិធីរក្សាការពារជាសម្ងាត់ ដូច្នេះតុលាការអាចជ្រើសរើសនីតិវិធីនាំការពិនិត្យឯកសារ ឬសួរម្ចាស់បំណុល[26] ដើម្បីចេញដីកាសម្រេច។

បើកូនបំណុលយល់ឃើញថា ការចាត់ចែងរក្សាការពារនេះប៉ះពាល់ផលប្រយោជន៍របស់ខ្លួនដោយមិនសមរម្យ ទើបរបបចាត់ចែងរក្សាការពារនេះអាចអនុញ្ញាតឲ្យកូនបំណុលប្តឹងតវ៉ាបាន

[23] ទំព័រទី ១០ សៀវភៅ ស្តីពី នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអលចនវត្ថុ ដែលបង្កើតឡើងដោយសមាជិកក្រុមការងារនៃសាលាភូមិន្ទចៅក្រម នៅខែមិនា ឆ្នាំ ២០០៩

[24] មាត្រា ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[25] មាត្រា ៥៦២.កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[26] មាត្រា ១១៨.កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ហើយតុលាការក៏ពិចារណាពីបណ្តឹងតវ៉ានេះដែលនាំឲ្យតុលាការទទួលស្គាល់ផ្លាស់ប្តូរ ឬលុបចោលការចាត់ចែងរក្សាការពារនេះបានតែម្តង[27]។

[27] ទំព័រទី ១១ សៀវភៅ ស្តីពី នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអលចនវត្ថុ ដែលបង្កើតឡើងដោយសមាជិកក្រុមការងារនៃសាលាភូមិន្ទថៅក្រម នៅខែមិនា ឆ្នាំ ២០០៩

# ជំពូកទី២

# នីតិវិធីចំពោះការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

## ២.១. សមត្ថកិច្ចរបស់យុត្តាធិការ

សមត្ថកិច្ចរបស់តុលាការវាមានសារៈសំខាន់ណាស់សម្រាប់ការវិនិច្ឆ័យ។ នៅពេលដែលម្ចាស់បំណុលបានដាក់ពាក្យសុំទៅតុលាការមួយ តុលាការនេះត្រូវពិនិត្យ មើលអំពីអត្ថិភាព ឬនត្ថិភាពនៃសមត្ថកិច្ចរបស់ខ្លួនព្រមទាំងភាពត្រឹមត្រូវនៃពាក្យសុំផងដែរ។ ប្រសិនបើតុលាការរកឃើញថាខ្លួនមិនមានសមត្ថកិច្ចលើរឿងរឹបអូសជាបណ្តោះអាសន្នទេនោះ តុលាការនោះត្រូវផ្ទេររឿងក្តីនោះទៅតុលាការដែលមានសមត្ថកិច្ចតាមរយៈពាក្យសុំរបស់គូភាគីឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន[28]។ សម្រាប់រឿងដែលទាក់ទងទៅនឹងការរឹបអូសជាបណ្តោះអាសន្ននេះ សមត្ថកិច្ចរបស់តុលាការគឺជាសមត្ថកិច្ចផ្តាច់មុខ[29]។ សមត្ថកិច្ចផ្តាច់មុខជាសមត្ថកិច្ចដែលច្បាប់បានកំណត់ (មិនមែនឆន្ទៈរបស់ភាគី) ដោយសារមូលហេតុនៃផលប្រយោជន៍សាធារណៈ ឬភាពចាំបាច់ដើម្បីដោះស្រាយរឿងក្តីនោះឲ្យទាន់ពេលវេលា និងត្រឹមត្រូវ។ ដូច្នេះតុលាការដែលមានសមត្ថកិច្ច មិនអាចត្រូវ បានផ្លាស់ប្តូរដោយការព្រមព្រៀង របស់គូភាគីបានឡើយ។ តុលាការដែលមាន សមត្ថកិច្ចតាមច្បាប់កំណត់នៅក្នុងរឿងក្តីនៃដីកាសម្រេចរក្សាការពារគឺត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ ដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុដែល នឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ។

### ២.១.១. តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី

អង្គសេចក្តី គឺជារឿងក្តីនៃបណ្តឹងដែលពាក្យបណ្តឹងត្រូវបានដាក់ ចំពោះសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ អង្គសេចក្តីក៏អាចជារឿងមជ្ឈត្តកម្ម ឬក៏រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងផងដែរ។ នៅមុនពេលដាក់ពាក្យបណ្តឹងអង្គសេចក្តី តុលាការមានសមត្ថកិច្ច គឺជាតុលាការដែលមានសមត្ថកិច្ចលើរឿងក្តីនៃបណ្តឹងដែលនឹងធ្វើនាពេលអនាគត[30] ។ ជាគោលការណ៍តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើកទី១។ ប៉ុន្តែ បើអង្គសេចក្តីត្រូវបានចាត់ការនៅក្នុង នីតិវិធីបណ្តឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ច លើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍[31]។

---

[28] មាត្រា ១៨ កថាខណ្ឌ១ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[29] មាត្រា ៥៣៣ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[30]កថាភាគទី២ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចំណុច១ តុលាការនៃការរឹបអូសជាបណ្តោះអាសន្ន ទំព័រ ១៩៨ នៃ សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ

[31] មាត្រា ៥៤០ កថាខណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

បើអង្គសេចក្តីកំពុងត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្តឹងសារទុកនៅឯតុលាការកំពូល នោះត្រូវត្រឡប់ទៅរកគោលការណ៍ដើមវិញ ពោលគឺតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះ លើកទី១។

**២.១.២.សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុជាកម្មវត្ថុនៃវិវាទស្ថិតនៅ**

ក្រៅពីតុលាការមានសមត្ថកិច្ចលើអង្គសេចក្តី ច្បាប់ក៏បានអនុញ្ញាតិឲ្យសាលាដំបូងណាដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬវត្ថុ ដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅផងដែរ។ នៅក្នុងពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន បើវត្ថុ ដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ននោះ គឺជាវត្ថុក្រៅពីចលនវត្ថុ នោះអ្នកដាក់ពាក្យសុំពាក្យសុំត្រូវបញ្ជាក់ពីវត្ថុដែលជាកម្មវត្ថុនោះឲ្យបានជាក់លាក់។

**២.២. ល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលវត្ថុ**

សម្រាប់ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ នៅពេលដែលម្ចាស់បំណុល ដាក់ពាក្យសុំ ម្ចាស់បំណុលត្រូវតែសរសេរនៅក្នុងពាក្យសុំរបស់ខ្លួនពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ និងភាពចាំបាច់ និងបង្ហាញពីអត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ និងភាពចាំបាច់តាមរយៈការធ្វើសេចក្តីបញ្ជាក់ដំបូង។ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ និងភាពចាំបាច់នេះវាគឺជាល័ក្ខខ័ណ្ឌសំខាន់។

**២.២.១ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ**

សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារដោយការរឹបអូសជាបណ្តោះអាសន្នចាំបាច់ត្រូវតែជាសិទ្ធិលើបំណុលដែលមានគោលបំណងជាប្រាក់។ សិទ្ធិទាមទារដែលត្រូវបានរក្សាការពារ អាចជាសិទ្ធិដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬពេលកំណត់បាន។ ប៉ុន្តែចំពោះសិទ្ធិទាមទារដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ ចាំបាច់មានអត្ថិភាពនៃមូលដ្ឋាននៃសិទ្ធិ។ ឧទាហរណ៍ដូចជាសិទ្ធិទាមទារឲ្យសងសំណងនាពេលអនាគតរបស់អ្នកធានា និងសិទ្ធិរបស់អ្នកដាក់ពាក្យបណ្តឹង ក្នុងការទាមទារឲ្យសងវិញនូវប្រាក់ប្រដាប់ក្តីនាពេលអនាគត ចំពោះភាគីម្ខាងទៀត។ ក៏ប៉ុន្តែចំពោះសិទ្ធិទាមទារដែលពុំមានការទទួលស្គាល់តម្លៃជាទ្រព្យសម្បត្តិបច្ចុប្បន្ន ដូចជាក្នុងករណីដែលល័ក្ខខ័ណ្ឌរបស់វាកម្រនឹងបានសម្រេច ឬ ករណីដែលពេលកំណត់វានៅឆ្ងាយពេកជាដើមនោះមិនអាចត្រូវបានទទួលស្គាល់នូវល័ក្ខខ័ណ្ឌនៃសិទ្ធិដែលត្រូវបានរក្សាការពារទេ។ ក្នុងករណីដែលនៃសិទ្ធិទាមទារដែលភ្ជាប់នឹងកិច្ចសន្យាមជ្ឈត្តកម្ម ឬសិទ្ធទាមទារដែលស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការបរទេស ក៏ដោយក៏អាចធ្វើការរឹបអូសជាបណ្តោះអាសន្នបានដោយយោងតាមភាពចាំបាច់នៃការ

ចាត់ចែងរក្សាការពារ។ ចំពោះសិទ្ធិទាមទារដែលកើតចេញពីនីតិវិធីនៃរឿងក្តី រដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (ការទាមទារឲ្យផ្តល់អាហារកិច្ចជាដើម) ក៏ត្រូវអនុវត្តដូចគ្នាដែរ[32]។

### ២.២.២ ភាពចាំបាច់នៃការរក្សាការពារ

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំមិនអាច ធ្វើទៅបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ[33]។ សម្រាប់ការចេញ ដីកា សម្រេចនេះផងដែរ វាត្រូវផ្អែកទៅលើភាពរួមគ្នារវាងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារផងដែរ ដោយមិនអាចផ្អែកទៅលើអត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារតែមួយប៉ុណ្ណោះទេ។ នៅក្នុងស្ថានភាពដែលម្ចាស់បំណុលបារម្ភថាអចលនវត្ថុ ឬទ្រព្យសម្បត្តិផ្សេងទៀតរបស់កូនបំណុល អាចនឹងមានការចាត់ចែងតាមរយៈការផ្ទេរ ឬ ការលក់ជាដើម ឬក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬបានផ្លាស់ប្តូរទីលំនៅជាច្រើនលើកដែលហេតុនេះវាជាឧបសគ្គមួយសម្រាប់ការអនុវត្តដោយបង្ខំ។ ភាពចាំបាច់នេះម្ចាស់បំណុលត្រូវសរសេរយ៉ាងណាបញ្ជាក់ឲ្យបានច្បាស់អំពី តម្រូវការចាំបាច់ដើម្បីឲ្យចៅក្រមចេញដីការក្សាការពារ។ ជាពិសេស ព័ត៌មានដែលភាគីម្ចាស់បំណុលមានទាក់ទិនទៅនឹងស្ថានភាពស្ថិតនៅហានិភ័យលើទ្រព្យសម្បត្តិរបស់កូនបំណុល។ ដូចជាក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំទំនងជានឹងត្រូវធ្វើនៅបរទេស នោះការរក្សាការពារត្រូវចាត់ទុកថាមានភាព ចាំបាច់។

ឧទាហរណ៍៖ កូនបំណុលបានបង្ហាញសញ្ញាថាខ្លួនមានចេតនា ទុច្ចរិតក្នុងការលក់នូវអចលនវត្ថុនោះទៅតតិយជន ដើម្បីរួចផុតពីការរឹបអូសជាបណ្តោះអាសន្ន ហើយធ្វើការគេចខ្លួចជាដើម។

## ២.៣. ពាក្យសុំដីការឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ[34]។ ការតម្រូវឲ្យដាក់ពាក្យសុំដែលជាមូលដ្ឋានក្នុង នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ននេះធ្វើជាលាយលក្ខណ៍អក្សរ ព្រោះដើម្បីធានាភាពច្បាស់លាស់។ តុលាការអាចចេញដីការសម្រេចរក្សាការពារបានលុះត្រាតែមានពាក្យសុំរបស់ភាគីណាម្ខាងទើបជាការត្រឹមត្រូវតាមនីតិវិធី។

---

[32] កថាភាគទី១ ល័ក្ខខ័ណ្ឌនៃរឹបអូសជាបណ្តោះអាសន្ន ចំណុច១ ល័ក្ខខ័ណ្ឌលើសិទ្ធិដែលត្រូវរក្សាការពារ ទំព័រ ១៩៦ នៃសេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ៥៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ

[33] មាត្រា ៥៤៥ កថាខណ្ឌ១ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[34] មាត្រា ៥៣៤ ចំណុច ក ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

### ២.៣.១ ទម្រង់នៃពាក្យសុំ និងសេចក្តីបញ្ជាក់ដំបូង

តុលាការអាចចេញដីកាសម្រេចរក្សាការពារបានលុះត្រាតែ មានពាក្យសុំរបស់ភាគីណាម្ខាងទើបជាការត្រឹមត្រូវតាមនីតិវិធី។ ក្នុងពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ ត្រូវសរសេរបញ្ជាក់នូវចំនុចដូចខាងក្រោមនេះ៖

**ក.** ឈ្មោះ ឬ នាមករណ៍ និងអាស័យដ្ឋានរបស់ភាគី ហើយនិងឈ្មោះនិងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

**ខ.** ខ្លឹមសារនៃដីការសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ។

**គ.** សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារ។

**ឃ.** ភាពចាំបាច់នៃការរក្សាការពារ។[35]

ចំណុចទាំងបួននេះ ជាមូលដ្ឋានដ៏សំខាន់ដែលត្រូវតែសរសេរបញ្ជាក់នៅក្នុងពាក្យសុំ។ ចំពោះអត្ថន័យដែលមាននៅក្នុងចំណុចនីមួយៗដែលគួរសរសេរបែបណានោះ នឹងបញ្ជាក់យ៉ាងច្បាស់ដូចខាងក្រោមនេះ៖

**ចំណុច ក ៖** នៅក្នុងចំណុច ក គឺទាក់ទងទៅនឹងអត្តសញ្ញាណនៃភាគី និងអ្នកតំណាង ដែលច្បាប់បានកំណត់។ នៅក្នុងពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ អ្នកដាក់ពាក្យសុំត្រូវ សរសេរឲ្យបានច្បាស់លាស់ថា តើនរណាជាអ្នកប្តឹង? ឈ្មោះអ្វី? តើអ្នកនោះមានអាស័យដ្ឋាននៅ ទីណា? ហើយអ្នកតំណាងដែលមានច្បាប់បានកំណត់របស់ជននោះជានរណា?មិនតែប៉ុណ្ណោះ ពាក់ព័ន្ធដល់ប្រសិទ្ធិភាពនៃការទាក់ទងដែលសមស្របទៅនឹងការជឿនលឿនរបស់សង្គមនាពេលបច្ចុប្បន្ន គឺលេខទូរស័ព្ទដែលគួរត្រូវសរសេរភ្ជាប់មកជាមួយ ពីព្រោះនាំឲ្យមានភាពងាយស្រួលក្នុងការជូនដំណឹងផងដែរ។

**ចំណុច ខ៖** សម្រាប់រឿងក្តីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ម្ចាស់បំណុលត្រូវសរសេរ និងកំណត់ឲ្យបានជាក់លាក់នូវអត្តសញ្ញាណ នៃអចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ន និងកំណត់ជាក់លាក់ផងដែរចំពោះសិទ្ធិលើបំណុល ដែលត្រូវបានរក្សាការពារ បញ្ចូលទៅក្នុងពាក្យសុំដើម្បីកំណត់ជាក់លាក់នូវកម្មវត្ថុនៃដីកាសម្រេច។

**ចំណុច គ៖** អ្នកដាក់ពាក្យសុំត្រូវសរសេររៀបរាប់អំពីមូលហេតុ និងចំនួនទឹកប្រាក់នៃសិទ្ធិទាមទារ។ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ត្រង់ចំណុចនេះត្រូវសរសេរអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗផ្សេងទៀតបើមាន ពីព្រោះថាការសរសេរអំពីអង្គហេតុទាំងពីរនេះគឺដើម្បីបង្កើតសិទ្ធិ។ ជាការពិតបើនិយាយពីអង្គហេតុដែល

[35] មាត្រា ៥៤១ កថាខ័ណ្ឌ១ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

ជាមូលហេតុនៃការទាមទារ ដោយផ្អែកទៅតាមមាត្រា ៧៥នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺវាត្រូវសរសេរនៅក្នុងពាក្យ បណ្តឹងឯណោះ ប៉ុន្តែដីការក្សាការពារអាចចេញបានមុន ការដាក់បណ្តឹងអង្គសេចក្តីត្រង់នេះមានន័យថា សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារ ត្រូវសរសេរយ៉ាងណាឲ្យមានអត្ថន័យ និងខ្លឹមសារដូចការដែលសរសេរអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ។ ប្រសិនបើម្ចាស់បំណុលអាចមើលឃើញអំពីអង្គហេតុតវ៉ាដែលអាចនឹងអះអាងដោយកូនបំណុលជាការប្រសើ ម្ចាស់បំណុលត្រូវបញ្ចូលនូវការបដិសេធអំពីអង្គហេតុតវ៉ានោះពីព្រោះវាមាន ប្រយោជន៍សម្រាប់តុលាការក្នុងការចេញដីកាសម្រេច និង សម្រេចអំពីចំនួនប្រាតិភោគ។

**ចំណុច ឃ៖** ភាពចាំបាច់នៃការរក្សាការពារនេះមិនត្រឹមតែជាល័ក្ខខ័ណ្ឌប៉ុណ្ណោះទេ តែម្ចាស់បំណុលក៏ត្រូវលើកយកភាពចាំបាច់នោះស្តែងឲ្យចៅក្រមបានដឹងតាមរយៈការសរសេរពី ភាពចាំបាច់របស់ខ្លួននៅក្នុងពាក្យសុំផងដែរ។

នៅពេលដែលម្ចាស់បំណុលសរសេរអំពី សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារនៅក្នុងពាក្យសុំ ម្ចាស់បំណុលគប្បីសរសេរឲ្យបានច្បាស់លាស់ និងសរសេរនូវភស្តុតាង (ឯកសារអំពីសេចក្តីបញ្ជាក់ដំបូង) ដែលបញ្ជាក់នូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែកលនឹងត្រូវបានការពារ និងភាពចាំបាច់នៃការរក្សាការពារ ពីព្រោះការយោងនេះមានប្រយោជន៍សម្រាប់តុលាការក្នុងការស្វែងរកនូវទំនាក់ទំនងរវាងអង្គហេតុ និង ភស្តុតាង។

បញ្ជីឈ្មោះភាគីទាំងអស់ បញ្ជីអចលនវត្ថុ ម្ចាស់បំណុលអាចភ្ជាប់ជាមួយពាក្យសុំឲ្យចេញដីការក្សាការពារក៏បាន វាផ្តល់ភាពងាយស្រួលដល់ចៅក្រមដែលចេញដីកាសម្រេច ដោយពុំចាំបាច់សរសេរខ្លឹមសារនៅឯកសារដែលភ្ជាប់មកនោះ លើដីកាសម្រេចរក្សាការពារនោះទៀតទេ ដោយហេតុថា ចៅក្រមគ្រាន់តែឆ្លើយតបអនុញ្ញាតចេញដីកាសម្រេចរក្សាការពារនៅលើលិខិតមួយយ៉ាងខ្លីតែមានភ្ជាប់ទៅវិញនូវឯកសារដែលម្ចាស់បំណុលបានភ្ជាប់មក។ បើនិយាយតាមពិតទៅ ប្រភេទនៃបញ្ជីទាំងនេះមិនត្រូវភ្ជាប់ជាមួយពាក្យសុំទេ ប៉ុន្តែវាផ្នែកមួយនៃពាក្យសុំ។ ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំមានច្រើនប្រភេទដូចជា ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង ឯកសារដើម្បីបញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ ឯកសារដើម្បីបញ្ជាក់ពីកម្មវត្ថុនៃការចាត់ចែងរក្សាការពារ និងឯកសារផ្សេងៗទៀត។

ចំពោះចំណុច **គ** និង **ឃ** ខាងលើនេះអ្នកដែលដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង[36]។ សេចក្តីបញ្ជាក់ដំបូង ត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន[37]។

---

[36] មាត្រា ៥៤១ កថាខ័ណ្ឌ៣ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[37] មាត្រា ១៣១ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

- **ឯកសារបញ្ជាក់ដំបូងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានការពារ**

អ្នកដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នម្ចាស់បំណុលចាំបាច់ ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងចំពោះសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានការពារ។ ដើម្បីធ្វើសេចក្តីបញ្ជាក់ចំពោះសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានការពារអ្នកដាក់ពាក្យសុំត្រូវធ្វើការបញ្ជាក់ពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការការទាមទារ។ ដូចដែលបានបញ្ជាក់នៅផ្នែកខាងលើរួចហើយ ភស្តុតាងដែលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងគឺជាឯកសារ។

ដូច្នេះឯកសារដែលបញ្ជាក់ពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនោះគឺមានទៅតាមប្រភេទនៃរឿងក្តីតួយ៉ាងដូចជារឿងក្តីទាក់ទងនឹងកិច្ចសន្យាខ្ចីបរិភោគ គឺលិខិតកិច្ចសន្យាខ្ចីបរិភោគ។ល។ ហេតុអ្វីបានជាត្រូវធ្វើការបញ្ជាក់របៀបនេះ? ឯកសារដែលបញ្ជាក់ពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានការពារនេះមានសារសំខាន់ណាស់ សម្រាប់ឲ្យចៅក្រមអាចពិនិត្យបានភ្លាមៗ និង កំណត់ថាតើម្ចាស់បំណុលមានសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានការពារ ឬអត់។

ផ្ទុយទៅវិញបើម្ចាស់បំណុលខកខានមិនបានដាក់ឯកសារបញ្ជាក់ពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានការពារទេនោះ ចៅក្រមមិនអាចដឹង ឬអាចកំណត់សិទ្ធិរបស់ម្ចាស់បំណុលបានឡើយ។ ការខ្វះឯកសារនេះ គឺវាខុសពីល័ក្ខខណ្ឌចាំបាច់ក្នុងការដាក់ពាក្យសុំដែលវាជាហេតុ មួយនាំឲ្យចៅក្រមត្រូវលើពាក្យសុំនោះចោលបាន ដោយដីកាសម្រេច។

- **ឯកសារបញ្ជាក់ដំបូងអំពីភាពចាំបាច់នៃការរក្សាការពារ**

លើសពីនេះទៅទៀត មានល័ក្ខខ័ណ្ឌមួយទៀតដែលចៅក្រមត្រូវពិចារណាដែលនោះ ថាតើវាមានភាពចាំបាច់ដែល ឬទេ? មានន័យថាចៅក្រមមិនអាចចេញដីកាសម្រេចរក្សាការពារ ដោយសំអាងទៅលើល័ក្ខខ័ណ្ឌសិទ្ធិ ឬទំនាក់ទំនងគតិយុត្តតែមួយនោះទេ គឺចាំបាច់ត្រូវមានល័ក្ខខ័ណ្ឌនៃភាពចាំបាច់នៃការរក្សាការពារផងដែរ ទើបចៅក្រមអាចចេញដីកាសម្រេចបាន។ ភាពចាំបាច់នៃការរក្សាការពារ គឺមានការប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់កូនបំណុល។ ភាពចាំបាច់រក្សាការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ គឺក្នុងការបារម្ភថា ការអនុវត្តដោយ បង្ខំនឹងមិនអាចធ្វើទៅបាន ឬមានភាពលំបាក់យ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ។ ដូច្នេះម្ចាស់ បំណុលដាក់ពាក្យសុំឲ្យចេញដីការឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ចាំបាច់ត្រូវធ្វើសេចក្តី បញ្ជាក់ដំបូងពីភាពចាំបាច់ គឺត្រូវផ្តល់ឯកសារដែលបញ្ជាក់ពីភាពចាំបាច់នៃការរក្សាការពារ ដោយ សរសេរពីមូលហេតុ និងស្ថានភាពផ្សេងៗដែលកូនបំណុលរបស់ខ្លួនមានដើម្បីបង្ហាញពីភាពចាំបាច់របស់ខ្លួនដើម្បីឲ្យចៅក្រមពិចារណាឈានទៅចេញដីការសម្រេច។ វាក៏ជាការលំបាកមួយ ដែលសម្រាប់ម្ចាស់បំណុល ក្នុងការស្វែងរកភស្តុតាងផ្សេងៗដែលបញ្ជាក់ថា កូនបំណុលរបស់ខ្លួន ជួបនឹងបញ្ហា

លំបាក ប៉ុន្តែនេះគឺជាកាតព្វកិច្ចរបស់ម្ចាស់បំណុលដែលចាំបាច់ត្រូវធ្វើសេចក្តីបញ្ជាកដំបូង។ ជាទូទៅ ឯកសារបញ្ជាក់ដំបូងពីភាពចាំបាច់នេះគ្រាន់តែជារបាយការណ៍ដែលរៀបចំឡើង ដោយម្ចាស់បំណុលគឺគ្រប់គ្រាន់ហើយ។ មូលហេតុ នឹងស្ថានភាពផ្សេងៗរបស់កូនបំណុលដែលម្ចាស់បំណុលបានលើកឡើងក្នុងរបាយការណ៍នេះជាភស្តុតាងដែលអាចបញ្ជាក់ ពីភាពចាំបាច់សម្រាប់ការរឹបអូសជាបណ្តោះអាសន្ន (បើមិនដូច្នោះទេម្ចាស់បំណុលមិនអាច ឬមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដីកាសម្រេចនៅកាលបរិច្ឆេទក្រោយបើម្ចាស់បំណុលឈ្នះក្តី)។

ឯកសារមួយចំនួនទៀតដែលត្រូវភ្ជាប់មកជាមួយផងដែលគឺៈ

- **ឯកសារដើម្បីបញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ**

តាមរយៈក្រមនីតិវិធីរដ្ឋប្បវេណី ក៏បានអនុញ្ញាតឲ្យមានអ្នកតំណាងដោយអាណត្តិ នៅក្នុងរឿងក្តីរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុ ក៏ដូចជានៅក្នុងនីតិវិធីចាត់ចែងរក្សាការពារផងដែរ។ ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ក៏ដូចនីតិវិធីសម្រាប់ការជំនុំជម្រះដែរ គឺអ្នកដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ មានសិទ្ធិជ្រើសតាំងអ្នកតំណាងដោយអាណត្តិ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួនដោយធ្វើសកម្មភាពបណ្តឹងជំនួសខ្លួន។ បើមានអ្នកតំណាងដោយអាណត្តិ អ្នកដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវដាក់ឯកសារបញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិនេះ ភ្ជាប់មកជាមួយពាក្យសុំ។ បើគ្មានលិខិតបញ្ជាក់ពីសិទ្ធិតំណាងទេ នោះតុលាការមិនអាចលើកចោលពាក្យសុំបានឡើយ គឺគ្រាន់តែឲ្យភាគីកែតម្រូវដោយណែនាំឲ្យអ្នកពាក្យសុំដាក់លិខិតនោះ។ ផ្ទុយទៅវិញបើភាគីមិនបានដាក់ទៀត តុលាការមិនអាចទទួលស្គាល់អ្នកតំណាងដោយអាណត្តិនោះទេ គឺភាគីត្រូវតែមកធ្វើសកម្មភាពនោះក្នុងកិច្ចនីតិវិធីនេះដោយខ្លួនឯង។ ឯកសារដែលបញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអណត្តិដែលជា ល័ក្ខខ័ណ្ឌចាំបាច់ត្រូវតែមានបើភាគីមានអ្នកតំណាងដោយអណត្តិ ព្រោះដើម្បីថៅក្រមកំណត់ពី ទំហំនៃសិទ្ធិរបស់អ្នកតំណាងដោយអណត្តិដើម្បីធានាស្ថេរភាពនៃកិច្ចនីតិវិធី។

- **ឯកសារបញ្ជាក់ពីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន**

កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវមានឯកសារដើម្បីបញ្ជាក់ និងភ្ជាប់មកជាមួយពាក្យសុំ ពីព្រោះថា តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដោយកំណត់ពីកម្មវត្ថុជាក់លាក់នៃការឹបអូសជាបណ្តោះអាសន្ន លើកលែងតែចលនវត្ថុ។ ឯកសារដើម្បីបញ្ជាក់ពីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺអ្នកដាក់ពាក្យសុំត្រូវ ធ្វើការបញ្ជាក់យ៉ាងណាដើម្បីឲ្យតុលាការជឿថា កម្មវត្ថុដែលសុំឲ្យតុលាការការធ្វើការរឹបអូសជាបណ្តោះអាសន្ននោះ ពិតជាទ្រព្យសម្បត្តិរបស់កូនបំណុលពិតមែន។ តាមធម្មតា ឯកសារជាលិខិត

បញ្ជាក់ពីកម្មសិទ្ធិ របស់កូនបំណុលចំពោះអចលនវត្ថុមានបញ្ជាក់ពីព័ត៌មានមួយចំនួនដូចជា ការបញ្ជាក់ថាដី មានទំហំប៉ុន្មាន ឬ ដី និងផ្ទះមានទំហំប៉ុន្មាន ដែលជាកម្មសិទ្ធិរបស់កូនបំណុលជាដើម។ ការបញ្ជាក់ពីកម្មសិទ្ធិនៅលើ អចលនវត្ថុ វាគឺជាភារកិច្ចរបស់មន្ត្រីសុរិយោដី ផ្ទុយទៅវិញបើមិនអាចទទួលបានការបញ្ជាក់ពីមន្ត្រី មានសមត្ថកិច្ចទេ នោះម្ចាស់បំណុលអាចរកឯកសារតាមគ្រប់មធ្យោបាយសុច្ចរិតផ្សេងៗ ដែលតុលាការអាចទទួលយកបាន ដូចជាឯកសារមានការបញ្ជាក់ពីមេភូមិ ឬចៅសង្កាត់ជាដើម។

### ២.៣.២ ពន្ធដាក់ពាក្យសុំ និងប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

- **ពន្ធដាក់ពាក្យសុំ**

ក្នុងករណីដែលដាក់ពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀលទៅតុលាការ [38]។ ប្រសិនបើពន្ធដាក់ពាក្យសុំខាងលើមិនត្រូវបានបង់ទេនោះ តុលាការត្រូវបង្គាប់ឲ្យអ្នកដាក់ពាក្យសុំបង់ពន្ធដាក់ពាក្យសុំក្នុងអំឡុងពេលសមរម្យ[39]។ ក្នុងករណីដែលអ្នកដាក់ពាក្យសុំនៅតែមិនបង់ពន្ធតាមបង្គាប់ខាងលើទេ តុលាការអាចលើកពាក្យសុំគាត់ចោលដោយដីកាសម្រេច។

- **ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ**

ប្រាក់ប្រដាប់តុលាការក្រៅពីពន្ធ គឺជាប្រាក់ប្រដាប់ក្ដីតុលាការដែលភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្ដី ត្រូវបង់មុនសម្រាប់ការចំណាយរបស់តុលាការ ដែលធ្វើសកម្មភាពតាមនីតិវិធីនៅក្នុងបណ្ដឹងរដ្ឋប្បវេណី ដូចជាចំនួនប្រាក់ចាំបាច់សម្រាប់ការបញ្ជូនឯកសារជាដើម[40]។

ឧទាហរណ៍៖ សោហ៊ុយសម្រាប់ការបញ្ជូនដីកាសម្រេចទៅកូនបំណុលជាដើម។

## ២.៤. ការពិនិត្យលើពាក្យសុំដីការឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

នៅពេលមានពាក្យសុំដីកាសម្រេចរក្សាការពារ បានបញ្ជូនមកដល់ចៅក្រមដែលទទួលបន្ទុក ចាត់ការលើពាក្យសុំដីកាសម្រេចនោះ[41]។ ចៅក្រមត្រូវធ្វើការពិនិត្យពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដូចខាងក្រោម៖

**ក/** ឈ្មោះ ឬ នាមករណ៍ និងអាស័យដ្ឋានរបស់ភាគី ហើយនឹងឈ្មោះ អាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

**ខ/** ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ។

[38] មាត្រា ៥៣៧ កថាខ័ណ្ឌ១ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[39] មាត្រា ៥៣៨ និង មាត្រា ៧៨ កថាខ័ណ្ឌ ១ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[40] ឧបសម្ព័ន្ធ

[41] ចៅក្រមដែលទទួលបន្ទុកនោះជាចៅក្រមដែលកំណត់តាមដីការសម្រេចប្រចាំឆ្នាំរបស់ប្រធានតុលាការ

**គ**/ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ។

**ឃ**/ ភាពចាំបាច់នៃការរក្សាការពារ។

ក្នុងករណីដែលពាក្យសុំផ្ទុយនឹង ចំណុចខាងលើនេះ តុលាការត្រូវបង្គាប់ឲ្យកែតម្រូវចំណុចខ្វះខាត ចំពោះពាក្យសុំនោះក្នុងអំឡុងពេលសមរម្យ។ ប្រសិនបើម្ចាស់បំណុលមិនបានកែតម្រូវចំណុចខ្វះខាតទេនោះ តុលាការត្រូវលើកពាក្យសុំនោះចោលដោយដីកាសម្រេច[42]។ ការពិនិត្យនេះចៅក្រមក៏ត្រូវពិនិត្យអំពីសមត្ថកិច្ចរបស់ខ្លួនថា តើមានសមត្ថកិច្ច ឬគ្មាន។ បើតុលាការរកឃើញថាវាមានកង្វះសមត្ថកិច្ច ចំពោះរឿងក្តីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះ គេត្រូវផ្ទេររឿងក្តីនោះទៅតុលាការមានសមត្ថកិច្ចដោយយោងតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់តុលាការ។ ក្រៅពីការពិនិត្យមើលពាក្យសុំ និងសមត្ថកិច្ចតុលាការមានភាពត្រឹមត្រូវ ហើយតុលាការត្រូវពិនិត្យមើលថាតើពន្ធដាក់ពាក្យសុំបានបង់ហើយ ឬនៅ?

**២.៤.១ កម្មវត្ថុនៃការពិនិត្យ**

មុននឹងចៅក្រមសម្រេចចេញដីកាសម្រេច ចាំបាច់ត្រូវពិនិត្យភស្តុតាងឲ្យបានច្បាស់សិន ថាតើពាក្យសុំនោះមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីឲ្យតុលាការសម្រេចចេញដីកាសម្រេចឬទេ? កម្មវត្ថុនៃការពិនិត្យភស្តុតាងចំនួន ពីរដែលតុលាការត្រូវពិនិត្យ គឺសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលនឹងត្រូវបានការពារ និងភាពចាំបាច់នៃការរក្សាការពារ។ នៅផ្នែកបន្ទាប់នេះជាការបកស្រាយ នូវនីតិវិធីនៃការពនិត្យពាក្យសុំទាំងមូល។

**២.៤.២ នីតិវិធីនៃការពិនិត្យ**

- **ការពិនិត្យភស្តុតាងជាឯកសារ**

សម្រាប់ការចេញដីការឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលត្រូវបង្ហាញឯកសារសេចក្តីបញ្ជាក់ដំបូងដើម្បីឲ្យតុលាការអាចសម្រេចថាតើមានសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានការពារ ឬអត់ ឬថាតើមានភាពចាំបាច់ដើម្បីចេញដីកាសម្រេចដែរ ឬទេ? សេចក្តីបញ្ជាក់ដំបូងត្រូវភ្ជាប់ជាមួយពាក្យសុំដើម្បីឲ្យតុលាការពិចារណា ដូច្នេះជាដំបូង តុលាការត្រូវពិនិត្យលើឯកសារបញ្ជាក់ដំបូងដូចជា៖

✓ឯកសារបញ្ជាក់ដំបូង ៖ ឯកសារចម្លងនៃកិច្ចសន្យា ប័ណ្ណកម្មសិទ្ធិលើទ្រព្យសម្បត្តិ បង្កាន់ដៃកំណត់ហេតុ ឬ របាយការណ៍ជាដើម ដែលធ្វើឡើងដោយម្ចាស់បំណុល ឬ ឯកសារបញ្ជាក់ ពីទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានការពារ ឬឯកសារផ្សេងៗទៀតដែលចាំបាច់ សម្រាប់ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។

[42] មាត្រា ៧៨ កថាខ័ណ្ឌ ២ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

- **ការសាកសួរម្ចាស់បំណុល**

តុលាការអាចហៅម្ចាស់បំណុលមកសួរយកព័ត៌មាន ដែលទាក់ទងនឹងចំណុចខាងលើបាន ដោយឲ្យម្ចាស់បំណុលបញ្ជាក់ឲ្យបានច្បាស់លាស់នូវគោលបំណង ដែលចង់ឲ្យតុលាការរឹបអូសជាបណ្តោះអាសន្ន។ ក្នុងការសាកសួរម្ចាស់បំណុល តុលាការអាចឲ្យម្ចាស់បំណុលឆ្លើយជាលាយលក្ខណ៍អក្សរ និងអាចឲ្យម្ចាស់បំណុលដាក់ឯកសារបន្ថែម។ មិនតែប៉ុណ្ណោះតុលាការក៏អាចអញ្ជើញម្ចាស់បំណុល មកតុលាការ និងសួរម្ចាស់បំណុលដោយផ្ទាល់បានផងដែរ។ នីតិវិធីនៃការសាកសួរម្ចាស់បំណុល គឺមិនធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ទេ ដូច្នេះនីតិវិធីសួរម្ចាស់បំណុល គឺមិនត្រូវបានធ្វើឡើងជាសាធារណៈឡើយ។ ការសួរម្ចាស់បំណុល គឺជាវិធីងាយៗសម្រាប់តុលាការក្នុងការធ្វើការបញ្ជាក់នូវខ្លឹមសារនៃពាក្យសុំ ឬភស្តុតាងជាឯកសារ។ ការសាកសួរម្ចាស់បំណុលនេះទៀតសោត មិនមែនដាច់ខាតត្រូវតែធ្វើនោះទេ។

នៅក្នុងករណីមួយចំនួន ចៅក្រមក៏អាចធ្វើកិច្ចនីតិវិធីដូចខាងក្រោមនេះបានផងដែរ ប៉ុន្តែគេកម្រនឹងធ្វើណាស់ដោយមូលហេតុវាផ្ទុយពីចរឹកលក្ខណៈនៃការចាត់ចែងរក្សាការពារ។ កិច្ចនីតិវិធីទាំងនោះមាន៖

- **ការសាកសួរកូនបំណុល**

តុលាការអាចសាកសួរកូនបំណុលបាន ហើយនីតិវិធីនៃការសាកសួរកូនបំណុល គឺត្រូវបានធ្វើដូចការសាកសួរម្ចាស់បំណុលដែរ។ ប៉ុន្តែចរឹកលក្ខណៈនៃការចាត់ចែងរក្សាការពារ ក៏ដូចជាការរឹបអូសជាបណ្តោះអាសន្នដែរ គឺវាមានលក្ខណៈបណ្តោះអាសន្ន បន្ទាន់បង្ខំ បន្ទាប់បន្សំ និងសម្ងាត់ ហេតុដូច្នេះហើយគេមិនសួរជាសួរកូនបំណុលទេ ព្រោះបារម្ភខ្លាចកូនបំណុលបង្កការលំបាកដល់ការអនុវត្ត ឬលួចបញ្ចៀសទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ន។ វិធីនេះ(ការសាកសួរកូនបំណុល) អាចជួយការពារផលប្រយោជន៍របស់កូនបំណុលដែរ ពេលតុលាការសួរព័ត៌មានមួយចំនួននោះ។ ឧទាហរណ៍៖ក្នុងករណីដែលរឿងក្តីមានលក្ខណៈស្មុគ្រស្មាញ ឬដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមើលទៅមានឥទ្ធិពលធំធេងចំពោះកូនបំណុល ឬមានលទ្ធិភាពជឿជាក់ថាការតវ៉ានឹងអាចត្រូវបានធ្វើឡើងដោយកូនបំណុល។ តុលាការអាចសួរកូនបំណុលដើម្បីផ្តល់ឱកាសឲ្យកូនបំណុលធ្វើការអះអាង ឬដាក់ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង។

- **ការទាញហេតុផលដោយផ្ទាល់មាត់**

ក្នុងរឿងរឹបអូសជាបណ្តោះអាសន្ន ភាគច្រើនតុលាការមិនសូវជ្រើសរើសយកការទាញហេតុផលដោយផ្ទាល់មាត់ទេ ពីព្រោះការទាញហេតុផលដោយផ្ទាល់មាត់មិនមែនជាល័ក្ខខ័ណ្ឌរបស់ច្បាប់ឡើយ។ ប៉ុន្តែក្នុងករណីដែលរឿងក្តីនោះមានលក្ខណៈស្មុគ្រស្មាញដែលតុលាការគិតថាការសួរភាគី និងការពិនិត្យភស្តុតាងជាឯកសារមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ដើម្បីចេញដីកាសម្រេច តុលាការអាចធ្វើការទាញហេតុផលផ្ទាល់មាត់បាន។

## ២.៥.ការចេញដីកាសម្រេចលើពាក្យសុំ

បន្ទាប់ចៅក្រមបានធ្វើកិច្ចនីតិវិធី និងពិនិត្យមើលលើគ្រប់ល័ក្ខខ័ណ្ឌទាំងអស់ដូចបានរៀបរាប់ខាងលើរួចមក ចៅក្រមនឹងត្រូវធ្វើការសម្រេចសេចក្តីចំពោះពាក្យសុំ ដែលម្ចាស់បំណុលបានដាក់។ ចៅក្រមត្រូវធ្វើយ៉ាងឲ្យបានឆាប់បំផុត និងត្រឹមត្រូវតាមនីតិវិធីច្បាប់ដើម្បីឆ្លើយតបទៅនឹងភាពបន្ទាន់បង្ខំ ដែលជាចរិកលក្ខណៈរបស់ការរឹបអូសជាបណ្តោះអាសន្ន។ បន្ទាប់ពីចៅក្រមធ្វើការវិនិច្ឆ័យ ចៅក្រមអាចសម្រេចសេចក្តី ដោយចេញដីកាសម្រេចការរឹបអូសជាបណ្តោះអាសន្នតាមពាក្យរបស់ម្ចាស់បំណុល ឬដីកាសម្រេចលើកចោលពាក្យសុំ។

### ២.៥.១ ដីកាសម្រេចបង្គាប់ឲ្យរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីយើង ពុំមានមាត្រាណាមួយចែងថាដីកាសម្រេចត្រូវធ្វើជាលាយលក្ខណ៍អក្សរនោះទេ ប៉ុន្តែយើងអាចនិយាយ បានថា ដីកាសម្រេចត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយយោងទៅលើមូលហេតុដូចខាងក្រោម៖

តុលាការត្រូវបញ្ជូនដីកាសម្រេចទៅភាគី។ បើដីកាសម្រេចមិនបានធ្វើឡើងជាលាយលក្ខណ៍អក្សរទេ នោះការបញ្ជូនមិនអាចធ្វើទៅកើតទេ។ ហើយការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ធ្វើទៅបានដោយផ្អែកលើ មូលដ្ឋាននៃឯកសារចម្លងយថាភូតនៃដីកាសម្រេច។ បើដីកាសម្រេចនោះមិនធ្វើជាលាយលក្ខណ៍ អក្សរទេនោះ ឯកសារចម្លងយថាភូតនៃដីកាសម្រេចមិនអាចធ្វើកើតឡើយ។ ដូច្នេះដីកាសម្រេចត្រូវ ធ្វើជាលាយលក្ខណ៍អក្សរ[43]។

### ២.៥.២ ទម្រង់ដីកាសម្រេចបង្គាប់ឲ្យរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

១. **ចំណុចចាំបាច់ដើម្បីបញ្ជាក់ពីរឿងក្តី៖** ក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវចាំបាច់មានបញ្ជាក់ពីចំណុចសំខាន់ៗ ដើម្បីបញ្ជាក់រឿងក្តីរួមមាន៖ សញ្ញាណនៃភាគី សញ្ញាណនៃសិទ្ធិលើបំណុលដែលទាមទារ និងលេខសំណុំរឿងជាដើម។ដោយសារតែដីកាសម្រេចត្រូវចេញដោយផ្អែកលើពាក្យសុំ នោះដីកាសម្រេចត្រូវតែជាដីកា សម្រេច ដែលទាក់ទងនឹងរឿងក្តី

[43] ទំព័រ ៣៩ សៀវភៅស្តីពី នីតិវិធីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ បោះពុម្ពលើកទី ១ (ខែមិនា ឆ្នាំ ២០០៩)

ជាក់លាក់ណាមួយ ដែលពាក្យសុំត្រូវបានដាក់។ ម្យ៉ាងវិញទៀត យើងមិនអាចបញ្ជាក់ពីអត្តសញ្ញាណនៃរឿងក្តីបានឡើយ បើដីកាសម្រេចនោះមិនសរសេរអំពីចំណុចសំខាន់ដើម្បីបញ្ជាក់អំពីរឿងក្តី។ ចំណុចមួយក្នុងចំណោមចំណុចសំខាន់ៗ ដើម្បីបញ្ជាក់ពីរឿងក្តី នោះគឺព័ត៌មានដែលទាក់ទងនឹងភាគី ដូចជា ឈ្មោះ និងអាស័យដ្ឋានរបស់ភាគី និងឈ្មោះ និងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់កំណត់។ ហើយនិងចំណុចសំខាន់ ផ្សេងទៀតដូចជា៖

ព័ត៌មានទាក់ទងនឹងសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ និងព័ត៌មានទាក់ទងនឹងកម្មវត្ថុនៃ ការរឹបអូសជាបណ្តោះអាសន្ន ក៏អាចជាចំណុចមួយដែលចាំបាច់សម្រាប់បញ្ជាក់រឿងក្តីផងដែរ។ ចំពោះខ្លឹមសារសរសេរសម្រាប់ការអនុវត្តជាក់ស្តែងមានជម្រើស ពីរយ៉ាងគឺ៖

ទី១.ថៅក្រមអាចសរសេរនូវអត្ថន័យទាំងមូល នៃភាពចាំបាច់ដើម្បីបញ្ជាក់ពីរឿងក្តីនៅក្នុងដីកាសម្រេចតែម្តងក៏បាន ប៉ុន្តែវាមានផលវិបាកមួយកើតឡើង គឺថាការធ្វើបែបនេះវានាំឲ្យដីកាសម្រេចនោះវែង និងខាត់បងពេលវេលាច្រើន។

ទី២.ថៅក្រមអាចសរសេរនូវអត្ថន័យក្នុងទម្រង់សង្ខេប ដោយគ្រាន់តែបញ្ជាក់ថាមានក្នុងឧបសម្ព័ន្ធជាការស្រេច។ ម្យ៉ាងវិញទៀត ថៅក្រមអាចប្រើបញ្ជីដែលពិពណ៌នាភាគី បញ្ជីសិទ្ធិលើបំណុល និងបញ្ជីទ្រព្យសម្បត្តិដែលបានភ្ជាប់មកជាមួយពាក្យសុំ និងបញ្ជាក់ពីរឿងក្តីដោយភ្ជាប់ជាមួយនឹងបញ្ជីទាំងនោះទៅនឹងដីកាសម្រេចតែម្តង។

**២.ការសំអាងហេតុ៖** ថៅក្រមត្រូវសរសេរពីសំអាងហេតុ ដោយសង្ខេបនៅក្នុងដីកាសម្រេចអំពីមូលហេតុ ដែលជាហេតុនាំឲ្យថៅក្រមសម្រេច ចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។

**៣.សេចក្តីសម្រេច៖** ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុ ត្រូវសរសេរបញ្ចូលនូវសេចក្តីសម្រេច ការសម្រេចបញ្ចប់នវការវិនិច្ឆ័យលើពាក្យសុំ ដែលបានដាក់ដោយម្ចាស់បំណុល។ នៅត្រង់នេះគេតែងតែប្រើពាក្យថា " ហេតុដូច្នេះសម្រេច " ។ ហើយនៅត្រង់ចំណុចនៃសេចក្តីសម្រេចតុលាការត្រូវ៖

- **កំណត់ជាក់លាក់ នូវកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុ**

ក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុ តុលាការត្រូវកំណត់ឲ្យបានច្បាស់ពីអត្តសញ្ញាណ និងទីតាំងដែលកម្មវត្ថុនោះតាំងនៅ បើមិនដូច្នោះទេ កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ស្ថិតនៅក្នុងភាពមិនច្បាស់លាស់ នោះហើយដែលជាហេតុនាំឲ្យការអនុវត្តមានការលំបាក់ នឹងជួបនឹងបញ្ហាជាពុំខាន។ ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ គឺទាមទារឲ្យមានគ្រប់គ្រាន់នូវព័ត៌មាននៃអចលនវត្ថុនោះ ហើយព័ត៌មានដែលតុលាការអាចទទួលបាន គឺតាមរយៈឯកសារបញ្ជាក់ដំបូង ដែលដាក់ដោយម្ចាស់បំណុល ដែលមានភ្ជាប់មកជា មួយពាក្យសុំ។

ថៅក្រមអាចប្រើប្រាស់បញ្ជីពិពណ៌នា អំពីអចលនវត្ថុដែលម្ចាស់ បំណុលបានដាក់ជាមួយពាក្យសុំ ដើម្បីជំនួសពីការបរិយាយពីអត្តសញ្ញាណនៃអចលនវត្ថុដោយប្រើពាក្យ " **រឹបអូសជាបណ្ដោះអាសន្ន នូវអចលនវត្ថុរបស់កូន បំណុល ឈ្មោះ (.....) ដូចមានក្នុងបញ្ជីអំពីអចលវត្ថុដែលបានភ្ជាប់មកជាមួយ។"** សូមបញ្ជាក់ថា ពេលអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គឺត្រូវ បានធ្វើឡើងតាមរយៈការចុះបញ្ជីដើម្បីបញ្ជាក់ថា អចលនវត្ថុនោះត្រូវបានធ្វើការរឹបអូសជាបណ្ដោះអាសន្នសិន ដូច្នេះដើម្បីឈានចូលដល់ការចុះបញ្ជីអំពី ការរឹបអូសជាបណ្ដោះអាសន្ននូវអចលនវត្ថុនោះបាន គឺតម្រូវឲ្យមានការកំណត់ឲ្យបានច្បាស់លាស់ នូវព័ត៌មានជុំវិញអចលនវត្ថុនោះជាមុនសិន។

- **ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន៖** ក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះ អាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើ ដើម្បីទទួល បាននូវការលុបការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន[44]។

- **ប្រាតិភោគ៖** ប្រាតិភោគ ត្រូវបានដាក់សម្រាប់គោលបំណងដើម្បីធានា សំណងនៃការខូចខាតដែលកើតឡើងចំពោះកូនបំណុល ដោយសារតែកំហុសរបស់ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។ ដូច្នេះ ថៅក្រមគប្បីធ្វើការបញ្ចូលព័ត៌មាន អំពីប្រាតិភោគនៅក្នុងដីកាសម្រេចដើម្បីជាការប្រាប់ដល់កូនបំណុល អំពីចំនួននៃប្រាតិភោគដែលត្រូវបានដាក់។បើតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដែលភ្ជាប់ជាមួយនូវការបង្គាប់ ឲ្យដាក់ប្រាតិភោគ ហើយការដាក់ប្រាតិភោគគឺជាល័ក្ខខ័ណ្ឌមួយដើម្បីអនុវត្តដីកា សម្រេចនោះ ចំណុចនេះត្រូវសរសេរនៅក្នុងចំណុចទី ៣។ ប៉ុន្តែប្រសិនបើតុលាការបង្គាប់ឲ្យដាក់ប្រាតិភោគមុនពេលចេញ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ការដាក់ប្រាតិភោគជាល័ក្ខខ័ណ្ឌមួយដើម្បីចេញដីកាសម្រេច នោះម្ចាស់បំណុលត្រូវធ្វើការផ្ញើប្រាតិភោគទៅតុលាការ ដើម្បីទទួលបានដីកាសម្រេច បន្ទាប់ពីដាក់ប្រាតិភោគរួច ហើយខាងតុលាការគេនឹងចេញ របាយការណ៍ និងឯកសារអំពីការផ្ញើនោះ រួចហើយម្ចាស់បំណុលត្រូវយកឯកសារ និងរបាយការណ៍ នោះប្រគល់ជូនតុលាការ ក្នុងករណីនេះ នៅក្នុងដីកាសម្រេចគេសរសេរវាថា " បានឃើញរបាយការណ៍ស្តីពីប្រាក់តំកល់ (ប្រាតិភោគ) ចំនួន .....។" នៅក្នុងចំណុចទី ១ មិនមែនសរសេរនៅក្នុងចំណុចទី ៣ឡើយ។

- **បន្ទុកប្រាក់ប្រដាប់ក្ដី៖**

– ពេលដែលការសម្រេចសេចក្ដីលើកចោលពាក្យសុំត្រូវ បានធ្វើឡើង សេចក្ដីសម្រេច នោះត្រូវកំណត់ពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី (បណ្ដឹងជំទាស់ ចំពោះសេចក្ដីសម្រេចនេះអាចត្រូវបានប្ដឹងទៅឧទ្ធរណ៍)។

[44] មាត្រា ៥៤៧ កថាខ័ណ្ឌ១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

– ពេលដែលដីកាសម្រេចទទួលស្គាល់ពាក្យសុំ ដីការឹបអូសជាបណ្ដោះអាសន្នត្រូវបានធ្វើឡើងក្នុងទស្សនៈពីរះ

<u>ទស្សនៈទី១</u> គឺថាដីកាសម្រេចមិនត្រូវកំណត់ពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី (បណ្ដឹងតវ៉ាចំពោះដីកាសម្រេច) ដីកាសម្រេចនោះអាចត្រូវបានដាក់ទៅតុលាការដែលចេញសម្រេចនោះ[45]។ ដូច្នេះដីកាសម្រេចនេះមិនឆ្លើយតបទៅនឹង "ដីកាសម្រេចសេចក្ដីដែលបញ្ចប់រឿងក្ដីនៅតុលាការ"[46] ឡើយ។

<u>ទស្សនៈទី២គឺ</u> ដីកាសម្រេចដែលទទួលស្គាល់ពាក្យសុំដីកាសម្រេចត្រូវកំណត់ពីប្រាក់ប្រដាប់ក្ដី។ ដោយហេតុថា ជានិច្ចជាកាលបណ្ដឹងជំទាស់ មិនត្រូវបានគេធ្វើឡើង ចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នឡើយ។ នៅក្នុងករណីនេះបន្ទុកនៃប្រាក់ប្រដាប់ក្ដីនឹងមិនត្រូវសម្រេចឡើយ។ ដើម្បីចៀសវៀងនូវស្ថានភាពបែបនេះ គេបកស្រាយថា ដីកាសម្រេចដែលទទួលស្គាល់ពាក្យសុំដីការឹបអូសជាបណ្ដោះអាសន្ន ត្រូវកំណត់អំពីបន្ទុកនៃប្រាកប្រដាប់ក្ដី។

### ២.៥.៣ ប្រាតិភោគ

#### ២.៥.៣.១ គោលបំណងនៃការដាក់ប្រាតិភោគ

ចំណុចពិសេស នៃការចេញដីការឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គឺតុលាការអាចចេញដីកាសម្រេចបាន ដោយពុំចាំបាច់សួរកូនបំណុលឡើយ ដោយគ្រាន់តែឆ្លងកាត់ការធ្វើសេចក្ដីបញ្ជាក់ដំបូងជាការស្រេច។ ក្នុងករណីខ្លះ ការដែលចេញដីកាសម្រេច វាបណ្ដាលឲ្យប៉ះពាល់ដល់ប្រយោជន៍របស់កូនបំណុលខ្លាំង ដែលអាចបណ្ដាលឲ្យកូនបំណុលខូចខាតច្រើន ដើម្បីជាការឆ្លើយតបទៅនឹងការខូចខាតរបស់កូនបំណុល ដែលអាចកើតមានឡើងជាយថាហេតុនោះទើបតុលាការតម្រូវឲ្យម្ចាស់បំណុលដាក់ប្រាតិភោគ។ ការដាក់ប្រាតិភោគ ដើម្បីធានាសងការខូចខាត និងជម្ងឺចិត្ត។

#### ២.៥.៣.២ ចំនួននៃប្រាតិភោគ

នៅពេលដែលតុលាការបង្គាប់ឲ្យម្ចាស់បំណុលដាក់ប្រាតិភោគ តុលាការត្រូវពិចារណាឲ្យបានល្អិតល្អន់ពីផលប៉ះពាល់ ដែលអាចនាំឲ្យមានការខូចខាតកើតឡើងជាយថាហេតុ ដោយសារតែការចេញដីការសម្រេច។ ដូច្នេះ តុលាការត្រូវសាកល្បងធ្វើការវាយតម្លៃ អំពីទំហំនៃការខូចខាតដែលនឹងអាចកើតមានឡើងចំពោះកូនបំណុល ដោយមានការប្រុងប្រយ័ត្នបំផុត ។ ក្រោយពីតុលាការ ពិចារណា លើការខូចខាតនាពេលខាងមុខតុលាការក៏ត្រូវតែពិចារណាទៅដល់ការធ្វើសេចក្ដីបញ្ជាក់ដំបូង។ មានន័យថាបើការធ្វើសេចក្ដីបញ្ជាក់ដំបូងនោះ មានលក្ខណៈរឹងមាំនោះចំនួន

[45] មាត្រា ៥៥០ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[46] មាត្រា ៦៥ កថាខ័ណ្ឌ១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

នៃការដាក់ប្រាតិភោគ គឺវាទាប ឬតិចទៅតាមនឹង។ ផ្ទុយទៅវិញ បើការធ្វើសេចក្តីបញ្ជាក់ដំបូងនោះពុំមានលក្ខណៈរឹងមាំ នោះតម្រូវការដាក់ប្រាតិភោគត្រូវមានកម្រិតខ្ពស់ ឬច្រើន។ ចំណុចចុងក្រោយ តុលាការត្រូវពិចារណាពីសណ្ឋាននៃអចលនវត្ថុ ដែលជាកម្មវត្ថុនៃការចេញដីកាសម្រេច ទើបវាមានលក្ខណៈងាយស្រួល ដល់តុលាការក្នុងការកំណត់នូវចំនួនប្រាតិភោគ ដែលតម្រូវឲ្យម្ចាស់បំណុលដាក់។

**២.៥.៣.៣ អំឡុងពេលនៃការដាក់ប្រាតិភោគ**

ដើម្បីដាក់ប្រាតិភោគ ភាគីត្រូវធ្វើតាមរយៈវិធីផ្ញើរប្រាក់ ឬឧបករណ៍ដែលអាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការ ដែលបង្គាប់ឲ្យដាក់ប្រាតិភោគ ឬតុលាការអនុវត្ត[47]។

មានសំនួរបានលើកឡើងថា៖ តើការដាក់ប្រាតិភោគត្រូវធ្វើឡើងនៅពេលណា? តុលាការអាចបង្គាប់ឲ្យដាក់ប្រាតិភោគ មុនពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះ អចលនវត្ថុ នោះការដាក់ប្រាតិភោគ ជាល័ក្ខខ័ណ្ឌមួយដើម្បីចេញដីកាសម្រេច។ ក្នុងករណីនេះ ម្ចាស់បំណុលត្រូវដាក់ប្រាតិភោគមុនចេញដីកាសម្រេច បើមិនដូច្នេះទេ តុលាការនឹងមិនចេញដីកាសម្រេច រហូតដល់ប្រាតិភោគត្រូវបានដាក់។ ក្នុងករណីនេះផងដែរ តុលាការនឹងចេញដីកាសម្រេច អំពីប្រាតិភោគ ហើយបើម្ចាស់បំណុលដាក់ប្រាតិភោគមុនចេញដីកាសម្រេចនោះ ម្ចាស់បំណុលនឹងត្រូវដាក់នូវសេចក្តីថ្លែងការណ៍ ឬរបាយការណ៍អំពីការដាក់ ប្រាតិភោគ ទៅកាន់តុលាការដើម្បីបង្ហាញថាខ្លួនបានដាក់ប្រាតិភោគរួចហើយ។

ម្យ៉ាងវិញទៀត តុលាការក៏អាចចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដែលភ្ជាប់ជាមួយនូវការបង្គាប់ឲ្យដាក់ប្រាតិភោគ នោះការដាក់ប្រាតិភោគ គឺជាល័ក្ខខ័ណ្ឌមួយដើម្បីអនុវត្តដីកាសម្រេចនោះ។ ដូច្នេះម្ចាស់បំណុលត្រូវដាក់ប្រាតិភោគ មុនពេលសុំអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុ មានន័យថា ម្ចាស់បំណុលមិនអាចមានលទ្ធភាពអនុវត្តដីកាសម្រេចនោះបានឡើយ រហូតដល់ពេលដែលខ្លួនបានដាក់ប្រាតិភោគ។

ចំពោះការតម្កល់ ឬការផ្ញើ វាគឺរបបមួយដែលមានករណីកិច្ចដាក់ប្រាតិភោគ ការដាក់ប្រាក់ ឬឧបករណ៍ដែលអាចជួញដូរបាន ដើម្បីឲ្យអ្នកមានសិទ្ធិលើប្រាតិភោគនោះ មានសិទ្ធិទាមទារយកវត្ថុដែលតម្កល់ទុកនោះបាន[48]។អ្នកដែលមានសិទ្ធិលើប្រាតិភោគសំដៅទៅលើបុគ្គលដែលទទួការផ្តល់ប្រាតិភោគ ដើម្បីជាប្រយោជន៍របស់ខ្លួន[49]។ចំពោះនីតិវិធីផ្ញើប្រាតិភោគ ត្រូវបានអនុវត្តតាមប្រកាស

[47] មាត្រា ៥៣៦ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[48] មាត្រា ៥៣៩ និង មាត្រា ៧២ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[49] មាត្រា ៧៣ កថាខ័ណ្ឌ១ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

របស់ក្រសួងយុតិធម៌ " ប្រកាសស្តី ពីនីតិវិធីនៃការផ្ញើរទៅតាមផ្លូវតុលាការ " ដែលនៅក្នុងប្រកាសនោះមានបញ្ជាក់លម្អិតអំពីនីតិវិធីផ្ញើ និងប្រគល់នូវវត្ថុផ្ញើ[50]។

**២.៥.៤ ប្រាក់រំដោះ**

**២.៥.៤.១ គោលបំណងនៃការដាក់ប្រាក់រំដោះ**

ចំពោះការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ នាំឲ្យមានការចាត់ចែងដែលកម្រិត នូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដែលមានគោលបំណងឲ្យសងជាប្រាក់ ក៏ប៉ុន្តែនៅពេលដែលបានផ្ញើប្រាក់ស្មើនឹងចំនួនទឹកប្រាក់ នៃសិទ្ធិលើបំណុល ដែលត្រូវបានរក្សាការពារ ឬចំនួនទឹកប្រាក់នៃកម្មវត្ថុដែលបានរឹបអូសជាបណ្តោះអាសន្ននោះ ភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមិនមានអត្ថិភាពទៀតទេ។ ដូច្នេះ តុលាការត្រូវកំណត់នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ នោះអំពីចំនួនទឹកប្រាក់ ដែលត្រូវផ្ញើដោយកូនបំណុលដើម្បីទទួលបានការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន[51] ។ គោលបំណងគឺការពារផលប្រយោជន៍របស់កូនបំណុល និងម្ចាស់បំណុល បើកូនបំណុលផ្ញើចំនួនទឹកប្រាក់ដែលបានកំណត់ដោយតុលាការ កូនបំណុលអាចរួចផុតពីការអនុវត្តរឹបអូសជាបណ្តោះអាសន្ន នូវ ទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ន ហើយកូនបំណុលក៏អាចប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិនោះបានដោយសេរីព្រោះថា ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នត្រូវបានលុបចោល។ បន្ទាប់ពីបានដាក់ប្រាក់រំដោះហើយវាគឺជាសេរីភាពរបស់កូនបំណុល បើសិនជាទ្រព្យសម្បត្តិ(អចលនវត្ថុ) របស់គាត់មានការកើនតម្លៃនោះគាត់អាចលក់បានថ្លៃដែរ រីឯម្ចាស់បំណុលនឹងទទួលបានការពេញចិត្តពីចំនួនទឹកប្រាក់ដែលកូនបំណុលបានផ្ញើ។ ប្រាក់រំដោះ គឺដើម្បីជំនួសទ្រព្យដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ន ។

**២.៥.៤.២ ចំនួននៃការដាក់ប្រាក់រំដោះ**

ការសម្រេចអំពីចំនួននៃប្រាក់រំដោះ គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រមក្នុងការសម្រេច ដោយមូលហេតុថាគ្មានមាត្រាណាមួយ ដែលបញ្ញត្តិពីការកំណត់ចំនួនប្រាក់រំដោះឡើយ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ ប៉ុន្តែ តុលាការត្រូវប្រឹងប្រែងដើម្បីរ៉ាប់រង ឲ្យប្រព្រឹត្តទៅដោយមានភាពយុត្តធម៌ និងការពារផលប្រយោជន៍សម្រាប់គូភាគី ដូច្នេះ ការដាក់ប្រាក់រំដោះត្រូវពិចារណាតាមពីរចំណុចដូចខាងក្រោម៖

---

[50] ឧបសម្ព័ន្ធ

[51] មាត្រា ៥៤៧ កថាខ័ណ្ឌ១ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

» **ចំនួនទឹកប្រាក់នៃទ្រព្យដែលត្រូវរឹបអូស** ៖ មានន័យថា តុលាការត្រូវពិចារណាទៅលើ តម្លៃនៃទ្រព្យរបស់កូនបំណុល ដែលម្ចាស់បំណុលធ្វើការស្នើសុំរឹបអូសជាបណ្ដោះអាសន្ន និងយក ចំនួនទឹកប្រាក់នៃទ្រព្យ ដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ជាចំនួនប្រាក់រំដោះ ដោយសារតែ ប្រាក់រំដោះ គឺជាប្រាក់មួយប្រភេទ សម្រាប់ដាក់ជំនួសនូវទ្រព្យដែលត្រូវបានរឹបអូសជាបណ្ដោះ អាសន្ន។ ប៉ុន្តែបើទ្រព្យនោះ មានតម្លៃលើសពីបំណុល នោះតុលាការត្រូវពិចារណាពីចំនួនបំណុលដែលទាមទារ។

»**សិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ**៖ តុលាការត្រូវធ្វើយ៉ាងណាឲ្យមានសមតុល រវាងសិទ្ធិលើបំណុល និងចំនួនទឹកប្រាក់នៃទ្រព្យដែលត្រូវបានរឹបអូស។ តុលាការត្រូវពិចារណាពី ចំនួននៃសិទ្ធិលើបំណុល ដែលត្រូវបានរក្សាការពារជាចំនួនប្រាក់រំដោះ ពីព្រោះគោលបំណងនៃការរឹបអូសជាបណ្ដោះអាសន្ន នឹងធានានូវការអនុវត្តដោយបង្ខំនាពេលអនាគត ចំពោះកម្មវត្ថុនៃបណ្ដឹងដែលមានគោលបំណងឲ្យសងជាប្រាក់ និងប្រាក់ដែលមានតម្លៃសមមូលទៅនឹងចំនួននៃសិទ្ធិលើបំណុល គឺគ្រប់គ្រាន់ហើយដើម្បីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដែលបានលើកឡើងខាងលើ។ ចៅក្រម អាចកំណត់ចំនួនប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន ស្មើនឹងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល។

ចំពោះនីតិវិធីធ្វើប្រាក់រំដោះត្រូវដូចគ្នាទៅ និងការផ្ញើរប្រាតិភោគដែលត្រូវបានអនុវត្តតាមប្រកាសរបស់ក្រសួងយុតិធម៌ " ប្រកាសស្តី ពីនីតិវិធីនៃការផ្ញើរទៅតាមផ្លូវតុលាការ " ដែលនៅក្នុងប្រកាសនោះមានបញ្ជាក់លំអិតអំពីនីតិវិធីផ្ញើ និងប្រគល់នូវវត្ថុផ្ញើ។

### ២.៥.៥ ដីកាសម្រេចលើកចោលពាក្យសុំ

ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ អាចត្រូវបានលើកចោលដោយដីកាសម្រេចលើកចោលពាក្យសុំ ក្នុងករណីថាពាក្យសុំនោះមិនបានបំពេញគ្រប់ល័ក្ខខ័ណ្ឌដូចជា មិនមានភាពចាំបាច់ក្នុងការរឹបអូសជាបណ្ដោះអាសន្នជាដើម ឬភស្តុតាងមិនគ្រប់គ្រាន់ដើម្បីធ្វើការបញ្ជាក់ជូនចៅក្រម ឬទាក់ទងទៅនឹងសមត្ថភាពរបស់ភាគី។ ចៅក្រមត្រូវបញ្ជូន ដីកាសម្រេចលើកចោលពាក្យសុំនោះ ទៅម្ចាស់បំណុល ដើម្បីឲ្យម្ចាស់បំណុលបានដឹងពីការលើកចោលពាក្យសុំរបស់ខ្លួន ហើយម្ចាស់បំណុលអាចធ្វើការប្ដឹងជំទាស់ ក្នុងរយៈពេលកំណត់ ២សប្ដាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង[52]។ ដីកាសម្រេចលើកចោលពាក្យសុំនោះ មិនចាំបាច់ធ្វើការបញ្ជូនទៅកូនបំណុលទេ។

[52] មាត្រា ៥៤៤ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

## ២.៦.ការបញ្ជូនដីកាសម្រេច

នៅពេលដែលតុលាការសម្រេច ចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ តុលាការត្រូវបញ្ជូនដីកាសម្រេចនោះទៅឲ្យភាគីទាំងម្ចាស់បំណុលនិងកូនបំណុលផងដែរ[53]។ ដោយកិច្ចការបញ្ជូនត្រូវធ្វើឡើងដោយក្រឡាបញ្ជី ហើយសម្រាប់ការបញ្ជូនត្រូវបានប្រតិបត្តដោយបុគ្គលិកប្រៃសណីយ៍ អជ្ញាសាលា ឬក្រឡាបញ្ជី[54]។ ការបញ្ជូននេះ គឺមានគោលបំណងដើម្បីឲ្យ ភាគីបានដឹងពីសេចក្ដីសម្រេចនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ហើយក៏ជាការផ្ដល់ឱកាសឲ្យកូនបំណុលក្នុងការប្ដឹងតវ៉ាដែរ។ ដើម្បីចៀសវាងនូវការរារាំងរបស់កូនបំណុល និងធានានូវការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន តុលាការគប្បីបញ្ជូនដីកាសម្រេចនោះទៅកូនបំណុលបន្ទាប់ពីតុលាការបញ្ជាក់ថាការអនុវត្តបានធ្វើចប់សព្វគ្រប់ហើយ។ ទោះបីនៅមុនពេលដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅកូនបំណុលក៏ដោយ ក៏ការអនុវត្តរក្សាការពារអាចធ្វើបានដែរ[55]។ ចំពោះដីកាសម្រេចលើកចោលពាក្យសុំរបស់ម្ចាស់បំណុល ដែលបានប្ដឹងសុំឲ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នវិញ គឺពុំចាំបាច់បញ្ជូនទៅឲ្យភាគីកូនបំណុលទេ ដោយហេតុថាដីកាសម្រេចលើកចោលពាក្យសុំនោះ វាពុំបានប៉ះពាល់ដល់ប្រយោជន៍របស់កូនបំណុលទេ ម្យ៉ាងវិញទៀត ក៏អាចចាត់ទុកបានថា ជាការទុកឱកាស ឲ្យម្ចាស់បំណុលស្វែងរកភស្តុតាងបន្ថែមទៀតសម្រាប់ប្ដឹងសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ជាថ្មីទៀតដែល ហើយការអនុវត្តរបៀបនេះក៏ជាការរក្សាការសម្ងាត់ឲ្យម្ចាស់បំណុលផងដែរ។ ដូច្នេះពាក្យថា **ដីកាសម្រេចរក្សាការពារ** នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គប្បីត្រូវពិចារណាក្នុងន័យថាជា **ដីកាសម្រេចបង្គាប់ឲ្យរក្សាការពារ** ។

ការបញ្ជូនអាចធ្វើឡើងតាមរូបភាពណាមួយដូចខាងក្រោម ៖

### ២.៦.១.ការបញ្ជូនដោយប្រគល់

ការបញ្ជូនត្រូវធ្វើឡើងដោយការប្រគល់ឯកសារ ដែលត្រូវបញ្ជូនទៅជនដែលត្រូវទទួលការបញ្ជូននោះ។ ក្នុងករណីដែលអ្នកទទួលការបញ្ជូនមិនចេះអក្សរ មន្ត្រីទទួលការបញ្ជូនគប្បីពន្យល់នូវខ្លឹមសារនៃឯកសារនោះនៅពេលប្រគល់ឯកសារ[56]។ សម្រាប់ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពវិញ ត្រូវធ្វើឡើងនៅចំពោះមុខអ្នកតំណាងដែលច្បាប់បានកំណត់។ ការបញ្ជូនត្រូវធ្វើនៅលំនៅឋានទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន។ ប៉ុន្តែ ចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់វិញ អាចធ្វើទៅទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់

[53] មាត្រា ៥៤៣ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[54] មាត្រា ២៤៦ កថាខ័ណ្ឌ២ និង ៣ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[55] មាត្រា ៥៦២ កថាខ័ណ្ឌ៣ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[56] មាត្រា ២៤៧ កថាខ័ណ្ឌ៣ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

សាមីខ្លួនបាន[57]។ ប៉ុន្តែ ភាគី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិ ក៏អាចជូនដំណឹងអំពីទីកន្លែងដែលខ្លួនត្រូវទទួលការបញ្ជូន ឲ្យតែទីកន្លែងនោះនៅក្នុងប្រទេសកម្ពុជា។ មិនតែប៉ុណ្ណោះភាគី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិក៏អាចជូនដំណឹងដើម្បីផ្លាស់ប្តូរទីកន្លែង ដែលបានជូនដំណឹងថាជា ទីកន្លែងដែលខ្លួនត្រូវទទួលការបញ្ជូន ឬអ្នកដែលបានជូនដំណឹងថាជាអ្នកទទួលការបញ្ជូននោះបានផងដែរ។ ។

### ២.៦.២ ការបញ្ជូននៅកន្លែងជួបប្រទះ

ក្នុងករណីដែលពុំច្បាស់ថាជនដែលត្រូវទទួលការ បញ្ជូននោះមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការ នៅក្នុងប្រទេសកម្ពុជាទេនោះ ការបញ្ជូនអាចធ្វើទៅបាននៅទីកន្លែងដែលបានប្រទះអ្នកនោះ លើកលែងតែក្នុករណីការបញ្ជូនចំពោះអ្នកដែលបានជូនដំណឹងដែលមានដូចជាភាគី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអណាត្តិអាចជូនដំណឹងអំពីទីកន្លែងដែលខ្លួន ត្រូវទទួលការបញ្ជូនឲ្យតែទីកន្លែងនោះស្ថិតនៅក្នុងប្រទេសកម្ពុជា [58]។ ទោះជាជនដែលត្រូវទទួលការបញ្ជូននោះមានលំនៅដ្ឋាន ទីសំណាក់ ទីកន្លែង អាជីវកម្ម និងទីស្នាក់ការនៅក្នុងប្រទេសកម្ពុជាច្បាស់លាស់ និងមានការជូនដំណឹង ពីទីកន្លែងដែលត្រូវធ្វើការបញ្ជូនក៏ដោយ បើភាគីមិនប្រកែកចំពោះការបញ្ជូននៅទីកន្លែងដែលជួបប្រទះទេ គឺអាចធ្វើតាមវិធីនេះបានផងដែរ។

### ២.៦.៣.ការបញ្ជូនដោយបន្ទប់កិច្ច

ប្រសិនបើមិនបានជួបជន ដែលត្រូវទទួលការបញ្ជូននៅឯទីកន្លែងដែលត្រូវទទួលការបញ្ជូនទេនោះមន្ត្រីទទួលបន្ទុកការបញ្ជូន អាចប្រគល់ឯកសារទៅឲ្យអ្នកបម្រើ ឬអ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬនៅជាមួយ ដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន[59]។ សម្រាប់អ្នកដែលមានការយល់ដឹងសមរម្យ ក្នុងការទទួលឯកសារនេះ អាចជាអ្នកដែលមានការយល់ដឹងច្បាស់អំពីសារៈសំខាន់នៃការបញ្ជូន យល់ពីអត្ថន័យនៃឯកសារដែលបានទទួល និងមានសមត្ថភាពអាចយកឯកសារនោះ ទៅប្រគល់ឲ្យជនដែលត្រូវទទួលការបញ្ជូននោះបាន។

ឧទាហរណ៍៖ ភរិយាអាចទទួលជំនួសប្តី ដែលជាបុគ្គលដែលត្រូវទទួលការបញ្ជូននោះបាន ប៉ុន្តែ ប្រសិនបើភរិយាជាអ្នកប្តឹងប្តីវិញ នោះការទទួលការបញ្ជូនរបស់ភរិយាជំនួសប្តី នឹងត្រូវចាត់

[57] មាត្រា ២៤៩ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[58] មាត្រា ២៥១ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[59] មាត្រា ២៥២ កថាខណ្ឌ១ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

ទុកជាមោឃៈ ព្រោះមានទំនាស់ផលប្រយោជន៍ ម្យ៉ាងវិញទៀតយើងមិនរំពឹងថាភរិយានឹងយកឯកសារដែលត្រូវបញ្ជូននោះទៅឲ្យប្ដីទេ។

**២.៦.៤.ការបញ្ជូនដោយទុកចោល**

បើជនដែលត្រូវទទួលការបញ្ជូន ឬជនដែលត្រូវទទួលការ បញ្ជូនដោយបង្គ្រប់កិច្ចមិនព្រមទទួលការបញ្ជូន ដោយគ្មានមូលហេតុត្រឹមត្រូវទេនោះ អាចទុកឯកសារដែលត្រូវបញ្ជូននោះចោលនៅទីកន្លែងនោះបាន[60] ។

**២.៦.៥.ការបញ្ជូនទៅបរទេស**

ក្នុងករណីជនដែលត្រូវទទួលការបញ្ជូនមានទីលំនៅនៅឯបរទេស ហើយពុំមានលំនៅឋាន ទីសំណាក់ ទីកន្លែង អាជីវកម្ម ឬទីស្នាក់ការដែលអាចធ្វើការបញ្ជូនបានទេ នោះអាចមានរបៀបចំនួនពីរដើម្បីបញ្ជូនៈ

១/ករណីជនដែលត្រូវទទួលការបញ្ជូននោះជាជនជាតិបរទេស គប្បីបញ្ជូនដោយប្រគល់ឲ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះ ជាអ្នកអនុវត្តការបញ្ជូន។

២/ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិខ្មែរ តែរស់នៅបរទេស គប្បីបញ្ជូនដោយប្រគល់ឲ្យឯកអគ្គរាជទូត ភារធារី ឬកុងស៊ុលរបស់ប្រទេសកម្ពុជាប្រចាំនៅប្រទេសនោះ ជាអ្នកអនុវត្តការបញ្ជូននោះ[61]។

- **កំណត់សម្គាល់**

១. មុននឹងបញ្ជូន តុលាការគប្បីពិនិត្យមើលសន្ធិសញ្ញា ឬអនុសញ្ញារវាងប្រទេសនោះ និងប្រទេសកម្ពុជា ឬកិច្ចព្រមព្រៀងផ្សេងទៀត ឬការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ព្រោះថាវាអាចកំណត់ពីរបៀបនៃការបញ្ជូន។

២. ចំពោះការបញ្ជូនទៅជនបរទេស ដែលរស់នៅក្នុងប្រទេសកម្ពុជាវិញ ត្រូវប្រើតាមវិធីនៃការបញ្ជូន ដូចជាការបញ្ជូនចំពោះជនជាតិខ្មែរដែរ។

**២.៦.៦.ការបញ្ជូនតាមការផ្សាយជាសាធារណៈ**

ការបញ្ជូនតាមការផ្សាយជាសាធារណៈអាចធ្វើ ទៅបានលុះត្រាតែគោរពទៅតាមល័ក្ខខ័ណ្ឌណាមួយក្នុងចំណោមល័ក្ខខ័ណ្ឌដូចដែលបានរៀបរាប់ ដូចខាងក្រោមៈ

១/ទោះជាខំប្រឹងប្រែងស្រាវជ្រាវរកយ៉ាងណា ក៏មិនអាចដឹងពីទីកន្លែងដែលត្រូវបញ្ជូន។

[60] មាត្រា ២៥២ កថាខណ្ឌ២ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[61] សៀវភៅនីតិវិធីរដ្ឋប្បវេណី រៀបរៀងដោយៈ លោក កេត សុជាតិ សម្រាប់និស្សិតបរិញ្ញាប័ត្រជាន់ខ្ពស់ នីតិសាស្ត្រ

២/ក្នុងករណីយើងដឹងពីទីកន្លែងដែលត្រូវបញ្ជូន ប៉ុន្តែការបញ្ជូនមិនអាចធ្វើទៅបានទោះជាព្យាយាមបញ្ជូនតាមរបៀបនៃការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល ក៏ដោយ។

៣/មិនអាចធ្វើការបញ្ជូនដែលត្រូវធ្វើនៅបទេស ឬត្រូវបានទទួលស្គាល់ថា គ្មានលទ្ធិភាពនឹងធ្វើបាន ក្នុងករណីដែលត្រូវធ្វើការបញ្ជូនទៅបរទេស។

៤/ក្នុងករណីតុលាការមិនបានទទួលលិខិតបញ្ជាក់ ពីការបញ្ជូនពីក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៅបរទេស ក្នុងអំឡុងពេល ៦ខែគិតចាប់ពីពេលបញ្ជូន។

ចាំបាច់ត្រូវតែមានពាក្យសុំរបស់ភាគីដែលសុំឲ្យ តុលាការធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ និងបន្ទាប់ពីទទួលបានការអនុញ្ញាតិពីតុលាការ ទើបអាចប្រើការបញ្ជូនតាមវិធីនេះបាន។ ប៉ុន្តែក្នុងករណីដើម្បីជៀសវៀងការយឺតយ៉ាវ និងយល់ឃើញថាមានការចាំបាច់ តុលាការក៏អាចបង្គាប់ឲ្យក្រឡាបញ្ជី ធ្វើការ បញ្ជូនផ្សាយជាសាធារណៈដោយឆន្ទានុសិទ្ធិ ទោះជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ។

- **សម្គាល់**

១/បើការបញ្ជូនតាមការផ្សាយជាសាធារណៈត្រូវបានធ្វើ ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលត្រូវបានបំពេញហើយនោះ នៅតែមិនអាចបញ្ជូនបាននោះក្រឡាបញ្ជីគប្បីជូនដំណឹងដោយរបៀបសមរម្យ (តាមទូរស័ព្ទ , ផ្ញើតាម ប៉ុស្តិ៍ប្រៃសនីយ៍ ឬបិទនៅលំនៅឋាន , ទីសំណាក់របស់អ្នកដែលត្រូវបានទទួលការ បញ្ជូនជាដើម) អំពីហេតុផលដែលនាំឲ្យមានការបញ្ជូនផ្សាយជាសាធារណៈ ទៅភាគីដែលត្រូវទទួលការបញ្ជូននោះ។

២/ការបញ្ជូនតាមការផ្សាយជាសាធារណៈចាប់ពីលើកទី២ទៅ ចំពោះភាគីដដែល តុលាការត្រូវធ្វើដោយឆន្ទានុសិទ្ធិ ប៉ុន្តែចំពោះករណីការបញ្ជូនទៅជនដែលនៅបរទេស ត្រូវតែមានពាក្យសុំរបស់ភាគីរាល់លើកនៃការផ្សាយជាសាធារណៈ។

**របៀបបញ្ជូនជាសាធារណៈ៖**

១/ ក្រឡាបញ្ជី ត្រូវបិទប្រកាសនៅទីកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ ឬ ទីកន្លែងដែលតុលាការយល់ថាសមស្រប[62] និងត្រូវប្រកាស ថា ក្រឡាបញ្ជីជាអ្នករក្សាទុកនៅឯកសារដែលធ្វើការបញ្ជូន ហើយឯកសារបញ្ជូននោះអាចប្រគល់ឲ្យទៅជនដែលត្រូវទទួលការបញ្ជូននៅពេលណាក៏បាន។

២/ តុលាការអាចចុះក្នុងរាជកិច្ច ឬសារព័ត៌មានផ្សាយថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ។

[62] អាចប៉ុស្តិ៍ សាលាឃុំ/ សង្កាត់ជាដើម

៣/ ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស ក្រឡាបញ្ជីមិនចាំបាច់ផ្សាយក្នុងរាជកិច្ច ឬក្នុងសារព័ត៌មានក៏បាន[63]។

**អានុភាព៖**

១/ការបញ្ជូនតាមការផ្សាយជាសាធារណៈ នឹងមានអនុភាពជាការបញ្ជូននៅក្រោយអំឡុងពេល ២ សប្តាហ៍បានកន្លងហួសទៅ ដោយគិតចាប់ពីថ្ងៃដែលបានបិទប្រកាស។ ក៏ប៉ុន្តែ ការបញ្ជូនតាមការផ្សាយជាសាធារណៈជាលើកទី ២ ទៅនឹងមាននៅថ្ងៃបន្ទាប់ពីថ្ងៃបិទប្រកាសនោះ។

២/អានុភាពនៅទីនេះមានន័យថា ការបញ្ជូនមានសុពលភាពហើយត្រូវចាត់ទុកថា អ្នកដែលត្រូវទទួលការបញ្ជូនបានទទួលការបញ្ជូននោះ។

៣/ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈ ដែលត្រូវធ្វើទៅបរទេសនឹងមានអានុភាពជាការបញ្ជូននៅក្រោយអំឡុងពេល ០៦សប្តាហ៍បន្ទាប់ពីថ្ងៃបិទប្រកាស។

បន្ទាប់ពីធ្វើការបញ្ជូនរួចហើយ មន្ត្រីទទួលបន្ទុកការបញ្ជូនដែលបានធ្វើការបញ្ជូននោះ ត្រូវធ្វើរបាយការណ៍អំពីការបញ្ជូននោះទៅតុលាការ។ របាយការណ៍នៃការបញ្ជូននោះត្រូវ បញ្ជាក់អំពីចំណុចដូចខាងក្រោម៖

**ក**/ សញ្ញាណនៃរឿងក្តី និងឯកសារដែលបានបញ្ជូន។

**ខ**/ ជនដែលត្រូវទទួលការបញ្ជូន។

**គ**/ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូន។

**ឃ**/ វិធីបញ្ជូន។

**ង**/ ចំណាត់ការតាមកថាខ័ណ្ឌទី៣ មាត្រា២៤៧នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងករណីជនដែលត្រូវទទួលការបញ្ជូននោះមិនចេះអក្សរ។

**ច**/ ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដែលទទួលឯកសារ។

**ឆ**/ ហេតុការណ៍ដែលមិនព្រមទទួលការបញ្ជូន នៅក្នុងករណីដែលជនត្រូវទទួលការបញ្ជូនឬអ្នកដែលត្រូវទទួលការប្រគល់ឯកសារតាមបញ្ញាតិ នៃកថាខ័ណ្ឌទី១នៃមាត្រា ២៥២ (ការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល) ប្រកែកមិនព្រមទទួល។

**ជ**/ ហេតុការណ៍នៅក្នុងករណីដែលការបញ្ជូនបានធ្វើតាមបញ្ញាតិមាត្រា ២៥២ (ការបញ្ជូនដោយបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល)។

**ឈ**/ ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន[64]។

[63] មាត្រា ២៥៦ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៦

[64] គំរូនៃរបាយការណ៍បញ្ជូនក្នុង ឧបសម្ព័ន្ធនៅផ្នែកខាងក្រោយ

ប្រសិនបើក្នុងករណីដែលបានព្យាយាមបញ្ជូនតែមិនអាចសម្រេចបាន មន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវធ្វើរបាយការណ៍អំពីហេតុការណ៍នោះ និងចំណុចដែលបានកំណត់នៅចំណុចខាងលើចាប់ពីចំណុច **ក** រហូតដល់ចំណុច **ឃ** និងចំណុច **ឈ** ជូនទៅតុលាការ។

# ជំពូកទី៣

# ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

## ៣.១. ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

ស្ថាប័នដែលទទួលបន្ទុក លើការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលវត្ថុ គឺតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ជាអ្នកមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ[65]។ ដូច្នេះ ក្រោយពីតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ចំពោះអចលនវត្ថុតាមពាក្យសុំហើយនោះ ម្ចាស់បំណុលនៃការអនុវត្តរក្សាការពារ អាចដាក់ពាក្យសុំឲ្យអនុវត្តចំពោះដីកាសម្រេចនោះទៅតុលាការអនុវត្ត ដែលជាតុលាការមានសមត្ថកិច្ចក្នុងការអនុវត្តដីកាសម្រេចនោះ។ បើយើងនិយាយអំពី ការចាត់ចែងរក្សាការពារជាបណ្ដោះអាសន្នទាំងមូល ស្ថាប័នដែលទទួលបន្ទុកក្នុងការអនុវត្តដីកាសម្រេច គឺមានពីរ ៖ ១/ តុលាការអនុវត្តរក្សាការពារ និង ២/ អាជ្ញាសាលា ប៉ុន្តែសម្រាប់ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុវិញ គឺអាជ្ញាសាលាគ្មានភារកិច្ច ឬ គ្មានសមត្ថកិច្ចឡើយ។

## ៣.២. ពាក្យសុំឲ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

ម្ចាស់បំណុល ត្រូវសរសេរពាក្យសុំឲ្យអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ហើយបន្ទាប់មកម្ចាស់បំណុល ត្រូវយកពាក្យសុំរបស់គាត់នោះចូលទៅការិយាល័យរដ្ឋបាលនៃតុលាការអនុវត្តដើម្បីចាប់ផ្ដើមនីតិវិធីអនុវត្ត។ សម្រាប់ពាក្យសុំរបស់ម្ចាស់បំណុលនោះដែរ ម្ចាស់បំណុលត្រូវសរសេរ ពាក្យរបស់ខ្លួនឲ្យបានត្រឹមត្រូវ ហើយភ្ជាប់ជាមួយឯកសារមួយចំនួនដូចមានបញ្ជាក់ខាងក្រោម។

### ៣.២.១ ទម្រង់ពាក្យសុំឲ្យអនុវត្តដីកាសម្រេច និងឯកសារដែលត្រូវភ្ជាប់

#### ៣.២.១.១ ទម្រង់ពាក្យសុំឲ្យអនុវត្តដីកាសម្រេច

ពាក្យសុំឲ្យអនុវត្តការរឹបអូសអូសជាបណ្ដោះអាសន្នត្រូវសរសេរតាមចំណុចដូចខាងក្រោម៖

**ក.** ឈ្មោះ ឬនាមករណ៍ និងអាស័យដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្តនិងកូនបំណុលនៃការអនុវត្ត ហើយនឹងឈ្មោះ និងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ (ម្ចាស់បំណុលអាចប្រើប្រាស់នូវបញ្ជីពណ៌នាអំពីភាគីបាន)។

**ខ.** សញ្ញាណនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដែលជាលិខិតអនុវត្ត។

**គ.** សេចក្ដីសុំឲ្យអនុវត្តតាមការបង្ខំ ដោយផ្ទាល់ចំពោះអចលនវត្ថុ ដែលជាកម្មវត្ថុនៃការរឹបអូស។

[65] មាត្រា ៥៦៧ កថាខ័ណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

**ឃ.** សញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុ នៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្ត បានស្នើសុំ (ម្ចាស់ បំណុលអាចប្រើប្រាស់បញ្ជីពណ៌នាអំពីអចលនវត្ថុ)។

**ង.** ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឲ្យអនុវត្តដោយបង្ខំតាមការអនុវត្តដោយជំនួស ឬវិធានបង្ខំប្រយោល។[66] បន្ទាប់ពីសរសេរពាក្យសុំឲ្យអនុវត្តរួចហើយម្ចាស់បំណុលត្រូវ ភ្ជាប់នូវឯកសារមួយទៀតដូចមានបញ្ជាក់ក្នុងចំណុចខាងក្រោមបន្ទាប់។

### ៣.២.១.២ ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំឲ្យអនុវត្តដីកាសម្រេច

កាលណាអ្នកប្តឹងសុំឲ្យមានការរឹបអូសជាបណ្តោះអាសន្ន បានទទួលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នពីតុលាការរួចហើយនោះ អ្នកប្តឹងសុំត្រូវដាក់ពាក្យសុំឲ្យអនុវត្តហើយ ត្រូវភ្ជាប់មកជាមួយពាក្យសុំនោះរួមមាន៖

• លិខិតចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ សម្រាប់ការសុំឲ្យអនុវត្តអ្នកប្តឹងសុំនៃដីកាសម្រេចនោះពុំចាំបាច់ស្នើសុំរូបមន្តអនុវត្តទេ ប៉ុន្តែបើការអនុវត្តនោះធ្វើឡើងចំពោះ ឬ សម្រាប់ជនក្រៅពីភាគី ដែលត្រូវបានកំណត់នៅក្នុងដីកាសម្រេច ត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេច ដែលភ្ជាប់នឹងរូបមន្តអនុវត្ត[67]។

• លិខិតបញ្ជាក់អំពីអ្នកតំណាងដោយអាណត្តិ៖ កាលណាអ្នកប្តឹងសុំឲ្យចេញ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ បានផ្តល់សិទ្ធិអំណាចឲ្យអ្នកតំណាងដោយអាណត្តិ សិទ្ធិអំណាចនោះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ប៉ុន្តែ ប្រសិនបើមានបណ្តឹងអង្គសេចក្តីហើយ ហើយក៏មានលិខិតប្រគល់សិទ្ធិអ្នកតំណាងដោយអាណត្តិ នោះអ្នកតំណាងក៏អាចធ្វើសកម្មភាព ចំពោះការចាត់ចែងរក្សាការពារបានដែល ដោយគ្រាន់តែធ្វើការ ចម្លងឯកសារផ្លូវការ រួចភ្ជាប់មកជាមួយពាក្យសុំអនុវត្តតែម្តង។ នៅពេលដែលដាក់ពាក្យសុំឲ្យធ្វើ ការរឹបអូសជាបណ្តោះអាសន្នទៅតុលាការអនុវត្ត អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការអនុវត្តដែលជាសោហ៊ុយចាំបាច់សម្រាប់នីតិវិធីអនុវត្ត[68]។ ប៉ុន្តែ បើអ្នកដាក់ពាក្យសុំអនុវត្តមិនបានបង់សោហ៊ុយជាមុនទេនោះ តុលាការអនុវត្តអាចលើកចោលពាក្យសុំនោះ ឬលុបចោលនូវនីតិវិធីអនុវត្តបាន។

[66] មាត្រា ៥៦៤ និងមាត្រា ៣៩៩ កថាខ័ណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[67] មាត្រា ៥៦២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[68] មាត្រា ៥៣៧ កថាខ័ណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### ៣.២.២ ការពិនិត្យលើពាក្យសុំ និង ការពិនិត្យលើល័ក្ខខ័ណ្ឌចាំបាច់

#### ៣.២.២.១ ការពិនិត្យលើពាក្យសុំ

ពាក្យសុំឲ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន គឺត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដូច្នេះនៅពេលដែលតុលាការអនុវត្ត បានទទួលពាក្យសុំឲ្យអនុវត្តដីកាសម្រេច តុលាការត្រូវពិនិត្យថាតើពាក្យសុំឲ្យអនុវត្តដីកាសម្រេចនោះ ស្របនឹងល័ក្ខខ័ណ្ឌនៃរបៀបដាក់ពាក្យសុំ ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទម្រង់នៃពាក្យសុំ ខាងលើដែរ ឬទេ។ ក្រៅពីនេះតុលាការអនុវត្តត្រូវពិនិត្យផងដែរ នូវឯកសារភ្ជាប់ដូចជា លិខិតចម្លងយថាភូតនៃដីកាសម្រេច រឹបអូសជាបណ្ដោះអាសន្ន លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ បញ្ជីឈ្មោះភាគី។

#### ៣.២.២.២ ការពិនិត្យលើល័ក្ខខ័ណ្ឌចាំបាច់នៃការអនុវត្តដីកាសម្រេច

បន្ទាប់ពីបានពិនិត្យលើរបៀបនៃការដាក់ពាក្យសុំ ឲ្យអនុវត្តដីកាសម្រេចហើយនោះ តុលាការអនុវត្តត្រូវពិនិត្យមើលលើល័ក្ខខ័ណ្ឌចាំបាច់ នៃ ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ព្រោះថាបើមិនបានបំពេញនូវល័ក្ខខ័ណ្ឌទាំងនោះទេ គឺ អនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នមិនអាចធ្វើទៅបានឡើយ។ ល័ក្ខខ័ណ្ឌចាំបាច់ទាំងនោះមានដូចខាងក្រោម៖

- លិខិតយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន៖ តុលាការត្រូវពិនិត្យមើល ថាតើឈ្មោះភាគីដែលមាននៅក្នុងពាក្យសុំឲ្យអនុវត្តនោះ ដូចគ្នាទៅនឹងឈ្មោះភាគី ដែលមាននៅក្នុងដីកាសម្រេចដែរ ឬទេ។ បើឈ្មោះដូចគ្នា គឺការអនុវត្តដីកាសម្រេច ត្រូវបានធ្វើឡើងដោយផ្អែកទៅលើតែឯកសារចម្លងលិខិតយថាភូតនៃដីកាសម្រេចតែប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើឈ្មោះភាគីមិនដូចគ្នាទេ គឺការអនុវត្តត្រូវធ្វើឡើងដោយ ផ្អែកទៅលើឯកសារលិខិតចម្លងយថាភូតនៃ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត[69]។
- អំឡុងពេល៖ ការរឹអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ មិនអាចត្រូវធ្វើឡើយ បើអំឡុងពេល ០២ សប្ដាហ៍បានកន្លងហួសទៅចាប់ពីថ្ងៃដែលដីកាសម្រេចនោះបញ្ជូនទៅដល់ម្ចាស់បំណុល[70]។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថាប្រសិនបើ មិនអនុវត្តភ្លាមៗទេ នោះការរឹបអូសជាបណ្ដោះអាសន្ន នឹងមិនមានភាពចាំបាច់ឡើយ។ ក៏ប៉ុន្តែវាជាការគ្រប់គ្រាន់ហើយក្នុងការចាប់ផ្ដើមសកម្មភាពនៃការអនុវត្ត នៅក្នុងអំឡុងពេល ០២ សប្ដាហ៍ ចំណែកឯសកម្មភាពបន្តបន្ទាប់មកទៀត នៃការអនុវត្តមិនចាំបាច់ត្រូវតែធ្វើនៅក្នុងអំឡុងពេលនេះទេ។ អំឡុងពេលនេះមិនកែប្រែជាថ្មី ដោយដីកាសម្រេច

[69] ទំព័រ ៤៨ ចំណុច ៧.១ នៃ សៀវភៅស្ដីពី នីតិវិធីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ បោះពុម្ពលើកទី ១ (ខែមិនា ឆ្នាំ ២០០៩)

[70] មាត្រា ៥៦២ កថាខ័ណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ទទួលស្គាល់ការរឹបអូសជាបណ្ដោះអាសន្ន ដែលបានចេញដោយសារតែមានការដាក់ពាក្យសុំតវ៉ានោះទេ។ ក៏ប៉ុន្តែក្នុងករណី ដែលការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានផ្អាកនៅមុនពេលផុតអំឡុងពេលនេះ ត្រូវចាត់ទុកថាអំឡុងពេលមានដំណើរការពីដំបូង ចាប់ពីពេលដែលការផ្អាកបានកន្លងផុត។ ទោះបីជាអំឡុងពេលនោះកន្លងផុតក៏ដោយ ក៏មិនធ្វើឲ្យដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន បាត់បង់អានុភាពឡើយ[71]។

- ក្នុងករណីដែលតុលាការចេញដីកាសម្រេចរក្សាការពារដោយឲ្យដាក់ប្រាតិភោគ ប្រាតិភោគនោះជាល័ក្ខខ័ណ្ឌមួយសម្រាប់ការ អនុវត្តដីកាសម្រេច ដូច្នេះតុលាការ ត្រូវពិនិត្យមើលថាតើប្រាតិភោគត្រូវបានដាក់រួចហើយ ឬមិនទាន់ដាក់។

## ៣.៣ ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ តាមរយៈពាក្យសុំរបស់ម្ចាស់បំណុលនោះ យើងអាចបែងចែកការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ចំពោះអចលនវត្ថុនោះជាពីរប្រភេទ គឺការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលចុះបញ្ជីរួច និងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី។ មូលហេតុចំពោះការបែងចែកជាពីរប្រភេទនេះ ព្រោះថា ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ចំពោះអចលនវត្ថុដែលបានចុះបញ្ជី និងមិនទាន់បានចុះបញ្ជី វាមានភាពខុសគ្នា។ នៅផ្នែកខាងក្រោមនេះយើងខ្ញុំនឹងធ្វើការបញ្ជាក់ជាថាតើ អចលនវត្ថុដែលបានចុះបញ្ជីរួចសំដៅទៅអ្វី និងអចលនវត្ថុមិនទាន់បានចុះបញ្ជីរួចសំដៅទៅលើអ្វី។

### ៣.៣.១ ការអនុវត្តចំពោះអចលនវត្ថុដែលបានចុះបញ្ជី

អចលនវត្ថុដែលបានចុះបញ្ជីរួច សំដៅទៅលើអចលវត្ថុដែលបានចុះបញ្ជីសុរិយោដីដើម្បីទទួលបានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលវត្ថុ (តាមភាសាសាមញ្ញហៅថាប្លង់រឹង)។ ប្រសិនបើអចលនវត្ថុ ដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ននោះ ជាប្រភេទអចលនវត្ថុដែលបានចុះបញ្ជីរួច នោះ ការអនុវត្តចំពោះការរឹបអូសជាបណ្ដោះអាសន្ន មិនមានភាពស្មុគស្មាញប៉ុន្មានទេ ព្រោះថា ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើឡើងតាមរបៀបចុះបញ្ជីពីការរឹបអូសជាបណ្ដោះអាសន្ន[72]។ ក្នុងចុះបញ្ជីពីការរឹបអូសបណ្ដោះអាសន្ន ក្រឡាបញ្ជីត្រូវធ្វើការផ្ទុកផ្ដាក់ឲ្យស្ថាប័នដែលមានសមត្ថកិច្ច ចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន[73]។ ស្ថាប័នដែលមានសមត្ថកិច្ចនេះសំដៅទៅលើ រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ ក្រុង

[71] កថាភាគទី៤ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំណុច១ ល័ក្ខខ័ណ្ឌនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ទំព័រ ២០៦ នៃសេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ

[72] កថាខ័ណ្ឌទី ១ មាត្រា ៥៦៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[73] កថាខ័ណ្ឌទី ៣ មាត្រា ៥៦៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ស្រុក ខ័ណ្ឌ ដែលអចលនវត្ថុតាំងនៅ។ ការផ្ទុកផ្តាក់របស់ក្រឡាបញ្ជី ត្រូវធ្វើឡើងតាមរយៈលិខិតដែលមានឈ្មោះថា " លិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជី " ហើយក្រឡាបញ្ជីត្រូវធ្វើការបញ្ជូនលិខិតនេះទៅស្ថាប័នមានសមត្ថកិច្ច ។

#### ៣.៣.១.១. ទម្រង់នៃលិខិតផ្ទុកផ្តាក់

លិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជី ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ឈ្មោះតុលាការ លេខលិខិតផ្ទុកផ្តាក់ ឈ្មោះក្រឡាបញ្ជី កាលបរិច្ឆេទ ហត្ថលេខា និងបោះត្រារបស់ក្រឡាបញ្ជី[74]។ ក្រៅពីនេះត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនទៀតដូចជា៖

កម្មវត្ថុ:...................(សរសេរអំពីខ្លឹមសារចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន............)

**ក.** អត្តសញ្ញាណនៃអចលនវត្ថុ...........................(លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំង)

**ខ.** ឈ្មោះកម្មសិទ្ធិករ ឬម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ នៃអចលនវត្ថុ ......................... ...................... (អាស័យដ្ឋាន..................................)

**គ.** គោលបំណងនៃការចុះបញ្ជី...................................(ចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននូវ កម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ ទៅលើអចលនវត្ថុចំណុច " ក" )

**ឃ.**មូលហេតុ............................... (ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ......ចុះថ្ងៃទី ......... ខែ...........ឆ្នាំ............ និងឈ្មោះរបស់តុលាការ.........................។

**ង.** ឈ្មោះម្ចាស់បំណុល ................................. (អាស័យដ្ឋាន.........................................)

**ច.** ឈ្មោះកូនបំណុល..................................(អាស័យដ្ឋាន..........................................)

**ឯកសារភ្ជាប់ជាមួយ:**

- ✓ ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។

#### ៣.៣.១.២. របៀបចុះបញ្ជីសម្រាប់ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលវត្ថុ

របៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ក្នុងសៀវភៅគោលបញ្ជីក្នុងសៀវភៅគោលដីធ្លីនៅពេលដែលរដ្ឋបាលសុរិយោដីទទួលបានលិខិតផ្ទុកផ្តាក់ គឺត្រូវចុះបញ្ជីទៅតាមប្រភេទនៃ ការរឹបអូសជាបណ្តោះអាសន្ន៖

**ក.** ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នកម្មសិទ្ធិ ត្រូវសរសេរក្នុងសៀវភៅគោលបញ្ជីដីធ្លីនៅក្នុងខ្ទង់បន្ទុកលើអចលនវត្ថុថា:

---

[74] ជំពូកទី២ ផ្នែកទី១ ប្រការ៥ នៃប្រកាសអន្តរក្រសួងស្តីពី នីតិវិធីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

" ត្រូវបានរឹបអូសជាបណ្តោះអាសន្នកម្មសិទ្ធិ តាមដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន លេខ .... ចុះថ្ងៃទី....ខែ.........ឆ្នាំ...... របស់តុលាការ.......... លរ.AJ........(ជាទឹកក្រហម)" រួចបោះត្រា លេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬខ្មៅ)។

**ខ.** ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំណែកកម្មសិទ្ធិអវិភាគ ត្រូវសរសេរក្នុងសៀវភៅគោលបញ្ជីដីធ្លីនៅក្នុងខ្ទង់បន្ទុកលើអចលនវត្ថុថា: "ត្រូវបានរឹបអូសជាបណ្តោះអាសន្នចំណែកកម្មសិទ្ធិអវិភាគរបស់ឈ្មោះ..........................តាមដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ.............ចុះថ្ងៃទី....ខែ.........ឆ្នាំ...... របស់តុលាការ.......... លរ.AJ........(ជាទឹកក្រហម)" រួចបោះត្រាលេខាចារឹក និងចុះការបរិច្ឆេតនៃការចុះបញ្ជី (ជាទឹកខៀវ ឬខ្មៅ)។

**គ.** ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវសរសេរក្នុងសៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍នៅក្នុងខ្ទង់បន្ទុកលើអចលនវត្ថុថា: "ត្រូវបានរឹបអូសជាបណ្តោះអាសន្នសិទ្ធិជួលអិន្ត្រៃយ៍ តាមដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ..........ចុះថ្ងៃទី........ខែ...............ឆ្នាំ.............របស់តុលាការ.....................លរ.AJ........(ជាទឹកក្រហម)" រួចបោះត្រា លេខាចារឹក និងចុះការបរិច្ឆេតនៃការចុះបញ្ជី (ជាទឹកខៀវ ឬខ្មៅ)។

**ឃ.** ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ដែលជាសិទ្ធិរួម ត្រូវសរសេរក្នុងសៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ នៅក្នុងខ្ទង់បន្ទុកលើអចលនវត្ថុថា៖ "ត្រូវបានរឹបអូសជាបណ្តោះអាសន្នចំណែកសិទ្ធិជួលអចិន្ត្រៃយ៍របស់ឈ្មោះ.................................. តាមដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ..................ចុះថ្ងៃទី............ខែ.........ឆ្នាំ............. របស់តុលាការ.............................. លរ.AJ........(ជាទឹកក្រហម)" រួចបោះត្រា លេខាចារឹក និងចុះការបរិច្ឆេតនៃការចុះបញ្ជី (ជាទឹកខៀវ ឬខ្មៅ)។

**ង.** ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នផលុបភោគ ត្រូវសរសេរ ក្នុងសៀវភៅចុះបញ្ជីផលុបភោគ នៅក្នុងខ្ទង់បន្ទុកលើអចលនវត្ថុថា: "ត្រូវបានរឹបអូសជាបណ្តោះអាសន្នផលុបភោគ តាមដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ..........ចុះថ្ងៃទី........ខែ........ ឆ្នាំ............របស់តុលាការ.................................... លរ.AJ........(ជាទឹកក្រហម)" រួចបោះត្រាលេខាចារឹក និងចុះការបរិច្ឆេតនៃការចុះបញ្ជី (ជាទឹកខៀវ ឬខ្មៅ)។

**ច.** ចំពោះការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំណែកផលុបភោគ ដែលជាសិទ្ធិរួម ត្រូវសរសេរក្នុងសៀវភៅចុះបញ្ជីផលុបភោគ នៅក្នុងខ្ទង់បន្ទុកលើអចលនវត្ថុថា: "ត្រូវបានរឹបអូសជាបណ្តោះអាសន្នចំណែកផលុបភោគរបស់ឈ្មោះ.............................តាមដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ.........ចុះថ្ងៃទី........ខែ...............ឆ្នាំ............របស់តុលាការ..................

លរ.AJ........(ជាទឹកក្រហម)" រួចបោះត្រា លេខាចារឹក និងចុះការបរិច្ឆេតនៃការចុះបញ្ជី (ជាទឹកខៀវ ឬខ្មៅ)[75]។

បន្ទាប់ពីបានចុះបញ្ជី តាមការផ្ទុកផ្តាក់របស់ក្រឡាបញ្ជីរួចមក រដ្ឋបាលសុរិយាដីត្រូវថតចម្លង ចេញពីសៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួសអចិន្ត្រៃយ៍ ឬសៀវភៅចុះបញ្ជីផលុបភោគដែលបានចុះនោះ ដោយមានសេចក្តីបញ្ជាក់របស់ប្រធានរដ្ឋបាលសុរិយោដី រាជធានី ខេត្ត ថា " បានចម្លងត្រឹមត្រូវតាមច្បាប់ដើម " រួចផ្ញើទៅក្រឡាបញ្ជីដែលបានផ្ញើលិខិតផ្ទុកផ្តាក់នោះ[76]។ ហើយក្រឡាបញ្ជីនោះ ត្រូវរក្សាទុកនូវឯកសារចម្លង ដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះ ក្នុងសំណុំរឿង។ ប្រសិនបើក្រឡាបញ្ជីពិនិត្យឃើញថា ឯកសារចម្លងដែលបានផ្ញើមកក្រឡាបញ្ជីនោះ ចុះមិនបានត្រឹមត្រូវទៅតាមលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជី ដូចជាមានចំណុចខ្វះខាត ឬចំណុចមិនត្រឹមត្រូវ ឬ ការសរសេរខុសខ្វង់ ជាដើមនោះ ក្រឡាបញ្ជីអាចឲ្យខាងសុរិយោដីធ្វើការកែតម្រូវឯកសារនោះ ឲ្យបានត្រឹមត្រូវឡើងវិញ ហើយក្រោយពីសុរិយោដីធ្វើការកែប្រែ រួចត្រូវបញ្ជូនឯកសារត្រឹមត្រូវនោះត្រឡប់ទៅក្រឡាបញ្ជីវិញ[77]។

ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ពុំត្រូវរារាំងកូនបំណុលក្នុងការប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុតាមវិធីធម្មតាឡើយ[78]។ ដូច្នេះកូនបំណុលមិនត្រូវបានរារាំងពីការប្រើប្រាស់អចលនវត្ថុដែលមានវិវាទនោះឡើយ ហើយមិនចាំបាច់ចាក់ចេញឡើយ។ លើសពីនេះទៅទៀត ក្នុងករណីកូនបំណុលជួលអចលនវត្ថុនោះទៅឲ្យអ្នកផ្សេងមុនពេលអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ការជួលបន្តនៃអចលនវត្ថុនេះមិនប្រឆាំងនឹងអានុភាព នៃការរឹបជាបណ្តោះអាសន្នឡើយ។ ផ្ទុយទៅវិញ ការជួលសារជាថ្មីនៃអចលនវត្ថុដែលមានវិវាទទៅអ្នកដ៏ទៃ ក្រោយការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន មិនត្រូវចាត់ទុកជាការប្រើប្រាស់ធម្មតានោះទេ ហើយវាប្រឆាំង នឹងអានុភាពនៃការរឹបអូសជាបណ្តោះអាសន្ន ទោះបីជាកិច្ចសន្យាជួលរវាងកូនបំណុល និងអ្នកជួលមានសុពលភាពដ៏ដោយ ក៏កិច្ចសន្យាជួលនោះត្រូវចាត់ទុកថាមិនមានសុពលភាពទេក្នុងនីតិវិធី។

ដូច្នេះអ្នកជួលមិនអាចតតាំងនឹងម្ចាស់បំណុល អ្នកទិញអចលនវត្ថុនោះជាអាទិ៍ដោយប្រើសិទ្ធិជួល របស់ខ្លួនបានឡើយ។

[75] កថាខ័ណ្ឌទី ៥ ប្រការ ៣២ នៃប្រកាសអន្តរក្រសួងស្តីពី នីតិវិធីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី
[76] កថាខ័ណ្ឌទី ៤ មាត្រា ៥៦៧ និង កថាខ័ណ្ឌទី ២ មាត្រា ៥២០ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[77] កថាខ័ណ្ឌទី ៨ ប្រការ ៣៩ នៃប្រកាសអន្តរក្រសួងស្តីពី នីតិវិធីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី
[78] កថាខ័ណ្ឌទី ៤ មាត្រា ៥៦៧ និង កថាខ័ណ្ឌទី ៣ វាក្យខ័ណ្ឌ ១ មាត្រា ៥២១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

### ៣.៣.២ ការអនុវត្តចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី

អចលនវត្ថុដែលមិនទាន់បានចុះបញ្ជីសំដៅទៅលើ ដី ឬចំណែកឯកជននៃអាគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី។ ម្យ៉ាងទៀតយើងអាចនិយាយបានថា អចលនវត្ថុដែលមិនទាន់បានចុះបញ្ជី គឺជាអចនលវត្ថុទាំងឡាយណា ដែលម្ចាស់នៃអចនលវត្ថុនោះមានត្រឹមតែ វិញ្ញាបនប័ត្រសម្គាល់ការកាន់កាប់អចលនវត្ថុ(ប្លង់ទន់)។ នៅត្រង់ចំណុចនេះច្បាស់ណាស់នឹងមានសំណួរសំខាន់មួយដែលត្រូវបានលើកឡើង ថាបើអចលនវត្ថុរបស់កូនបំណុលមិនបានចុះបញ្ជី ហើយតុលាការចេញដីកាសម្រេចបង្គាប់ឲ្យរឹបអូសជាបណ្ដោះអាសន្ន តើតុលាការត្រូវធ្វើដូចម្ដេច? ក្នុងករណីនេះក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឲ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីដីធ្លីនោះ ព្រមទាំងចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នផង។ នៅពេលដែលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់មានចុះបញ្ជី ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្ដាក់ឲ្យចុះបញ្ជីទៅស្ថាប័នមានសមត្ថកិច្ចឲ្យ ចាប់ផ្ដើមនីតិវិធីចុះបញ្ជីលើកដំបូង និងចុះបញ្ជីពីការរឹបអូសជាបណ្ដោះអាសន្នតាមទម្រង់ នឹង ខ្លឹមសារដូចខាងក្រោម៖

**ក.** កម្មវត្ថុ៖ ១/ចាប់ផ្ដើមនីតិវិធីចុះបញ្ជីអចលនវត្ថុលើកដំបូង

២/សរសេរខ្លឹមសារនៃការចុះបញ្ជីការរឹបអូសជាបណ្ដោះអាសន្ន

**ខ.** អត្តសញ្ញាណនៃអចលនវត្ថុ៖ ទីតាំងដី ទំហំដី លេខក្បាលដី នៃទីតាំងអគារសហកម្មសិទ្ធិឈ្មោះអគារសហកម្មសិទ្ធិ និងលេខប័ណ្ណ។

**គ.** កម្មសិទ្ធិករ ឬភោគនៃដីដែលត្រូវបានសន្មត៖ ឈ្មោះ និងអាស័យដ្ឋាន។

**ឃ.** គោលបំណងនៃការចុះបញ្ជី៖ ការរឹបអូសជាបណ្ដោះអាសន្ន

**ង.** មូលហេតុ៖ ដីកាសម្រេចឲ្យរឹបអូសជាបណ្ដោះអាសន្នលេខ.... ចុះថ្ងៃទី ខែ ឆ្នាំ។

**ច.** ចំពោះការរឹបអូសជាបណ្ដោះអាសន្ន សរសេរឈ្មោះ និងអាស័យដ្ឋានរបស់ម្ចាស់បំណុល

**ឆ.** ចំពោះការរឹបអូសជាបណ្ដោះអាសន្ន សរសេរឈ្មោះ និងអាស័យដ្ឋានរបស់កូនបំណុល

**ឯកសារភ្ជាប់មានដូចខាងក្រោម ៖**

- ឯកសារចម្លងថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន
- ឯកសារនៃសេចក្ដីបញ្ជាក់ដំបូងអំពីកម្មសិទ្ធិ ជាអាទិ៍របស់កូនបំណុលនៃការចាត់ចែងរក្សាការពារចំពោះអចលនវត្ថុដែឡមិនទាន់បានចុះបញ្ជី[79]។

[79] ប្រការ៦ នៃប្រកាសលេខ ២១៤ ប្រក.ដនស អន្តរក្រសួង ស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារនិងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនទានបានចុះបញ្ជី ចុះថ្ងៃទី ២១ ខែ វិច្ឆកា ឆ្នាំ២០១៤

បន្ទាប់ពីបានទទួលលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជី ដោយផ្អែកលើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី និងទទួលបានលិខិតអនុញ្ញាតឲ្យចាប់ផ្តើមនីតិវិធីនៃការចុះបញ្ជី លើកដំបូង រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខ័ណ្ឌ ត្រូវចាប់ផ្តើមការអនុវត្តនីតិវិធីចុះបញ្ជីដោយគ្មានការយឺតយ៉ាវ ដោយអនុវត្តតាមបទបញ្ញាតាមបទដ្ឋានគតិយុត្ត ទាក់ទង នឹងនីតិវិធីនៃការចុះបញ្ជីលើកដំបូងដែលមានជាធរមាន។ ឧទាហរណ៍៖ បើការចុះបញ្ជីលើក ដំបូងចំពោះដីធ្លីត្រូវអនុវត្តទៅតាមទដ្ឋានគតិយុត្តទាក់ទង នឹងនីតិវិធីនៃការចុះបញ្ជីដីធ្លី ឬបើការចុះ បញ្ជីលើកដំបូងចំពោះចំណែកឯកជននៃអគារសហកម្មសិទ្ធិត្រូវអនុវត្តតាមបទដ្ឋានគតិយុត្តិ នឹង នីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូងដែលនៅជាធរមាន។ ម្ចាស់ បំណុល ឬម្ចាស់បំណុលនៃការអនុវត្តជាអ្នកទទួលបន្ទុកនូវការចំណាយក្នុងការចុះបញ្ជីលើកដំបូង។

បន្ទាប់ពីបានចុះបញ្ជីអចលនវត្ថុលើកដំបូងរួចហើយ នោះរដ្ឋបាលសុរិយោដីថ្នាក់ រាជធានីខេត្តដែលអចលនវត្ថុនោះតាំងនៅត្រូវសរសេរនៅក្នុងខ្ទង់ត្រង់ "បន្ទុកលើអចលនវត្ថុ" អំពីការរឹបអូសជាបណ្តោះអាសន្នដោយគ្មានការយឺតយ៉ាវ។ របៀបចុះបញ្ជីបន្ទាប់អំពីការចុះបញ្ជីលើកដំបូងចំពោះការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានធ្វើឡើងដូចគ្នាចំពោះរបៀបចុះបញ្ជី ចំពោះការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ នៅក្នុងចំណុច ៣.៣.១.២នៃផ្នែកខាងលើ។

## ៣.៤ អានុភាពនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

តុលាការត្រូវបង្គាប់កូនបំណុលកុំឲ្យចាត់ចែងអចលនវត្ថុដែលមានវិវាទ តាមរយៈការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន មានន័យថា បើទោះបីជាកូនបំណុលក្រោយមកធ្វើទង្វើដូចជាការផ្ទេរអចលនវត្ថុដែលមានវិវាទ ឬ យកវាទៅដាក់ប្រាតិភោគ នោះកូនបំណុល ឬតតិយជនដែលបានទទួលផលប្រយោជន៍ ពីចេតនាទុច្ចរឹតរបស់កូនបំណុលមិនអាចតតាំងនឹងម្ចាស់បំណុលដោយអនុភាពនៃទង្វើរបស់ខ្លួនឡើយ។ ដូចបានបញ្ជាក់ខាងលើរួចហើយ នៅពេលដែលម្ចាស់បំណុល បានចាប់ផ្តើមនីតិវិធីអនុវត្តចំពោះអចលនវត្ថុហើយនោះ ទង្វើរបស់កូនបំណុលបែបនេះមិនត្រូវបានគេចាត់ទុកថាមានសុពលភាពទេ។

## ៣.៥ ការផ្អាកការអនុវត្តចំពោះការរឹបអូសជាបណ្តោះអាសន្ន

ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន អាចត្រូវបានផ្អាកក្នុងលក្ខណៈជាការផ្អាកការអនុវត្តដោយសារមានពាក្យសុំតវ៉ា ឬពាក្យទាមទារឲ្យលុបចោល នូវដីកាសម្រេចជាបណ្តោះអាសន្ន និងពាក្យបណ្តឹងជំទាស់ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ា ឬពាក្យសុំលុបចោលនោះ។ ការផ្អាកការអនុវត្តដោយសារមានការតវ៉ាចំពោះការអនុវត្ត និងដោយសារមានដាក់ពាក្យបណ្តឹងជំទាស់ការផ្អាកការអនុវត្តដោយសារមានបណ្តឹងតវ៉ារបស់តតិយជន ជាអាទិ៍។ ប៉ុន្តែយ៉ាងណាក៏ដោយ

វាខុសប្លែកពីការអនុវត្តដោយបង្ខំ ការផ្អាកនៅក្រោយអនុវត្ត មិនសូវមានអត្ថន័យទេព្រោះថា ការអនុវត្តរឹបអូសជាបណ្តោះអាសន្នត្រូវបានបញ្ចប់នៅត្រឹមដំណាក់កាលនៃការរឹបអូសតែប៉ុណ្ណោះ[80]។

## ៣.៦ ការលុបចោលប្រាតិភោគ

ប្រសិនបើម្ចាស់បំណុលនៃរឿងក្តីចាត់ចែងរក្សាការពារ ក៏ដូចជាការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ឈ្នះបណ្តឹងអង្គសេចក្តី ហើយសាលក្រមបានចូលជាស្ថាពរម្ចាស់បំណុលនោះអាចទទួលនូវប្រាតិភោគដែលគាត់បានដាក់ តាមរយៈសេចក្តីបង្គាប់របស់តុលាការនោះអាចយកត្រឡប់មកវិញបាន។ ម្ចាស់បំណុលត្រូវដាក់ពាក្យសុំលុបចោលប្រាតិភោគ ដោយធ្វើការបញ្ជាក់នូវការរលត់នៃហេតុដែលត្រូវដាក់ប្រាតិភោគ ដើម្បីទទួលនូវប្រាតិភោគនោះត្រឡប់។

ឧទាហរណ៍៖ សាលក្រម និង សេចក្តីបញ្ជាក់ថា សាលក្រមនោះបានចូលជាស្ថាពរ។ ក្នុងករណីដែលតុលាការទទួលស្គាល់ថា មូលហេតុនៃការដាក់ប្រាតិភោគបានរលត់ តុលាការត្រូវចេញដីកាសម្រេចលុបចោលប្រាតិភោគនោះ។ ម្ចាស់បំណុលអាចទទួលប្រាតិភោគ ត្រឡប់មកវិញបានដោយផ្អែកលើដីកាសម្រេចលុបចោលប្រាតិភោគ។

[80] កថាភាគទី៥ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចំណុច ៣ ការផ្អាក និងការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ទំព័រ ២០៦ នៃសេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ

# ជំពូកទី៤ បណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យ ជាបណ្តឹងតវ៉ារបស់ភាគីដែលពុំយល់ព្រម ជាមួយសេចក្តីសម្រេចណាមួយ (សាលក្រម សាលដីកា ដីកាសម្រេច) របស់ចៅក្រម ឬតុលាការ ក្នុងគោលបំណងដើម្បីទាមទារឲ្យលុបចោល ឬផ្លាស់ប្តូរ សេចក្តីសម្រេចដើម[81]។ បណ្តឹឧបាស្រ័យ គឺជាបណ្តឹងទៅតុលាការជាន់ខ្ពស់ ហើយជានីតិវិធីមួយ ដែលចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។ ហេតុនេះយើង អាចនិយាយបានថាបើសេចក្តីសម្រេចនោះចូលជាស្ថាពរ គឺមិនអាចធ្វើបណ្តឹងឧបាស្រ័យបានទេ មិនមែនមានន័យថា មិនអាចធ្វើបណ្តឹងទៅតុលាការជាន់ខ្ពស់នោះទេ គឺអាចធ្វើបានដោយប្រើបណ្តឹងផ្សេងៗទៀត ក្រៅពីបណ្តឹងឧបាស្រ័យ ដែលមានបណ្តឹងទាមទារឲ្យជំនុំជម្រះសារជាថ្មី[82] ហើយចំពោះអានុភាពនៃបណ្តឹងឧបាស្រ័យ គឺបានបង្អាក់នូវការចូលជាស្ថាពររបស់សេចក្តីសម្រេចដើម គឺត្រូវរងចាំនៅនីតិវធីនៃបណ្តឹងឧបាស្រ័យចប់សិន[83]។

រីឯអត្ថន័យនៃការប្រើប្រាស់បណ្តឹងឧបាស្រ័យ សំដៅទៅលើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺអាស្រ័យចំពោះការសម្រេចដែលមិនទាន់ចូលជាស្ថាពរ[84]។ ចំពោះសាលក្រមសាលដីកា ឬដីកាសម្រេច ទាំងអស់នេះមិនមានលក្ខណៈដូចគ្នា ប៉ុន្តែវាជាកាសម្រេចសេចក្តី ដោយប្រព័ន្ធយុត្តាធិកា។ សាលក្រម គឺជាការសម្រេចសចក្តី ដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកលើការទាយហេតុផលដោយផ្ទាល់មាត់ លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសនៅក្នុងក្រមនេះ ឬនៅក្នុងច្បាប់ផ្សេងហើយកើតអានុភាព ដោយការប្រកាស ដោយផ្អែកលើលិខិតសាលក្រមនោះ[85] និងធ្វើឡើងដោយតុលាការជាន់ទាប។ សាលដីកា ជាសេចក្តីសម្រេចរបស់សាលាជម្រះក្តីជាន់ខ្ពស់មានសាលាឧទ្ធរណ៍ និងតុលាការកំពូល[86] ដែលតុលាការធ្វើលិខិតមានលក្ខណៈគ្រប់គ្រាន់ ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកលើការទាយហេតុផលដោយផ្ទាល់មាត់ ហើយកើតមានអានុភាពដោយការប្រកាស ដោយផ្អែកលើលិខិតសាលដីកា។ ចំពោះដីកាសម្រេច គឺជាការសម្រេចសេចក្តីដែលតុលាការ ឬចៅក្រមអាចធ្វើដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន

[81] វចនានុក្រមច្បាប់ របស់លោក ហ៊ី ធីឫទ្ធិ បោះពុម្ពលើកទី៣ ឆ្នាំ ២០១០ ស្នាដៃនិពន្ធទី៦
[82] មាត្រា.៣០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[83] មាត្រា.១៩៣. កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[84] មាត្រា.២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[85] មាត្រា. ១៧៩.កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[86] វចនានុក្រមច្បាប់ របស់លោក ហ៊ី ធីឫទ្ធិ បោះពុម្ពលើកទី៣ ឆ្នាំ ២០១០ ស្នាដៃនិពន្ធទី៦

ហើយមិនមែនជាសាលក្រម[87]។ បណ្តឹងចំពោះដីកាសម្រេច ត្រូវបានធ្វើឡើងដោយការដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេច និង ការទាមទារឲ្យលុបចោល ឬផ្លាស់ប្តូរនូវដីកាស្រេចដើម។

## ៤.១. ពាក្យសុំតវ៉ាចំពោះការរឹបអូសជាបណ្តោះអាសន្នលើអចលវត្ថុ

### ៤.១.១. ការដាក់ពាក្យសុំតវ៉ា

ចំពោះដីកាសម្រេចរក្សាការពារ មិនអាចប្តឹងជំទាស់ភ្លាមបានទេ ប៉ុន្តែកូនបំណុលអាចដាក់ពាក្យសុំតវ៉ា ចំពោះដីកាសម្រេចរក្សាការពារទៅតុលាការ ដែលបានចេញដីកាសម្រេចនោះបាន[88]។ ការតវ៉ា គឺជាវិធីឧបាស្រ័យមួយប្រភេទទៅតុលាការនៃថ្នាក់ដដែល ហើយអាចធ្វើនៅពេលណាក៏បាន ឲ្យតែមានផលប្រយោជន៍ក្នុងការតវ៉ា។

ការដាក់ពាក្យសុំតវ៉ា គឺជាឱកាសដែលផ្តល់ឲ្យកូនបំណុលដែលពុំមានឱកាសចូលរួមនៅក្នុងនីតិវិធីជាមុន ក្នុងការសុំឲ្យមានការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មិនមែនដោយតុលាការជាន់ខ្ពស់ទេ តែដោយតុលាការថ្នាក់ដដែល ដែលចំណុចនេះស្រដៀងគ្នាទៅនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿននៅក្នុងនីតិវិធីនៃការដាស់តឿនដែរ[89]។ ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់ លុបចោលដីកាសម្រេចលើកចោលពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ហើយចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នពាក្យសុំតវ៉ាចំពោះដីកាសម្រេចនេះ ត្រូវដាក់ទៅតុលាការនៃបណ្តឹងជំទាស់នោះដែរ។

### ៤.១.២. លក្ខខណ្ឌនៃពាក្យសុំតវ៉ា

ពាក្យសុំតវ៉ា ត្រូវធ្វើជាលាយលក្ខណ៍អក្សចំពោះការរក្សាការពារ[90]។ ដោយពុំមានការកំណត់អំឡុងពេល ពាក្យសុំតវ៉ាអាចដាក់នៅពេលណាក៏បាន ឲ្យតែដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននៅមានសុពលភាព។ ការដាក់ពាក្យសុំតវ៉ា មិនធ្វើឲ្យអានុភាពអនុវត្តនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ផ្អាកដោយស្វ័យប្រវត្តិទេ គឺត្រូវមានសេចក្តីសម្រេចបណ្តោះអាសន្នដោយឡែកដែលបង្គាប់ឲ្យផ្អាកការអនុវត្តរក្សាការពារ ឬលុបចោលការចាត់ចែងការអនុវត្ត[91]។ សេចក្តីសម្រេចបណ្តោះអាសន្ននេះ អាចធ្វើបានតែក្នុងករណី ដែលមានសេចក្តីបញ្ជាក់ដំបូងអំពីស្ថានភាព ដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និងអំពីការដែលមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារការអនុវត្តការរក្សាការពារនោះ

[87] មាត្រា.១៧៩.កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[88] មាត្រា.៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[89] មាត្រា. ៣២៧ និង មាត្រា.៣២៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[90] មាត្រា.៥៣៩.ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[91] មាត្រា.៥៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ប៉ុណ្ណោះ ហើយម្យ៉ាងទៀត ការដាក់ប្រាតិភោគមានភាពចាំបាច់ជានិច្ច[92]។ ស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ សំដៅទៅលើស្ថានភាពដែលផ្ទុយយ៉ាងច្បាស់លាស់ នឹងអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការចាត់ចែងរក្សាការពារ ដែលជាល័ក្ខខ័ណ្ឌចាំបាច់ សម្រាប់ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន (ឧទាហរណ៍ មានភាពមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែតនៅក្នុងការទទួលស្គាល់ ឬនៅក្នុងការបកស្រាយច្បាប់)។ ដោយឡែក ការបារម្ភថាការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារការអនុវត្តការរក្សាការពារ សំដៅទៅលើករណីដែលសំណងជាប្រាក់ តាមក្រោយទំនងនឹងមិនអាចសងគ្រប់ចំពោះការខូចខាតរបស់កូនបំណុលបានឡើយ (ឧទាហរណ៍ ករណីដែលកូនបំណុលនឹងធនក្ស័យ ឬមិនអាចរស់បានដោយសារការអនុវត្តការរឹបអូសជាណ្ដោះអាសន្ននូវប្រាក់បញ្ញើនៅធនាគាររបស់កូនបំណុលជាអាទិ៍)។

**៤.១.៣ ការវិនិច្ឆ័យអំពីការពាក្យសុំតវ៉ា**

នៅក្នុងការវិនិច្ឆ័យអំពីការតវ៉ា តុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬធ្វើការសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន[93]។ គោលបំណងនៃការកំណត់បែបនេះគឺដើម្បីផ្ដល់ទៅឲ្យភាគី (ជាពិសេសកូនបំណុល) នូវការធានានៅក្នុងការចូលរួមក្នុងនីតិវិធី។ ប៉ុន្តែយ៉ាងណាក៏ដោយ វាមិនចាំបាច់ទាល់តែថា នៅក្នុងកាលបរិច្ឆេទទាំងអស់ ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬការសួរដែលភាគីទាំងសងខាងអាចចូលរួមបាននោះទេ គឺគ្រាន់តែធានាឲ្យបាននូវកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួម តែម្ដងក៏ជាការគ្រប់គ្រាន់ដែរ។ ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ា ជាគោលការណ៍តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ[94]។ ទោះបីជាទូទៅ នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេចតុលាការអាចបញ្ចប់ការវិនិច្ឆ័យរបស់ខ្លួននៅពេលណាក៏បាន ក៏ដោយ ក៏នៅក្នុងនីតិវិធីនៃការវិនិច្ឆ័យអំពីការតវ៉ានេះ តុលាការត្រូវជូនដំណឹងទៅភាគី អំពីកាលបរិច្ឆេទនៃការបញ្ចប់ការវិនិច្ឆ័យ ដើម្បីផ្ដល់ឱកាសឲ្យភាគី ក្នុងការដាក់ឯកសារសម្រាប់ការវិនិច្ឆ័យ ទៅតុលាការ ឲ្យបានគ្រប់គ្រាន់។ ក៏ប៉ុន្តែប្រសិនបើការវិនិច្ឆ័យត្រូវបញ្ចប់នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទ នៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថាបញ្ចប់

[92] (ម.៥៥១.១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[93] មាត្រា.៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[94] មាត្រា.៥៥៣ វាក្យខណ្ឌទី.១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ការវិនិច្ឆ័យបាន ព្រោះថាការធានានៅក្នុងនីតិវិធីត្រូវបានផ្តល់ឲ្យគ្រប់គ្រាន់ហើយ គឺដូចគ្នាទៅនឹងនីតិវិធីបណ្តឹងដែរ[95]។

### ៤.១.៤ ដីកាសម្រេចអំពីពាក្យសុំតវ៉ា

នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ា តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬលុបចោលនូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។[96] ប្រសិនបើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មានភាពត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចទទួលស្គាល់ដីសម្រេចនោះ។ រីឯតុលាការត្រូវចេញដីកាសម្រេចផ្លាស់ប្តូរ ប្រសិនបើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មានផ្ទុកនូវចំណុចដែលត្រូវធ្វើការផ្លាស់ប្តូរ។ ករណីនេះ រួមបញ្ចូលករណីដូចជាល័ក្ខខ័ណ្ឌដែលម្ចាស់បំណុលត្រូវដាក់ប្រាតិភោគ ឬការបន្ថែមនូវប្រាតិភោគ នៅក្នុងអំឡុងពេលកំណត់ណាមួយ ជាអាទិ៍។ តុលាការត្រូវចេញដីកាសម្រេចលុបចោលការរឹបអូសជាបណ្តោះអាសន្ន ប្រសិនបើដីកាសម្រេចនោះ មានភាពមិនត្រឹមត្រូវ ហើយនៅក្នុងករណីនេះ តុលាការអាចដាក់ល័ក្ខខ័ណ្ឌឲ្យកូនបំណុលដាក់ប្រាតិភោគបាន។[97] ដីកាសម្រេចនេះ មិនមានអានុភាព បើមិនទាន់ចូលជាស្ថាពទេ ក៏ប៉ុន្តែបើយល់ឃើញថាចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនោះ មានអានុភាពភ្លាមៗបាន[98]។ ដីកាសម្រេចទាំងនេះត្រូវបញ្ជូនទៅភាគី[99] ហើយបណ្តឹងជំទាស់អាចធ្វើបានចំពោះដីកាសម្រេចទាំងនេះ[100]។

## ៤.២. ការលុបចោលនៃដីកាសម្រេច

ក្រៅពីការលុបចោលដោយសារការតវ៉ា ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចត្រូវបានលុបចោលនៅក្នុងករណីពីរ ដែលមាននីតិវិធីដោយឡែកពីគ្នា តាមពាក្យសុំរបស់កូនបំណុលៈ ទី១ ការលុបចោលដោយសាការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ជាអាទិ៍ និង ទី២ ការលុបចោលដោយសារការផ្លាស់ប្តូរស្ថានភាព។

### ៤.២.១ ការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី

ការលុបចោលដោយសារការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ជាអាទិ៍ៈ តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបង្គាប់ឲ្យម្ចាស់បំណុល ដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយឲ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលដែល

---

[95] មាត្រា.៥៥៣.វាក្យខណ្ឌទី.២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[96] មាត្រា.៥៥៤.កថាខណ្ឌទី.១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[97] មាត្រា.៥៥៤.កថាខណ្ឌទី.២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[98] មាត្រា.៥៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[99] មាត្រា.៥៥៤ កថាខណ្ឌទី.៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[100] មាត្រា.៥៦១ កថាខណ្ឌទី.១ ចំណុច.ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល[101]។ ការបង្គាប់នេះ ហៅថា ការបង្គាប់ឲ្យដាក់ពាក្យបណ្តឹង។ គោលបំណងនៃការបង្គាប់នេះ គឺដើម្បីបង្ខំឲ្យម្ចាស់បំណុលទៅទទួលលិខិតអនុវត្តសម្រាប់ការអនុវត្តដោយបង្ខំចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ។ ការកំណត់បែបនេះ នឹងទប់ស្កាត់នូវការខូចខាតធ្ងន់ធ្ងរដែលអាចនឹងកើតមានដល់កូនបំណុល ដោយសារទុកស្ថានភាពដែលមានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឲ្យយូរអង្វែង។ ហេតុនេះហើយ ការបង្គាប់ឲ្យដាក់ពាក្យបណ្តឹង អាចចេញបានដោយពុំមានល័ក្ខខ័ណ្ឌទាមទារអ្វីទេ ប្រសិនបើមានពាក្យសុំរបស់កូនបំណុល។ ក្នុងអំឡុងពេលនៃការដាក់ពាក្យបណ្តឹងអង្គសេចក្តី មិនត្រូវតិចជាង២ សប្តាហ៍ទេ[102]។

ប្រសិនបើម្ចាស់បំណុល មិនដាក់ឯកសារបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីការដាក់ពាក្យបណ្តឹងអង្គសេចក្តីនៅក្នុងអំឡុងពេល ដែលបានកំណត់នៅក្នុងការបង្គាប់ឲ្យដាក់ពាក្យបណ្តឹងទេ តុលាការត្រូវលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តាមពាក្យសុំរបស់កូនបំណុល[103]។ ម្យ៉ាងទៀតប្រសិនបើនៅក្រោយពេលដាក់ឯកសារបញ្ជាក់នេះហើយ ពាក្យបណ្តឹងអង្គសេចក្តីត្រូវបានដកវិញ ឬត្រូវបានលើកចោល នោះត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយ ហើយហេតុការណ៍នេះ ក៏នឹងនាំទៅដល់ការចេញដីកាសម្រេចលុបចោលដែរ[104]។ ការចាប់ផ្តើមនីតិវិធីមជ្ឈត្តកម្ម ប្រសិនបើមានកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្តី[105] និងការចាប់ផ្តើមនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប្រសិនបើអង្គសេចក្តី គឺជារឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងក៏ត្រូវចាត់ទុកថាជាការដាក់ពាក្យបណ្តឹងអង្គសេចក្តីដែរ។ ដីកាសម្រេចលុបចោល ត្រូវបញ្ជូនទៅភាគី[106] ហើយបណ្តឹងជំទាស់អាចធ្វើបានចំពោះដីកាសម្រេចនេះ[107]។

### ៤.២.២. ការផ្លាស់ប្តូរស្ថានភាព

ការលុបចោលដោយសារការផ្លាស់ប្តូរស្ថានភាព៖ បើមានការរលត់សិទ្ធិដែលត្រូវបានរក្សាការពារ ឬភាពចាំបាច់ក្នុងការរក្សាការពារ ឬការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬតុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោល

[101] មាត្រា.៥៥៧.កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[102] មាត្រា.៥៥៧.កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[103] មាត្រា.៥៥៧.កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[104] មាត្រា.៥៥៧.កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[105] មាត្រា.៥៥៧.កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[106] មាត្រា.៥៥៧.កថាខណ្ឌទី៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[107] មាត្រា.៥៦១.កថាខណ្ឌទី១.ចំណុច.ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តាមពាក្យសុំរបស់កូនបំណុលបាន[108] ។ ការផ្លាស់ប្តូរស្ថានភាពនេះត្រូវបានបែងចែកជាពីរប្រភេទ៖

ប្រភេទទីមួយ គឺករណីដែលនៅក្រោយពេល ចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មានកើតឡើងនូវអង្គហេតុថ្មី ដែលធ្វើឲ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ មានភាពត្រឹមត្រូវ។ ឧទាហរណ៍៖ ករណីដែលសិទ្ធិទាមទារទាំងអស់ដែលត្រូវបានរក្សាការពារ ត្រូវបានសងគ្រប់ចំនួន, ករណីដែលមានសាលក្រមនៃការជំនុំជម្រះលើកទី១ សម្រេចឲ្យម្ចាស់បំណុលចាញ់ក្តី នៅក្នុងបណ្តឹងអង្គសេចក្តី, ករណីដែលកូនបំណុលក្លាយជាអ្នកមានទ្រព្យសម្បត្តិគ្រប់គ្រាន់ដើម្បីសង, ករណីដែលម្ចាស់បំណុលមិនធ្វើការអនុវត្តដោយបង្ខំ បើទោះជាបានបំពេញគ្រប់ល័ក្ខខ័ណ្ឌទាមទារដែលអាចអនុវត្តដោយបង្ខំបានហើយក៏ដោយជាអាទិ៍។

ប្រភេទទីពីរ គឺករណីដែលកូនបំណុលបានដឹងអំពីហេតុ ដែលនាំឲ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ មានភាពមិនត្រឹមត្រូវ ឬអាចធ្វើសេចក្តីបញ្ជាក់ដំបូងអំពីហេតុនោះ នៅក្រោយពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ទោះបីជាអង្គហេតុនោះបានកើតឡើងនៅពេលចេញដីកាសម្រេចរក្សាការពារក៏ដោយ។ នៅក្នុងករណីនេះ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការផ្លាស់ប្តូរស្ថានភាពនោះ[109]។ ឧទាហរណ៍៖ ករណីដែលសិទ្ធិដែលត្រូវបានរក្សាការពារបានរលត់ដោយសារកាសង និង ករណីដែលភាពចាំបាច់នៃការរក្សាការពារបានរលត់ ដោយសារស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលគ្រាន់បើឡើងវិញ។ ចំពោះការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឲ្យបង់ប្រាក់ជាបណ្តោះអាសន្ន មានករណីដែលភាពចាំបាច់នៃការរក្សាការពារបានរលត់ដោយសារស្ថានភាពទ្រព្យសម្បត្តិរបស់ម្ចាស់បំណុលគ្រាន់បើឡើងវិញ។

បញ្ញត្តិទាក់ទងនឹងការសម្រេចសេចក្តី អំពីការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្តីអំពីពាក្យសុំទាមទារឲ្យលុបចោល ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន[110]។ មានន័យថា បញ្ញត្តិស្តីពីការសម្រេចសេចក្តីអំពីការផ្អាក ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ជាអាទិ៍[111] ការទាញហេតុផលដោយផ្ទាល់មាត់ និងការសួរនៅកាលបរិច្ឆេទ ដែលភាគីទាំងសងខាងអាចចូលរួមបាន[112]ការបញ្ចប់ការវិនិច្ឆ័យ[113]និង

[108] មាត្រា.៥៥៨.កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[109] មាត្រា.៥៥៨.កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[110] មាត្រា.៥៦០.កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[111] មាត្រា.៥៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[112] មាត្រា.៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[113] មាត្រា.៥៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

អានុភាពនៃដីកាសម្រេចលុបចោលដីកាសម្រេចលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន[114] ត្រូវយកមកអនុវត្តដូចគ្នាដែរចំពោះការលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយសារការផ្លាស់ប្ដូរស្ថានភាព។ ដីកាសម្រេចលុបចោល អាចដាក់ល័ក្ខខ័ណ្ឌឲ្យកូនបំណុលដាក់ប្រាតិភោគបាន ហើយដីកាសម្រេចនេះ ត្រូវបញ្ជូនទៅភាគី[115] និងអាចបណ្ដឹងជំទាស់បាន[116]។

### ៤.២.៣. ការអស់សុពលភាពនៃដីកាសម្រេច

ដីកាសម្រេចរក្សាការពារ ធ្វើឡើងក្នុងគោលបំណងការពារសិទ្ធិរបស់ម្ចាស់បំណុល ជាបណ្ដោះអាសន្ន ដោយតុលាការមិនទាន់សម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិនោះ តាមវិធីនៃបណ្ដឹងឡើយ។ ប៉ុន្តែ វាក៏អាចប៉ះពាល់ដល់ផលប្រយោជន៍របស់កូនបំណុលផងដែរ ប្រសិនបើមានការអូសបន្លាយពេលវេលាមិនសមរម្យ ហេតុនេះហើយទើបមាត្រា ៥៥៧ នេះកំណត់ថា តុលាការត្រូវបង្គាប់ម្ចាស់បំណុលឲ្យដាក់ពាក្យបណ្ដឹងអង្គសេចក្ដី និងឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹង ដោយកំណត់អំឡុងពេលមិនតិចជាង២សប្ដាហ៍ តាមពាក្យសុំរបស់កូនបំណុល[117]។

## ៤.៣. អានុភាពនៃការលុបចោល

ការលុបចោល ត្រូវបានធ្វើឡើងដោយពាក្យសុំរបស់កូនបំណុលក្នុងការលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដែលការលុបចោលមានទំនាក់ទំនងទៅនឹងលិខិតផ្ទុកផ្ដាក់ឲ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ដោយផ្អែកលើកថាខណ្ឌទី៣ និងកថាខណ្ឌទី៤ មាត្រា ៥៦៧ នៃក្រមរដ្ឋប្បវេណី។ បើពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ បើពាក្យសុំអនុវត្តការរឹបអូសជាបណ្ដោះអាសន្នត្រូវបានដក ឬបើដីកាសម្រេចលុបចោល ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ន បានបង្កើតអានុភាព ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ច ឲ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននោះ[118]។

ទម្រង់នៃលិខិតផ្ទុកផ្ដាក់ត្រូវបានសរសេរនូវចំណុចមួយចំនួនទៅតាមប្រភេទនៃលិខិតផ្ទុកផ្ដាក់ដូចខាងក្រោមនេះ៖

កម្មវត្ថុ: ..............................................(សរសេរអំពីខ្លឹមសារផ្ទុកផ្ដាក់ឲ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន.........................)

---

[114] មាត្រា. ៥៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[115] មាត្រា.៥៥៨.កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[116] មាត្រា.៥៦១.កថាខណ្ឌទី១.ចំណុច.ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[117] មាត្រា.៥៥៧.កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[118] ទំព័រទី ២០ ប្រការ ១៧ ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១

ក. អត្តសញ្ញានៃអចលនវត្ថុ...............................(លេខក្បាលដី ឬលេខប័ណ្ណនិងទីតាំងដី)

ខ. ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគី នៃអចលនវត្ថុ......... (អាសយដ្ឋាន........................)

គ. គោលបំណងនៃការចុះបញ្ជី (ការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននូវកម្មសិទ្ធិ សិទ្ធិជួលអចន្ត្រៃយ៍ ឬផលុបភោគទៅលើអចលនវត្ថុ ចំណុច "ក" )

ឃ. មូលហេតុ................ (ការដកពាក្យសុំដីការរឹបអូសជាបណ្តោះអាសន្ន ឬការដកពាក្យសុំអនុវត្តរឹបអូសជាបណ្តោះអាសន្នលេខ...... ចុះថ្ងៃទី........ខែ.......ឆ្នាំ........ហើយថ្ងៃទី.........ខែ..... ឆ្នាំ....... ដែលមានអានុភាព និងឈ្មោះរបស់តុលាការ...............)

ង. ឈ្មោះម្ចាស់បំណុល...............................(អាសយដ្ឋាន......................................)

ច. ឈ្មោះកូនបំណុល.................................(អាសយដ្ឋាន.....................................)

ដូច្នេះ ការលុបចោលត្រូវបានភ្ជាប់នូវឯកសារមួយចំនួនដូចខាងក្រោម ដើម្បីឲ្យការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ពុំមានអានុភាពក្នុងការអនុវត្តបន្តទៀត។

### ៤.៣.១ ពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម។ ការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូត នៃកំណាត់ហេតុនៃការដកពាក្យសុំនោះ។[119]

### ៤.៣.២ ពាក្យសុំអនុវត្តការរឹបអូសជាបណ្តោះអាសន្នត្រូវបានដក

នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតដកពាក្យសុំនោះ ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម។ ការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃកំណាត់ហេតុនៃការដកពាក្យសុំនោះ។[120]

119 ទំព័រទី ២១ ប្រការ ១៧ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១

120 ទំព័រទី២១ ប្រការ ១៧ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១

### ៤.៣.៣ ដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុត្រូវបានធ្វើឡើងដោយគោរពនូវចំណុចមួយចំនួនដូចជាៈ

ក. ការលុបចោលដោយផ្អែកលើមាត្រា ៥៦៩ (ការលុបចចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដោយធ្វើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន[121]។

ខ. ក្នុងករណីដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបានលុបចោលផ្អែកលើមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) មាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ជាអាទិ៍) មាត្រា ៥៥៨ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារការផ្លាស់ប្តូរស្ថានភាព) និងមាត្រា ៥៦១ (បណ្តឹងជំទាស់) ហើយតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិ នៃគន្ថីទី៦) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី១ ចំណុច "ក" ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។

គ. ការលុបចោលដោយផ្អែកលើមាត្រា ៥៥១(ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) មាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី៦) និងចំណុច "ឆ" កថាខណ្ឌទី១ នៃមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តរឹបអូសជាបណ្តោះអាសន្ន។

ឃ. ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិ នៃគន្ថីទី៦) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី១ ចំណុច "ង" (ឯកសារចម្លងយថាភូតនៃកំណត់ហេតុសៈជា ដែលមានខ្លឹមសារថា មិនអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ឬក៏ដកពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នឬដកពាក្យសុំអនុវត្តការរឹបអូសជាបណ្តោះអាសន្ន) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។

ង. ការលុបចោលដោយផ្អែកលើមាត្រា ៥៦៥ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី៦) មាត្រា ៣៦៤ (បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត) មាត្រា ៣៦៧ (ការសម្រេចសេចក្តី ផ្អាកការ

[121] ទំព័រទី២២ ប្រការ ១៧ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១

អនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) មាត្រា ៣៦៨ (ការសម្រេចសេចក្តីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬសាលដីកាចុងក្រោយ ជាអាទិ៍) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី១ ចំណុច "ឆ" ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន យោងតាមកថាខណ្ឌទី២ នៃមាត្រា ៣៦៧ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរតាមមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី៦) ឬអនុសារសាលក្រមចុងក្រោយនៃបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តដែលបង្គាប់ឲ្យលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ការចាត់ចែងការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។

ច. ការលុបចោលដោយផ្អែកលើមាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិ នៃគន្ថីទី៦) មាត្រា ៣៦៥ (បណ្តឹងតវ៉ារបស់តតិយជន) មាត្រា ៣៦៧ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) មាត្រា ៣៦៨ (ការសម្រេចសេក្តីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬសាលដីកាចុងក្រោយ ជាអាទិ៍) និងមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ) កថាខណ្ឌទី១ ចំណុច "ឆ" ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន យោងកថាខណ្ឌទី២ នៃមាត្រា ៣៦៧ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ា ចំពោះការទាមទារ ជាអាទិ៍) ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរតាម មាត្រា ៥៦៤ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិនៃគន្ថីទី៦) ឬអនុសារសាលក្រមចុងចក្រោយនៃបណ្តឹងតវ៉ារបស់តតិយជន ដែលបង្គាប់ឲ្យលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។

ឆ. ការលុបចោលដោយផ្អែកលើកថាខណ្ឌទី៤ នៃមាត្រា ៥៦៧ (ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ) មាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។

ជ. ការលុបចោលដោយផ្អែកលើកថាខណ្ឌទី៣ នៃមាត្រា ៥៣៧ (សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍) ក្រឡាបញ្ជីត្រូវភ្ជាប់ឯកសារចម្លងយថាភូត នៃដីកាសម្រេចលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន[122]។

[122] ទំព័រទី ២៣ ប្រការ ១៧ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១

### ៤.៣.៤ នីតិវិធីការលុបការចុះបញ្ជី

ការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើក្នុងសៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ និងសៀវភៅចុះបញ្ជីផលុបភោគ។ នៅពេលរដ្ឋបាលសុរិយោដី ទទួលបានលិខិតផ្ទុកផ្តាក់ដែលបានកំណត់ផ្នែកខាងលើ (អានុភាពនៃការលុបចោល) ដោយផ្អែក លើកថាខណ្ឌទី៣ ទី៤នៃមាត្រា ៥៦៧ និងមាត្រា ៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺត្រូវចុះបញ្ជីអំពី ការលុបចោលទៅតាមប្រភេទនៃការលុបអំពីការរឹបអូសជាបណ្តោះអាសន្ន[123]៖

ក. ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នកម្មសិទ្ធិ ឬ ការលុបការរឹបអូសជាបណ្តោះអាសន្នចំណែកកម្មសិទ្ធិអវិភាគ ត្រូវសរសេក្នុង សៀវភៅគោលបញ្ជីដី ធ្លី នៅក្នុងខ្ទង់ ត្រង់ បន្ទុកលើអចលនវត្ថុ ដូចគ្នានឹងការចុះបញ្ជីអំពី ការរឹបអូសជាបណ្តោះអាសន្នកម្ម សិទ្ធិ ឬចំណែកកម្មសិទ្ធិអវិភាគ ដោយត្រូវសរសេថា៖

ត្រូវបានលុបការរឹបអូសជាបណ្តោះអាសន្ន............. ដែលតុលាការ...........បានចេញដីកា សម្រេចលេខ..........ចុះថ្ងៃទី..........ខែ.............ឆ្នាំ............. តាមដីកាសម្រេចលុបចោលលេខ....... ចុះថ្ងៃទី.........ខែ.........ឆ្នាំ........របស់តុលាការ.............លរ..... ឬការដកពាក្យសុំដីការរឹបអូសជា បណ្តោះអាសន្ន ឬការដកពាក្យសុំអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ចុះថ្ងៃទី........ខែ.....ឆ្នា.......... (ជាទឹកខៀវ ឬខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី(ជាទឹកក្រហម)។

ខ. ចំពោះការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពី ការរឹបអូសជាបណ្តោះអាសន្នសិទ្ធិជួល អចិន្ត្រៃយ៍ ឬការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ដែល ជាសិទ្ធិរួម ត្រូវសរសេក្នុង សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ នៅក្នុងខ្ទង់ ត្រង់ បន្ទុកលើអចលន វត្ថុ ដូចគ្នានឹងការចុះបញ្ជីអំពី ការរឹបអូសជាបណ្តោះអាសន្នសិទ្ធិជួលអចិន្ត្រៃយ៍ ឬចំណែកសិទ្ធីជួល អចិន្ត្រៃយ៍ ឬចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ដោយត្រូវសរសេថា៖

ត្រូវបានលុបការរឹបអូសជាបណ្តោះអាសន្ន............. ដែលតុលាការ...........បានចេញដីកា សម្រេចលេខ............ចុះថ្ងៃទី..........ខែ.............ឆ្នាំ............តាមដីកាសម្រេចលុបចោលលេខ.......... ចុះថ្ងៃទី........ខែ..........ឆ្នាំ...........របស់តុលាការ............លរ.......... ឬការដកពាក្យសុំដីការរឹបអូសជា បណ្តោះអាសន្ន ឬការដកពាក្យសុំអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ចុះថ្ងៃទី........ខែ........ឆ្នាំ....... (ជាទឹកខៀវ ឬខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី(ជាទឹកក្រហម)។

[123] ទំព័រទី ៦២ ប្រកាស ៣៣ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១

គ. ចំពោះការចុះបញ្ជីអំពីការលុបចោលការចុះបញ្ជីអំពី ការរឹបអូសជាបណ្តោះអាសន្នផលុបភោគ ឬការលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំណែកផលុបភោគ ដែលជាសិទ្ធិរួម ត្រូវសរសេក្នុង សៀវភៅចុះបញ្ជីផលុបភោគ នៅក្នុងខ្ទង់ត្រង់ បន្ទុកលើអចលនវត្ថុ ដូចគ្នានឹង ការចុះបញ្ជីអំពី ការរឹបអូសជាបណ្តោះអាសន្នផលុបភោគ ឬចំណែកផលុបភោគ ដោយត្រូវសរសេថាៈ

ត្រូវបានលុបការរឹបអូសជាបណ្តោះអាសន្ន............ ដែលតុលាការ..........បានចេញដីកាសម្រេចលេខ........ចុះថ្ងៃទី......ខែ..........ឆ្នាំ............ តាមដីកាសម្រេចលុបចោលលេខ.................. ចុះថ្ងៃទី.........ខែ..........ឆ្នាំ.............របស់តុលាការ...........លរ.......... ឬការដកពាក្យសុំដីការឹបអូសជាបណ្តោះអាសន្ន ឬការដកពាក្យសុំអនុវត្តការរឹបអូសជាបណ្តោះអាសន្នចុះថ្ងៃទី.......ខែ....ឆ្នាំ....... ជាទឹកខៀវ ឬខ្មៅ រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី(ជាទឹកក្រហម)[124]។

## ៤.៤. បណ្តឹងជំទាស់

បណ្តឹងជំទាស់ គឺជាវិធីឧបាស្រ័យមួយប្រភេទទៅតុលាការជាន់ខ្ពស់។ បណ្តឹងប្រភេទនេះ អាចធ្វើទៅបាន លុះត្រាតែក្នុងករណីដែលការចាត់ចែងការអនុវត្ត ត្រូវបានធ្វើឡើងដោយតុលាការអនុវត្ត មិនមែនដោយអាជ្ញាសាលានោះទេ។

ដីកាសម្រេចរក្សាការពារមិនអាចប្តឹងជំទាស់បានទេ ប៉ុន្តែចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬពាក្យសុំទាមទារឲ្យលុបចោលដីកាសម្រេចរក្សាការពារអាចប្តឹងជំទាស់បាន[125]។ បន្ទាប់ពីតុលាការបានសម្រេចទៅលើដីកាសម្រេចខាងលើនេះ ប្រសិនបើភាគីណាមួយមិនពេញចិត្តទៅនឹងសេចក្តីសម្រេចនោះ គឺភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធអាចប្តឹងជំទាស់បាន។

ចំពោះសេចក្តីសម្រេចដែលលើចោលពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារម្ចាស់បំណុលអាចប្តឹងជំទាស់បានក្នុអំឡុងពេល ២(ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង ហើយអំឡុងពេលដែលបានកំណត់ ២សប្តាហ៍មិនអាចពន្យារបានឡើយ[126]។

### ៤.៤.១. របៀបប្តឹងជំទាស់

បុគ្គលដែលមានសិទ្ធិក្នុងការដាក់បណ្តឹងជំទាស់បាន គឺបុគ្គលដែលទទួលរងការប៉ះពាល់ដោយសារដីកាសម្រេច ដោយរួមមានម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត និងអាច

[124] ទំព័រទី៦៣ ប្រកាស ៣៣ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១

[125] មាត្រា.៥៦១.កថាខណ្ឌទី១.ចំណុច.ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[126] មាត្រា.៥៤៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ជាតតិយជនផងដែរ។ ដើម្បីអាចប្ដឹងជំទាស់បាន ភាគីដែលមានគោលបំណងប្ដឹង ត្រូវដាក់ពាក្យបណ្ដឹងជំទាស់ជាលក្ខណ៍អក្សរទៅតុលាការដើម។ នៅក្នុងករណីនេះ តុលាការដើមត្រូវធ្វើឲ្យបានឆាប់រហ័ស នូវពាក្យបណ្ដឹងជំទាស់ និងសំណុំរឿងទៅតុលាការនៃបណ្ដឹងជំទាស់[127]។ ក្នុងករណីដែលពុំបានសរសេរច្បាស់លាស់ អំពីមូលហេតុនៃការទាមទារឲ្យលុបចោល ឬផ្លាស់ប្ដូរដីកាសម្រេចដើម ក្នុងពាក្យបណ្ដឹងជំទាស់ទេ ម្ចាស់បណ្ដឹងជំទាស់គប្បីដាក់លិខិតជាលាយលក្ខណ៍អក្សរដែលសរសេរអំពីចំណុចទៅតុលាការនៃបណ្ដឹងជំទាស់ នៅក្នុងអំឡុងពេល ២ សប្ដាហ៍គិតចាប់តាំងពីថ្ងៃដែលបានដាក់ពាក្យបណ្ដឹងជំទាស់នោះ[128]។

ភាគីដែលមានសិទ្ធិក្នុងការប្ដឹងជំទាស់ ទៅលើសេចក្ដីសម្រេចរបស់តុលាការមានដូចជា៖ ម្ចាស់បំណុល កូនបំណុល ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិ។ នៅក្នុងពាក្យបណ្ដឹងជំទាស់ ភាគីត្រូវសរសេរឲ្យបានច្បាស់លាស់ អំពីមូលហេតុនៃការទាមទារឲ្យតុលាការធ្វើការផ្លាស់ប្ដូរ ឬលុបចោល នូវដីកាសម្រេចដើម។ តុលាការដែលមានសមត្ថកិច្ចទៅលើការប្ដឹងជំទាស់នេះគឺ សាលាឧទ្ធរណ៍។ ម្យ៉ាងទៀត រយៈពេលដែលអាចដាក់ប្ដឹងជំទាស់បាន គឺស្ថិតក្នុងអំឡុង ២ សប្ដាហ៍[129]។

#### ៤.៤.២. ការសម្រេចសេចក្ដី

នៅពេលដែលតុលាការបានទទួលពាក្យប្ដឹងជំទាស់របស់ភាគី ហើយតុលាការបានធ្វើការទាយហេតុផលដោយផ្ទាល់មាត់រួចមក តុលាការបានធ្វើការសម្រេចសេចក្ដី។ បណ្ដឹងជំទាស់នោះគឺប្ដឹងជំទាស់លើដីកាសម្រេចលើកចោលពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងរក្សាការពារ និងដីកាសម្រេចអំពីពាក្យសុំទាមទារឲ្យលុបចោលដីកាសម្រេចរក្សាការពារ។

ការសម្រេចសេចក្ដីលើបណ្ដឹងជំទាស់ ចំពោះដីកាសម្រេចលើកចោលពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ គឺអាចស្ដែងឡើងក្នុងទិដ្ឋភាពនៃដីកាសម្រេចពីប្រភេទគឺ៖

- ដីកាសម្រេចរក្សាទុកដីកាសម្រេចដើម
- ដីកាសម្រេចលុបចោលដីកាសម្រេចដើម(ចេញដីកាសម្រេចរក្សាការពារថ្មី)។

[127] មាត្រា.៣០១.កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[128] មាត្រា.៣០១.កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[129] មាត្រា.៥៦១.កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ករណីតុលាការនៃបណ្ដឹងជំទាស់ចេញដីកាសម្រេចរក្សាទុកដីកាសម្រេចដើម គឺភាគីមិនប្ដឹងជំទាស់បានតទៅទៀតទេ[130]។ ប៉ុន្តែ បើតុលាការនៃបណ្ដឹងជំទាស់ចេញដីកាសម្រេចលុបចោលលើដីកាសម្រេចនោះបាន។ ម៉្យាងទៀត ការសម្រេចសេចក្ដីអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេច គឺតុលាការជាន់ខ្ពស់ត្រូវទទួលស្គាល់ ផ្លាស់ប្ដូរ ឬលុបចោលនូវដីកាសម្រេចដើម ហើយសេចក្ដីសម្រេចនេះភាគីមិនអាចប្ដឹងជំទាស់បានតទៅទៀតនោះទេ។

ការសម្រេចសេចក្ដីលើបណ្ដឹងជំទាស់ ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ាដីកាសម្រេចរក្សាការពារអាចស្ដែងឡើងក្នុងទិដ្ឋភាពនៃដីកាសម្រេចពីរប្រភេទគឺៈ

- ដីកាសម្រេចរក្សាទុកដីកាសម្រេចដើម
- ដីកាសម្រេចលុបចោលដីកាសម្រេចដើម

ការសម្រេចលើពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ដែលទទួលស្គាល់ដីកាសម្រេចដើមរបស់តុលាការនៃបណ្ដឹងជំទាស់ គឺភាគីមិនអាចប្ដឹងជំទាស់ទៀតឡើយ[131]។ ទោះបីជាតុលាការនៃបណ្ដឹងជំទាស់រក្សាទុក ឬលុបចោលនូវដីកាសម្រេចដើមក៏ដោយ។ ផ្ទុយទៅវិញ ការសម្រេចសេចក្ដីលើពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារដែលលុបចោលដីកាសម្រេចនោះគឺតុលាការនៃបណ្ដឹងជំទាស់ចេញនូវៈ ដីកាសម្រេចរក្សាតម្កល់ទុកដីកាសម្រេចដើម និងដីកាសម្រេចលុបចោលដីកាសម្រេចដើម។ ករណីតុលាការចេញដីកាសម្រេចរក្សាតម្កល់ទុកដីកាសម្រេចដើម គឺភាគីមិនអាចប្ដឹងជំទាស់បាននោះទេ[132]។ លើកលែងតែករណី តុលាការចេញដីកាសម្រេចលុបចោលដីកាសម្រេចដើម ហើយចេញដីកាសម្រេចថ្មី គឺភាគីដែលមិនសុខចិត្តអាចដាក់ពាក្យសុំតវ៉ា ចំពោះដីកាសម្រេចនោះបាន[133]។ ម្យ៉ាងវិញទៀត ការសម្រេចសេចក្ដីលើពាក្យសុំតវ៉ាចំពោះដីកាសម្រេចក្រោយនេះ គឺភាគីមិនអាចប្ដឹងជំទាស់បានទៀតនោះទេ[134]។ ទោះបីជា តុលាការចេញដីកាសម្រេចទទួលស្គាល់ ឬលុបចោលដីកាសម្រេចនោះវិញក៏ដោយ។

មួយវិញទៀត បណ្ដឹងចំទាស់ចំពោះដីកាសម្រេចអំពីពាក្យសុំទាមទារឲ្យលុបចោលដីកាសម្រេចរក្សាការពារ គឺការសម្រេចសេចក្ដីរបស់តុលាការនៃបណ្ដឹងជំទាស់អាចស្ដែងឡើងក្នុងទិដ្ឋភាពដីកាសម្រេចពីរប្រភេទគឺ ដីកាសម្រេចរក្សាទុកដីកាសម្រេចដើម និងដីកាសម្រេចលុបចោលដីកាសម្រេចដើម។ ម្យ៉ាងទៀតដីកាសម្រេចទាំងពីរនេះ គឺភាគីមិនអាចជំទាស់ទៀតបាន

[130] មាត្រា.២៥៩.ចំណុច.គ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[131] មាត្រា.២៥៩.កថាខណ្ឌទី.៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[132] មាត្រា.២៥៩.កថាខណ្ឌទី.៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[133] មាត្រា.៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[134] មាត្រា.៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ឡើយ[135]។ប៉ុន្តែក្នុងករណីតុលាការនៃបណ្តឹងជំទាស់ចេញដីកាសម្រេចលុបចោលដីកាសម្រេចដើម ហើយបើម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬការបង់ប្រាក់ ឬប្រើប្រាស់ ឬថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចដើមនោះ តុលាការអាចបង្គាប់ឲ្យម្ចាស់បំណុលបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬសងប្រាក់ដែលកូនបំណុលបានបង់ ឬបង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ ឬថែរក្សាគ្រប់គ្រងបានតាមពាក្យសុំរបស់កូនបំណុល[136]។

[135] មាត្រា.២៥៩.កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[136] មាត្រា.៥៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ ស្វែងយល់អំពីច្បាប់ និងទ្រឹស្តីមួយចំនួន និងចងក្រងជាអត្ថបទសារណាស្តីអំពី " **ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ** " យើងអាចសង្កេតឃើញថាវិធានច្បាប់ទាំងនោះមានលក្ខណៈពេញលេញសម្រាប់ការអនុវត្តចំពោះ សិទ្ធិលើបំណុល ដែលម្ចាស់បំណុលបារម្ភខ្លាចថា ការអនុវត្តដោយបង្ខំមិនអាចធ្វើទៅបាន ឬមានការលំបាក។ ហើយ ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលវត្ថុនេះ វាក៏មិនមែនជាវិធានការណ៍មួយដែលថ្មីស្រឡាងសម្រាប់កម្ពុជានោះឡើយ ប៉ុន្តែវាគឺជាវិធានការថ្មីមួយដែលមានខ្លឹមសារ និងបញ្ជាក់អំពីនីតិវិធីក្នុងការដាក់ពាក្យសុំ និងការអនុវត្តច្បាស់លាស់។ ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមានចែងនៅក្នុង ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ របស់កម្ពុជា មានការវិវត្តន៍មកពីការសម្រេចកិច្ចការប្រញាប់ដែលមានបញ្ញាត្តិ នៅក្នុងសារាចរ ស្តីពី សេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី លេខ ០៤ សរច ៨៤ ចុះថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ ១៩៨៤ ដែលវាជាវិធានការបណ្តោះអាសន្ន និងបង្ការការអន្តរាយ ក៏ប៉ុន្តែដីកាសម្រេចជាការប្រញាប់នេះវាមានភាពហាក់ដូចជាមិនសូវច្បាស់លាស់នោះទេ។

ប្រសិនបើយើងសង្កេតមើលទៅលើទិដ្ឋភាពជាក់ស្តែងនៅក្នុងសង្គមវិញ ថាតើការអនុវត្តជាក់ស្តែងចំពោះការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមានលក្ខណៈត្រឹមត្រូវដែរ ឬទេ។ ច្បាប់គឺ គ្រាន់តែជាវិធានដែលបានបង្កើតឡើងដោយនីតិនិពន្ធ សម្រាប់ឲ្យមន្ត្រីអនុវត្តច្បាប់ និងប្រជាជនគោរពតាម អ្វីដែលជាចំណុចសំខាន់គឺថា តើការអនុវត្តច្បាប់បានធ្វើឡើងដោយត្រឹមត្រូវតាមច្បាប់ និងគោលបំណងរបស់នីតិនិពន្ធដែរ ឬទេ។ នៅក្នុងការរឹបអូសជាបណ្តោះអាសន្នចំពោះអចលវត្ថុ បើយើងសង្កេតមើលទៅវាហាក់ដូចជាមានការការពារសិទ្ធិរបស់ម្ចាស់បំណុលខ្លាំងណាស់ ប៉ុន្តែដើម្បីជៀសវាងពីចេតនាទុច្ចរឹតរបស់កូនបំណុលក្នុងការចាត់ចែងទ្រព្យដើម្បីរួចផុតពីការអនុវត្តដោយបង្ខំនោះ យើងអាចនិយាយថា ដូចជាសមហេតុ សមផលម្យ៉ាងដែល ដោយការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុគឺ គ្រាន់តែកម្រិតនូវសិទ្ធិចាត់ចែងរបស់កូនបំណុលតែប៉ុណ្ណោះ ហើយគេមិនបានបិទសិទ្ធិរបស់កូនបំណុលនៅក្នុងការតវ៉ាចំពោះសេចក្តីសម្រេចដែល ពោលគឺកូនបំណុលអាចបណ្តឹតវ៉ាចំពោះដីកាសម្រេចអំពីការរឹបអូសជាបណ្តោះអាសន្នបានប្រសិនបើខ្លួនយល់ថាការសម្រេចសេចក្តីនោះបានធ្វើឡើងដោយអយុត្តិធម៌។

ដោយហេតុថាការឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុចំពោះអចលវត្ថុ អាចនឹងមានភាពប៉ះពាល់ខ្លាំងទៅដល់ផលប្រយោជន៍នៃ ភាគីណាម្ខាងប្រសិនបើតុលាការមិនបានដើរតួនាទីអព្យាក្រឹត្យ និង ឯករាជ្យភាព ដែលខ្លួនជាអ្នកមានសិទ្ធិសម្រេចសេចក្តីទេនោះ។ ព្រោះថាការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុកម្រិតនូវសិទ្ធិសេរីភាព របស់កូនបំណុលក្នុងការ ចាត់ចែងនូវ

ទ្រព្យនោះ ប្រសិនបើតុលាការធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តីចំពោះពាក្យសុំរបស់ម្ចាស់បំណុលដោយផ្អែកទៅលើសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិ និងភាពចាំបាច់ដែលល័ក្ខខ័ណ្ឌសម្រាប់ការចេញដីកាសម្រេចនោះ បើតុលាការពិនិត្យលើល័ក្ខខណ្ឌ មានគ្រប់ហើយតុលាការចេញសេចក្តីសម្រេចនោះមានន័យថា ការសម្រេចសេចក្តីនោះត្រឹមត្រូវ ព្រោះដើម្បីការពារការលួចចាត់ចែងទ្រព្យសម្បិត្តរបស់កូនបំណុលដោយចេតនាទុច្ចរិត។ ក៏ប៉ុន្តែប្រសិនបើចៅក្រមគាត់ ធ្វើការសម្រេចសេចក្តីដោយប្រកាន់បក្សពួក ឬប្រព្រឹត្តអំពើមិនប្រក្រតីណាមួយនោះ គឺចៅក្រមនោះគាត់មានបុរេនិច្ឆ័យរួចទៅហើយ ទោះបីជាមានសេចក្តីបញ្ជាក់ដំបូង អំពីល័ក្ខខ័ណ្ឌសម្រាប់ការចេញ ដីកាសម្រេច និងភត្តុតាងក៏ដោយ ឬគ្មានក៏ដោយ ក៏ចៅក្រមនោះធ្វើការសម្រេចសេចក្តីឲ្យបក្សពួក របស់គេឈ្នះដែរ។ ដូចដែលបានបញ្ជាក់រួចហើយថា ទោះជាយ៉ាងណាក៏ដោយក៏គេមិនបានបិទសិទ្ធិរបស់ភាគីនៅក្នុងការបណ្តឹងតវ៉ាដែរ។

# អនុសាសន៍

ទី១៖ សម្រាប់រឿងក្តីរឹបអូសអូសជាបណ្តោះអាសន្ន ចៅក្រមក្នុងនាមជាអ្នកធ្វើការសម្រេចសេចក្តីត្រូវពិនិត្យមើលល័ក្ខខ័ណ្ឌសម្រាប់ការចេញដីកាសម្រេច និងថ្លឹងថ្លែង មុនចេញសេចក្តីសម្រេច។ នៅពេលដែលចៅក្រមសម្រេចសេចក្តីដោយមានភាពលំអៀង បណ្តាលឲ្យមានភាព អយុត្តធម៌ដល់ភាគីម្ខាងទៀត។ ចៅក្រមត្រូវយកចំណេះដឹង និងសមត្ថភាពដែលខ្លួនមានយកមកប្រើឲ្យអស់លិទ្ធភាព។ សម្រាប់ការសម្រេចសេចក្តីដែល ចៅក្រមត្រូវសម្រេចចិត្តដោយមិនលុះនូវអគតិ ទាំងបួនគឺ៖

- ភ័យោគតិ
- ឆន្ទាគតិ
- មោហាគតិ និង
- ទោសាគតិ។

ទី២៖ សម្រាប់ប្រជាជនមួយចំនួនធំ នៅមិនទាន់មានការយល់ដឹងភាពទូលំទូលាយនៃច្បាប់នៅឡើយ។ តួយ៉ាងដូចជានៅក្នុងរឿងរដ្ឋប្បវេណី ចំពោះពាក្យបណ្តឹងដែលមានគោលបំណងឲ្យសងជាប្រាក់ ឬសិទ្ធិលើបំណុលនោះ នាំឲ្យម្ចាស់បំណុលមួយចំនួនធំប្រាកដជាមិនដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឡើងប្រសិនជាមិនមានជំនួយពីអ្នកច្បាប់។ មិនត្រឹមតែប៉ុណ្ណោះចំពោះស្វែងរកភស្តុតាងសំខាន់មួយចំនួន ឬកិច្ចនីតិវិធីបន្ទាប់ ក៏អាចធ្វើឲ្យកូនបំណុល និងម្ចាស់បំណុលមានភាពលំបាកដោយសារការខ្វះចំណេះដឹងខាងច្បាប់។ ការខ្វះចំណេះដឹងខាង ផ្លូវច្បាប់នេះវាអាចធ្វើឲ្យភាគីម្ខាងណាមួយបាត់ប្រយោជន៍ ហើយវាក៏អាចក្លាយជាបន្ទុកបន្ថែមទៅ លើកូនបំណុលដែលខ្វះលិទ្ធភាពក្នុងការពឹងពាក់មេធាវីជាដើម។

ជាអនុសាសន៍៖

តាមរយៈក្រសួងយុត្តិធម៌

- បង្កើតសិក្ខាសាលាឲ្យបានច្រើនដែលទាក់ទងទៅនឹងផ្នែកច្បាប់
- ត្រូវពង្រឹងសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ ជាពិសេសចៅក្រម
- បង្កើតសាច់រឿងខ្លីៗ ដែលទាក់ទងនឹងរឿងរដ្ឋប្បវេណី ដែលនាពេលកន្លងមកភាគច្រើនសុទ្ធតែជាសាច់រឿងដែលទាក់ទងទៅនឹងរឿព្រហ្មទណ្ឌ

តាមរយៈស្ថានីយ៍វិទ្យុ ទូរទស្សន៍

- បង្កើតកម្មវិធីសំនួរ ចម្លើយដែលទាក់ទងនឹងផ្នែកច្បាប់ឲ្យបានច្រើនតាមរយៈ ស្ថានីយ៍វិទ្យុ
- បង្កើត និងបង្កើនការចាក់ផ្សាយកម្មវិធីបទសម្ភាសជាមួយអ្នកច្បាប់
- បង្កើនការចាក់ផ្សាយសាច់រឿងខ្លីៗដែលទាក់ទងខាងផ្លូវច្បាប់